# មាតិកា

## I~ខុទ្ទកាល័យព្រះមហាក្សត្រ

### ១~ព្រះរាជក្រម

១៤-១១-២០០៥ -ព្រះរាជក្រម នស/រកម/១១០៥/០៣៧ ស្តីពីការប្រកាសឱ្យប្រើច្បាប់ស្តីពីការអនុម័តយល់ព្រមឱ្យ ព្រះរាជាណាចក្រកម្ពុជា ចូលជាភាគី នៃពិធីសារ ស្តីពីការប្រឆាំងការរត់ពន្ធជនអន្តោប្រវេសន៍ នៅតាមដែនគោក ដែនសមុទ្រ និងដែនអាកាស ដែលបំពេញបន្ថែមលើអនុសញ្ញារបស់អង្គការសហប្រជាជាតិ ស្តីពីការប្រឆាំងបទឧក្រិដ្ឋកម្មឆ្លងដែនដែលមានអង្គការចាត់តាំង ៧២៥១

### ២~ព្រះរាជក្រឹត្យ

០២-១២-២០០៥ -ព្រះរាជក្រឹត្យ នស/រកត/១២០៥/៤៧៥ ស្តីពីការតែងតាំងលោក **អៀ ស៊ីផុន** ជា**ឧកញ៉ា** ៧២៨២

០២-១២-២០០៥ -ព្រះរាជក្រឹត្យ នស/រកត/១២០៥/៤៧៦ ស្តីពីការប្រោសព្រះរាជទាន គ្រឿងឥស្សរិយយស **សេនាជ័យសិទ្ធ** ចំពោះនាយទាហានជាន់ខ្ពស់ នៃកងយោធពលខេមរភូមិន្ទ ចំនួន ០២ រូប ៧២៨៣

០២-១២-២០០៥ -ព្រះរាជក្រឹត្យ នស/រកត/១២០៥/៤៧៧ ស្តីពីការប្រោសព្រះរាជទាន គ្រឿងឥស្សរិយយស **សហមេត្រី** តាមលំដាប់ថ្នាក់ចំពោះនាយទាហានជាន់ខ្ពស់ នៃកងទ័ពប្រជាជនវៀតណាម ចំនួន ០៥ រូប ៧២៨៤

០២-១២-២០០៥ -ព្រះរាជក្រឹត្យ នស/រកត/១២០៥/៤៧៨ ស្តីពីការប្រោសព្រះរាជទាននូវគ្រឿងឥស្សរិយយសតាមលំដាប់ថ្នាក់ជូនចំពោះ កងឯកភាព ០១ និងនាយទាហាន មន្ត្រីជាន់ខ្ពស់ សប្បុរសជន ចំនួន ២៦ រូប ដែលមានស្នាដៃល្អ និងគុណបំណាច់ក្នុងការបំពេញភារកិច្ច និងជួយកសាងអភិវឌ្ឍន៍ កងពលតូចលេខ ៧០ ៧២៨៥

០២-១២-២០០៥ -ព្រះរាជក្រឹត្យ នស/រកត/១២០៥/៤៧៩ ស្តីពីការប្រោសព្រះរាជទានចំពោះ ឯកឧត្តម **សូរ ជុំឃួរ** នូវគ្រឿងឥស្សរិយយស **ព្រះរាជាណាចក្រកម្ពុជា** ថ្នាក់ **ធិបឌិន្ទ** ៧២៨៧

០២-១២-២០០៥ -ព្រះរាជក្រឹត្យ នស/រកត/១២០៥/៤៨០ ស្ដីពី :
-ត្រូវបានតម្លើងឋានន្តរសក្តិជូនលោក **គង ស៊ាន** ពីឋានន្តរសក្តិវរមន្ត្រីថ្នាក់លេខ ៥ ទៅជា ឧត្តមមន្ត្រីថ្នាក់លេខ ៥
-ត្រូវបានតម្លើងឋានន្តរសក្តិជូនមន្ត្រីរាជការចំនួន ០៦ រូប ពីក្របខ័ណ្ឌមន្ត្រីក្រមការ ទៅក្នុងក្របខ័ណ្ឌមន្ត្រីរដ្ឋបាលជាន់ខ្ពស់ ៧២៨៨

០២-១២-២០០៥ -ព្រះរាជក្រឹត្យ នស/រកត/១២០៥/៤៨២ ស្ដីពីការតែងតាំងឯកឧត្តម **ឈឹម សៅគី** ជាទីប្រឹក្សាអមទីស្ដីការគណៈរដ្ឋមន្ត្រី មានឋានៈស្មើ **អនុរដ្ឋលេខាធិការ** ៧២៩០

០៥-១២-២០០៥ -ព្រះរាជក្រឹត្យ នស/រកត/១២០៥/៤៨៣ ស្ដីពីការតែងតាំងឯកឧត្តម **ថាច់ វណ្ណៈ** ជាទីប្រឹក្សាផ្ទាល់សម្ដេច **នរោត្តម សិរីវុឌ្ឍ** ឧបនាយករដ្ឋមន្ត្រី មានឋានៈស្មើ **អនុរដ្ឋលេខាធិការ** ដោយមិនទទួលប្រាក់បៀវត្ស បន្ថែមលើមុខងារបច្ចុប្បន្ន ៧២៩១

## II. ក្រុមប្រឹក្សាធម្មនុញ្ញ

០៦-១២-២០០៥ -សេចក្ដីជូនដំណឹងលេខ ១២/២០០៥ កបធ.សជណ ស្ដីពីករណីសូមចាត់ទុកជាអាសាសូន្យ នូវក្ដីសំរេចរបស់រដ្ឋសភាលើសន្ធិសញ្ញាបំពេញបន្ថែម រវាងព្រះរាជាណាចក្រកម្ពុជា និង សាធារណរដ្ឋសង្គមនិយមវៀតណាម ទៅលើសន្ធិសញ្ញាកំណត់ព្រំដែនរដ្ឋ ឆ្នាំ ១៩៨៥ ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី ១១ ខែ វិច្ឆិកា ឆ្នាំ ២០០៥ កន្លងទៅ ៧២៩២

## III. រាជរដ្ឋាភិបាល

### ១. អនុក្រឹត្យ

០៧-១២-២០០៥ -អនុក្រឹត្យលេខ ១៣៨ អនក្រ.បក ស្ដីពីការទទួលស្គាល់វិទ្យាស្ថាន រ៉ូវលីង ៧២៩៣
០១-១២-២០០៥ -អនុក្រឹត្យលេខ ៨៤១ អនក្រ.តត ស្ដីពីការជូនមេដាយស្ថាបនាជាតិ ៧២៩៦
០១-១២-២០០៥ -អនុក្រឹត្យលេខ ៨៤២ អនក្រ.តត ស្ដីពីការជូនមេដាយស្ថាបនាជាតិ ៧២៩៧
០១-១២-២០០៥ -អនុក្រឹត្យលេខ ៨៤៣ អនក្រ.តត ស្ដីពីការជូនមេដាយការងារ ៧២៩៨
០១-១២-២០០៥ -អនុក្រឹត្យលេខ ៨៤៤ អនក្រ.តត ស្ដីពីការជូនមេដាយស្ថាបនាជាតិ ៧២៩៩
០២-១២-២០០៥ -អនុក្រឹត្យលេខ ៨៤៥ អនក្រ.តត ស្ដីពីការជូនមេដាយសុវត្ថារា ៧៣០០
០២-១២-២០០៥ -អនុក្រឹត្យលេខ ៨៤៦ អនក្រ.តត ស្ដីពីការជូនមេដាយស្ថាបនាជាតិ ៧៣០១

០២-១២-២០០៥ -អនុក្រឹត្យលេខ ៨៤៧ អនក្រ.តត ស្ដីពីការជូនមេដាយសហមេត្រី ៧៣០២

០២-១២-២០០៥ -អនុក្រឹត្យលេខ ៨៤៨ អនក្រ.តត ស្ដីពីការជូនមេដាយស្ថាបនាជាតិ ៧៣០៣

០២-១២-២០០៥ -អនុក្រឹត្យលេខ ៨៤៩ អនក្រ.តត ស្ដីពីការជូនមេដាយមុនីសារាភ័ណ្ឌ ៧៣០៤

០៥-១២-២០០៥ -អនុក្រឹត្យលេខ ៨៥០ អនក្រ.តត ស្ដីពីការតែងតាំងប្រធានអគ្គនាយកចំការកៅស៊ូ ៧៣០៥

០៥-១២-២០០៥ -អនុក្រឹត្យលេខ ៨៥១ អនក្រ.តត ស្ដីពីការតែងតាំងសមាសភាពក្រុមប្រឹក្សាភិបាលប្រចាំចំការកៅស៊ូ សម្រាប់អាណត្តិទី ៣ ៧៣០៧

០៦-១២-២០០៥ -អនុក្រឹត្យលេខ ៨៥២ អនក្រ.តត ស្ដីពីការជូនមេដាយមុនីសារាភ័ណ្ឌ ៧៣១០

០៦-១២-២០០៥ -អនុក្រឹត្យលេខ ៨៥៣ អនក្រ.តត ស្ដីពីការជូនមេដាយការងារ ៧៣១២

០៦-១២-២០០៥ -អនុក្រឹត្យលេខ ៨៥៤ អនក្រ.តត ស្ដីពីការជូនមេដាយស្ថាបនាជាតិ ៧៣១៤

០៦-១២-២០០៥ -អនុក្រឹត្យលេខ ៨៥៥ អនក្រ.តត ស្ដីពីការជូនមេដាយការងារ ៧៣១៥

០៦-១២-២០០៥ -អនុក្រឹត្យលេខ ៨៥៦ អនក្រ.តត ស្ដីពីការជូនមេដាយសុវត្ថារា ៧៣២១

០៦-១២-២០០៥ -អនុក្រឹត្យលេខ ៨៥៧ អនក្រ.តត ស្ដីពីការជូនមេដាយស្ថាបនាជាតិ ៧៣២៣

០៦-១២-២០០៥ -អនុក្រឹត្យលេខ ៨៥៨ អនក្រ.តត ស្ដីពីការជូនមេដាយស្ថាបនាជាតិ ៧៣២៤

០៦-១២-២០០៥ -អនុក្រឹត្យលេខ ៨៥៩ អនក្រ.តត ស្ដីពីការជូនមេដាយការងារ ៧៣២៥

០៦-១២-២០០៥ -អនុក្រឹត្យលេខ ៨៦០ អនក្រ.តត ស្ដីពីការជូនមេដាយសហមេត្រី ៧៣៦៩

០៦-១២-២០០៥ -អនុក្រឹត្យលេខ ៨៦១ អនក្រ.តត ស្ដីពីការជូនមេដាយសុវត្ថារា ៧៣៧០

០៦-១២-២០០៥ -អនុក្រឹត្យលេខ ៨៦២ អនក្រ.តត ស្ដីពីការជូនមេដាយការងារ ៧៣៧១

០៧-១២-២០០៥ -អនុក្រឹត្យលេខ ៨៦៣ អនក្រ.តត ស្ដីពីការជូនមេដាយសហមេត្រី ៧៣៧៣

០៧-១២-២០០៥ -អនុក្រឹត្យលេខ ៨៦៤ អនក្រ.តត ស្ដីពីការជូនមេដាយមុនីសារាភ័ណ្ឌ ៧៣៧៤

០៧-១២-២០០៥ -អនុក្រឹត្យលេខ ៨៦៥ អនក្រ.តត ស្ដីពីការតែងតាំងមុខតំណែងនាយនគរបាលជាតិ ៧៣៧៥

០៧-១២-២០០៥ -អនុក្រឹត្យលេខ ៨៦៦ អនក្រ.តត ស្ដីពីការតែងតាំង និងតម្លើងឋានន្តរសក្តិនាយនគរបាលជាតិ ៧៣៧៦

០៨-១២-២០០៥ -អនុក្រឹត្យលេខ ៨៦៧ អនក្រ.តត ស្ដីពីការជូនមេដាយស្ថាបនាជាតិ ៧៣៧៨

០៨-១២-២០០៥ -អនុក្រឹត្យលេខ ៨៦៨ អនក្រ.តត ស្ដីពីការជូនមេដាយស្ថាបនាជាតិ ៧៣៧៩

០៨-១២-២០០៥ -អនុក្រឹត្យលេខ ៨៦៩ អនក្រ.តត ស្ដីពីការជូនមេដាយស្ថាបនាជាតិ ៧៣៨១

០៨-១២-២០០៥ -អនុក្រឹត្យលេខ ៨៧០ អនក្រ.តត ស្តីពីការជូនមេដាយមុនីសារាភ័ណ្ឌ ៧៣៨២
០៨-១២-២០០៥ -អនុក្រឹត្យលេខ ៨៧១ អនក្រ.តត ស្តីពីការជូនមេដាយការងារ ៧៣៨៣
០៨-១២-២០០៥ -អនុក្រឹត្យលេខ ៨៧២ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ ៧៣៨៤
០៨-១២-២០០៥ -អនុក្រឹត្យលេខ ៨៧៣ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ ៧៣៨៥
០៨-១២-២០០៥ -អនុក្រឹត្យលេខ ៨៧៤ អនក្រ.តត ស្តីពីការជូនមេដាយការងារ ៧៣៨៦
០៨-១២-២០០៥ -អនុក្រឹត្យលេខ ៨៧៥ អនក្រ.តត ស្តីពីការផ្ទេរភារកិច្ចជុននាយទាហាន ៧៣៨៧
០៨-១២-២០០៥ -អនុក្រឹត្យលេខ ៨៧៦ អនក្រ.តត ស្តីពីការតែងតាំងក្រុមប្រឹក្សាភិបាលសំរាប់ដឹកនាំវិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា ៧៣៨៨
០៨-១២-២០០៥ -អនុក្រឹត្យលេខ ៨៧៧ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ ៧៣៩០
០៨-១២-២០០៥ -អនុក្រឹត្យលេខ ៨៧៨ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ ៧៣៩២

## ២-សេចក្តីសំរេច

០៦-១២-២០០៥ -សេចក្តីសំរេចលេខ ៥២ សសរ ស្តីពីការកែសម្រួលប្រាក់ឧបត្ថម្ភគោលនយោបាយធានារ៉ាប់រងសង្គមសំរាប់មន្ត្រីរាជការស៊ីវិល ៧៣៩៤
០៧-១២-២០០៥ -សេចក្តីសំរេចលេខ ៥៣ សសរ ស្តីពីការបង្កើតគណៈកម្មាធិការពិនិត្យវាយតម្លៃក៏រិតសញ្ញាប័ត្រ និង លិខិតបញ្ជាក់ការសិក្សា ៧៣៩៧
០៨-១២-២០០៥ -សេចក្តីសំរេចលេខ ៥៤ សសរ ស្តីពីការបង្កើតគណៈកម្មការអន្តរក្រសួងដោះស្រាយបញ្ហាពាក់ព័ន្ធនឹងការសាងសង់ព្រះពុទ្ធបដិមាអង្គធំ នៅវត្តឯកភ្នំ ឃុំពាមឯក ស្រុកឯកភ្នំ ខេត្តបាត់ដំបង ៧៤០០

# IV-ការងារបណ្តាក្រសួង

## ១-ទិស្តីការរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

០១-១២-២០០៥ -សារាចរណែនាំលេខ ០០៩ សហវ ស្តីពីការគ្រប់គ្រងទំនិញនាំចូលគ្មានលក្ខណៈពាណិជ្ជកម្ម ៧៤០២

## ២-ទិស្តីការរដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល

០១-១២-២០០៥ -ប្រកាសលេខ ៩០២ ឧរថ.កឧ.ប្រក ស្តីពីការអនុញ្ញាតឱ្យក្រុមហ៊ុន អ៊ិហ្គាមេន បង្កើតរោងចក្រ "កាត់ដេរសម្លៀកបំពាក់ " ដែលមានឈ្មោះថា "អ៊ិហ្គាមេន " ៧៤០៧

០៦-១២-២០០៥ -ប្រកាសលេខ៩២២ ឧរថ.កឧ.ប្រក ស្ដីពីការអនុញ្ញាតឱ្យក្រុមហ៊ុន នូវខប បង្កើតរោងចក្រ "កាត់ដេរសម្លៀកបំពាក់ " ដែលមានឈ្មោះថា "នូវខប " ៧៤០៩

០៨-១២-២០០៥ -ប្រកាសលេខ ៩៣២ ឧរថ.កឧ.ប្រក ស្ដីពីការអនុញ្ញាតឱ្យក្រុមហ៊ុន សាងរ៉ូ (ខេមបូឌា) បង្កើតរោងចក្រ "កាត់ដេរសម្លៀកបំពាក់ " ដែលមានឈ្មោះថា "សាងរ៉ូ (ខេមបូឌា) " ៧៤១១

០៨-១២-២០០៥ -ប្រកាសលេខ ៩៣៣ ឧរថ.កឧ.ប្រក ស្ដីពីការអនុញ្ញាតឱ្យក្រុមហ៊ុន វ៉ូស៊ូ ស៊ីអិនអេស (ខេមបូឌា) បង្កើតរោងចក្រ " កាត់ដេរសម្លៀកបំពាក់ " ដែលមានឈ្មោះថា " វ៉ូស៊ូ ស៊ីអិនអេស (ខេមបូឌា) " ៧៤១៣

## ៣_ទីស្ដីការរដ្ឋមន្ត្រីក្រសួងការងារ និង បណ្ដុះបណ្ដាលវិជ្ជាជីវៈ

០២-១២-២០០៥ -ប្រកាសលេខ ១៨៨៦ ក.ក.ប.វ ស្ដីពីការឈប់បុណ្យដែលត្រូវមានប្រាក់ឈ្នួល ប្រចាំឆ្នាំ២០០៦ ៧៤១៥

## ៤_ទីស្ដីការរដ្ឋមន្ត្រីក្រសួងយុត្តិធម៌

១៩-៨-២០០៥ -សេចក្ដីណែនាំលេខ ០៣កយ.សណន/២០០៥ ស្ដីអំពីការអនុវត្តន៍គោលការណ៍នានាក្នុងច្បាប់ជាតិ និងអន្តរជាតិដែលកំពុងនៅជាធរមាន ទាក់ទងនឹងការការពារជនរងគ្រោះ នៃបទល្មើសព្រហ្មទណ្ឌ ៧៤១៧

# ព្រះរាជក្រម

នស/រកម/១១០៥/០៣៧

## យើង

## ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
## សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
## ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
## ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

-បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

-បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា

-បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាស ឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ

-បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចនាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា និងរបស់សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## ប្រកាសឱ្យប្រើ

ច្បាប់ស្តីពីការអនុម័តយល់ព្រម ឱ្យព្រះរាជាណាចក្រកម្ពុជាចូលជាភាគី នៃពិធីសារស្តីពីការប្រឆាំងការរត់ពន្ធជនអន្តោប្រវេសន៍នៅតាមដែនគោក ដែនសមុទ្រ និងដែនអាកាសដែលបំពេញបន្ថែមលើអនុសញ្ញារបស់អង្គការសហប្រជាជាតិស្តីពីការប្រឆាំងបទឧក្រិដ្ឋកម្មឆ្លងដែនដែលមានអង្គការចាត់តាំង ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី ៣១ ខែ សីហា ឆ្នាំ ២០០៥ នាសម័យប្រជុំរដ្ឋសភាលើកទី ៣ នីតិកាលទី ៣ និងព្រឹទ្ធសភាបានអនុម័តយល់ស្របលើទម្រង់ និងគតិនៃច្បាប់នេះទាំងស្រុងកាលពីថ្ងៃទី ១៩ ខែ កញ្ញា ឆ្នាំ ២០០៥ នាសម័យប្រជុំពេញអង្គលើកទី ១០ នីតិកាលទី ១ ដែលមានសេចក្តីទាំងស្រុងដូចតទៅនេះ :

# ច្បាប់
# ស្តីពី
# ការអនុម័តយល់ព្រមឱ្យព្រះរាជាណាចក្រកម្ពុជាចូលជាភាគីនៃពិធីសារ ស្តីពីការប្រឆាំងការរត់ពន្ធជនអន្តោប្រវេសន៍ នៅតាមដែនគោក ដែនសមុទ្រ និងដែនអាកាស ដែលបំពេញបន្ថែមលើអនុសញ្ញា របស់អង្គការសហប្រជាជាតិ ស្តីពីការប្រឆាំងបទឧក្រិដ្ឋកម្ម ឆ្លងដែនដែលមានអង្គការចាត់តាំង

មាត្រា ១.-

អនុម័តយល់ព្រមឱ្យព្រះរាជាណាចក្រកម្ពុជាចូលជាភាគីនៃពិធីសារស្តីពីការប្រឆាំងការរត់ពន្ធជនអន្តោប្រវេសន៍នៅតាមដែនគោក ដែនសមុទ្រ និងដែនអាកាស ដែលបំពេញបន្ថែមលើអនុសញ្ញារបស់អង្គការសហប្រជាជាតិស្តីពីការប្រឆាំងបទឧក្រិដ្ឋកម្មឆ្លងដែន ដែលមានអង្គការចាត់តាំង ដែលអនុម័តដោយមហាសន្និបាតអង្គការសហប្រជាជាតិ ក្នុងសម័យប្រជុំលើកទី ៥៥ តាមសេចក្តីសម្រេចលេខ ៥៥/២៥ ចុះថ្ងៃទី ១៥ ខែ វិច្ឆិកា ឆ្នាំ ២០០០ នៅទីក្រុងញូវយ៉ក ហើយដែលព្រះរាជាណាចក្រកម្ពុជា បានចុះហត្ថលេខាចូលជាភាគី នាថ្ងៃទី ១១ ខែ វិច្ឆិកា ឆ្នាំ ២០០១ ដូចមានអត្ថបទទាំងស្រុងភ្ជាប់មកជាមួយនេះ ។

មាត្រា ២.-

រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ត្រូវបន្តរាល់នីតិវិធីដើម្បីអនុវត្តពិធីសារនេះ ។

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ ថ្ងៃទី ១៤ ខែ វិច្ឆិកា ឆ្នាំ ២០០៥

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ

នរោត្តម សីហមុនី

នស/រកម.០៥១១.៥០៤

បានយកសេចក្តីក្រាបបង្គំទូលថ្វាយ

សូមឡាយព្រះហស្តលេខាព្រះមហាក្សត្រ

នាយករដ្ឋមន្ត្រី

ហត្ថលេខា

ហ៊ុន សែន

បានជម្រាបជូនសម្តេចនាយករដ្ឋមន្ត្រី

សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

ហត្ថលេខា ព្រះហស្តលេខា

ស ខេង នរោត្តម សិរីវុឌ្ឍ

លេខ ... ច.ល

ដើម្បីចម្លងចែក

រាជធានីភ្នំពេញ ថ្ងៃទី ... ខែ ... ឆ្នាំ២០០៥

អគ្គលេខាធិការរាជរដ្ឋាភិបាល

សណ្ឋាយ ... តាន់

# ពិធីសារប្រឆាំងនឹងការរត់ពន្ធជនអន្តោប្រវេសន៍ នៅតាមដែនគោក ដែនសមុទ្រ ដែនអាកាស និង ការបំពេញបន្ថែមនៅក្នុងអនុសញ្ញារបស់អង្គការសហប្រជាជាតិ ស្តីពីការប្រឆាំងនឹងបទឧក្រិដ្ឋកម្មឆ្លងដែន

អត្ថបទដែលដកស្រង់ពីច្បាប់ដើម ការថតចម្លងនេះត្រូវ បានបញ្ជាក់ដោយអគ្គលេខាធិការអង្គការសហប្រជាជាតិ និងត្រូវបានគេចេញផ្សាយនៅពេលក្រោយ

អង្គការសហប្រជាជាតិ

២០០០

# ពិធីសារប្រឆាំងនៅនឹងការរត់ពន្ធជនអន្តោប្រវេសន៍ នៅតាមដែនគោក ដែនសមុទ្រ ដែនអាកាស និង ការបំពេញបន្ថែមនៅក្នុងអនុសញ្ញារបស់អង្គការសហប្រជាជាតិ ស្តីពីការប្រឆាំងនៅនឹងបទឧក្រិដ្ឋកម្មឆ្លងដែន

## អារម្ភកថា

### ការចូលរួមរបស់បណ្តារដ្ឋដែលជាសមាជិកចំពោះពិធីសារនេះ

សេចក្តីប្រកាសស្តីអំពីសកម្មភាពដ៏មានប្រសិទ្ធភាពក្នុងកិច្ចការពារប្រឆាំងទៅនឹងការរត់ពន្ធជនអន្តោប្រវេសន៍នៅតាមដែនគោក ដែនសមុទ្រ និងដែនអាកាសតម្រូវអោយមានការចូលរួមយ៉ាងទូលំទូលាយជាអន្តរជាតិ រួមមានទាំងកិច្ចសហប្រតិបត្តិការ ការផ្លាស់ប្តូរពត៌មានទៅវិញទៅមកហើយនិងវិធានការសមស្របដទៃទៀត ក្នុងនោះរួមមានវិធានការសេដ្ឋកិច្ច សង្គម ក្នុងកម្រិតជាតិ និងអន្តរជាតិនៅតាមតំបន់ ។

ការរំលឹកឡើងវិញនូវមហាសន្និបាត អង្គការសហប្រជាជាតិ សេចក្តីសម្រេចលេខ ៥៤/១២១២ នាថ្ងៃទី២២ ខែ ធ្នូ ឆ្នាំ ១៩៩៩ ក្នុងមហាសន្និបាតនេះបានជម្រុញអោយបណ្តារដ្ឋដែលជាសមាជិក និងអង្គការសហប្រជាជាតិពង្រឹងនូវកិច្ចសហប្រតិបត្តិការអន្តរជាតិ នៅតាមតំបន់នូវផ្នែកអន្តោប្រវេសន៍អន្តរជាតិ ហើយនិងការអភិវឌ្ឍន៍ដើម្បីកត់សំគាល់នូវឫសគល់នៃបុព្វហេតុជនអន្តោប្រវេសន៍ ជាពិសេសបណ្តារដ្ឋជាសមាជិកទាំងនោះដែលទាក់ទិនទៅនឹងភាពក្រីក្រ ហើយនិងដើម្បីបង្កើននូវអត្ថប្រយោជន៍ដែលពាក់ព័ន្ធទៅនឹងជនអន្តោប្រវេសន៍អន្តរជាតិ និងធ្វើការលើកទឹកចិត្តកន្លែងណាដែលពាក់ព័ន្ធទៅនឹងយន្តការនៅតាមតំបន់ និងអនុតំបន់អន្តរជាតិ ដើម្បីបន្តដោះស្រាយនូវបញ្ហាអន្តោ-ប្រវេសន៍ និងការអភិវឌ្ឍន៍ ។

ធ្វើអោយជាក់លាក់នូវសេចក្តីត្រូវការដើម្បីផ្តល់អោយជនអន្តោប្រវេសន៍ ជាមួយនឹងការថែទាំដោយក្តីមេត្តា ហើយនិងកិច្ចការពារដ៏ពេញលេញនៃសិទ្ធិរបស់គេ ។

ទទួលខុសត្រូវនូវការពិត ថ្វីត្បិតតែកិច្ចការដែលបានធានាអះអាងនៅកិច្ចប្រជុំអន្តរជាតិដទៃទៀតក៏ដោយ ក៏មិនមានការអនុវត្តន៍ជាទូទៅដែលកត់សំគាល់នៅរាល់ចំណុចនៃការរត់ពន្ធជនអន្តោប្រវេសន៍ ហើយនិងបញ្ហាដែលទាក់ទិនដទៃទៀត ។

ទាក់ទិនទៅនឹងការកើនឡើងនូវសកម្មភាពសំខាន់ៗនៃក្រុមឧក្រិដ្ឋជនដែលមានអង្គការចាត់តាំងឡើងក្នុងការរត់ពន្ធជនអន្តោប្រវេសន៍ ហើយនិងទាក់ទិនទៅនឹងសកម្មភាពបទឧក្រិដ្ឋកម្មដទៃទៀត ដែលបានកំណត់ក្នុងពិធីសារនេះដែលនឹងនាំមកនូវផលអាក្រក់យ៉ាងធំដល់បណ្តារដ្ឋដែលពាក់ព័ន្ធ ។

ទន្ទឹមនឹងនោះការរត់ពន្ធជនអន្តោប្រវេសន៍ក៏មានពាក់ព័ន្ធផងដែរដែលអាចធ្វើអោយមានគ្រោះថ្នាក់ដល់អាយុជីវិត ឬក៏សុវត្ថិភាពដែលពាក់ព័ន្ធទៅនឹងជនអន្តោប្រវេសន៍ ។

ការរលើកឡើងវិញនូវសេចក្តីសំរេចចិត្តរបស់អង្គការសហប្រជាជាតិលេខ ៥៣/១១១ ចុះថ្ងៃទី ០៣ ខែ ធ្នូ ឆ្នាំ ១៩៩៨ តាមមហាសន្និបាតបានសំរេច ដើម្បីបង្កើតឡើងនូវគណៈកម្មាធិការសិទ្ធិមនុស្សមួយជាអន្តររដ្ឋាភិបាល ដោយគ្មានដែនកំណត់ក្នុងគោលបំណងពិភាក្សាអោយបានល្អិតល្អន់ទូលំទូលាយ នៃអនុសញ្ញាអន្តរជាតិក្នុងការប្រឆាំងនឹងបទឧក្រិដ្ឋកម្មឆ្លងដែនដែលមានអង្គការចាត់តាំង ហើយនឹងធ្វើការពិភាក្សាគ្នាអោយបានហ្មត់ចត់ ក្នុងនោះរួមមានទាំងឯកសារច្បាប់អន្តរជាតិដែលបង្ហាញនូវការជួញដូរខុសច្បាប់ ក្នុងការដឹកជញ្ជូនជនអន្តោប្រវេសន៍នៅតាមដែនសមុទ្រ ។

ធ្វើអោយជាក់លាក់នូវការបំពេញបន្ថែមនៃអនុសញ្ញារបស់អង្គការសហប្រជាជាតិ ប្រឆាំងទៅនឹងបទឧក្រិដ្ឋ-កម្មឆ្លងដែនដែលមានអង្គការចាត់តាំង ជាមួយនឹងឯកសារច្បាប់អន្តរជាតិ ប្រឆាំងទៅនឹងការរត់ពន្ធជនអន្តោប្រវេស្តន៍តាមដែនគោក ដែនសមុទ្រ និងដែនអាកាស នឹងមានអត្ថប្រយោជន៍ក្នុងកិច្ចការពារ ហើយនិងប្រយុទ្ធប្រឆាំងទៅនឹងបទឧក្រិដ្ឋកម្មទាំងនោះ ។

ចុះទការព្រមព្រៀងដូចខាងក្រោមនេះ:

## I-បទបញ្ញត្តិទូទៅ

## មាត្រា ១

## ការទាក់ទិនទៅនឹងអនុសញ្ញារបស់អង្គការសហប្រជាជាតិ ប្រឆាំងនឹងបទឧក្រិដ្ឋកម្មឆ្លងដែនដែលមានអង្គការចាត់តាំង

១-ការបំពេញបន្ថែមនូវអនុសញ្ញារបស់អង្គការសហប្រជាជាតិ នៃពិធីសារនេះដើម្បីប្រឆាំងទៅនឹងបទឧក្រិដ្ឋកម្មឆ្លងដែន នឹងត្រូវបានបកស្រាយរួមគ្នាទៅតាមអនុសញ្ញា ។

២-បទបញ្ញត្តិនៃអនុសញ្ញានេះ នឹងអនុវត្តទៅតាមការផ្លាស់ប្តូរសមរម្យចំពោះពិធីសារនេះលុះត្រាតែមានអ្វីៗផ្សេងទៀតដែលមានចែងនៅទីនេះ ។

៣-បទល្មើសទាំងនេះបានបង្កើតឡើងដោយអនុលោមទៅតាមមាត្រា ៦ នៃពិធីសារនេះនឹងត្រូវបានចាត់ទុកជាបទល្មើសដែលបានបង្កើតឡើងដោយយោងទៅតាមអនុសញ្ញា ។

## មាត្រា ២

## អត្ថប្រយោជន៍ នៃសេចក្តីថ្លែងការណ៍

គោលបំណងនៃពិធីសារនេះ ត្រូវតែការពារ ហើយនិងប្រយុទ្ធប្រឆាំងទៅនឹងអំពើរត់ពន្ធជនអន្តោប្រវេសន៍ក៏ដូចជាការជំរុញអោយកិច្ចសហប្រតិបត្តិការនៅក្នុងចំណោមរដ្ឋជាសមាជិកដែលបានបញ្ចប់ ក្នុងខណៈនៃកិច្ចការពារសិទ្ធិជនអន្តោប្រវេសន៍ដែលត្រូវបានរត់ពន្ធ ។

## មាត្រា ៣

## ការប្រើប្រាស់ពាក្យស័ព្ទ

ចំពោះគោលបំណងនៃពិធីសារនេះគឺ :

(a)-"អំពើរត់ពន្ធជនអន្តោប្រវេសន៍" នឹងសំដែងអោយឃើញនូវការទាក់ទាញ ក្នុងគោលបំណងដើម្បីទទួលបាននូវផលប្រយោជន៍ផ្នែកសំភារៈ និងហិរញ្ញវត្ថុដោយផ្ទាល់ ឬដោយប្រយោលនៃជនណាម្នាក់ដែលបានចូលដោយខុសច្បាប់ទៅក្នុងរដ្ឋមួយជាសមាជិក ដែលជននោះមិនមែនជាសញ្ជាតិរបស់ខ្លួន ឬក៏ការគ្មានអាសយដ្ឋានអចិន្ត្រៃយ៍ ។

(b)-"ការចូលដោយខុសច្បាប់" មានន័យថាការឆ្លងកាត់ព្រំដែនដោយពុំបានអនុវត្តទៅតាមតម្រូវការជាចាំបាច់ ចំពោះការចូលដោយស្របច្បាប់ទៅក្នុងរដ្ឋដែលជាម្ចាស់ផ្ទះ ។

(c)-"ការបន្លំអត្តសញ្ញាណ ឬក៏ឯកសារធ្វើដំណើរ" គឺសំដៅទៅលើអត្តសញ្ញាណ ឬក៏ឯកសារនៃការធ្វើដំណើរណាមួយ ។

(i)-កិច្ចការដែលត្រូវបានធ្វើដោយក្លែងបន្លំ ឬក៏កែប្រែទៅតាមមធ្យោបាយសំភារៈខ្លះៗដោយជនណាម្នាក់ផ្សេងទៀត ឬក៏ទីភ្នាក់ងារណាមួយដែលត្រូវបានអនុញ្ញាតនូវច្បាប់ពេញលេញដើម្បីធ្វើ ឬក៏ចេញនូវឯកសារធ្វើដំណើរឬអត្តសញ្ញាណក្នុងនាមរដ្ឋមួយ ឬក៏

(ii)-កិច្ចការដែលត្រូវបានចេញផ្សាយមិនប្រក្រតី ឬក៏បានទទួលតាមរយៈការរាយការណ៍បំផ្លើស អំពើពុករលួយ ឬក៏ការបង្ខិតបង្ខំ ឬក៏ក្នុងលក្ខណៈខុសច្បាប់ដទៃផ្សេងទៀត ឬក៏

(iii)-កិច្ចការដែលកំពុងតែត្រូវបានប្រើប្រាស់ដោយបុគ្គលម្នាក់ដែលមិនមែនជាអ្នកកាន់កាប់ត្រឹមត្រូវ ។

(d)-"នាវា" គឺសំដៅទៅលើប្រភេទនាវាទឹកណាមួយដោយរាប់បញ្ចូលទាំងនាវាដែលនៅនឹងកន្លែង ហើយនឹងនាវាសមុទ្រដែលបានប្រើប្រាស់ ឬដែលអាចត្រូវបានប្រើប្រាស់ជាមធ្យោបាយដឹកជញ្ជូនតាមផ្លូវទឹកលើកលែងតែនាវាចំបាំង នាវាជំនួយ ឬក៏នាវាជាកម្មសិទ្ធិដទៃទៀតដែលប្រើប្រាស់ដោយរដ្ឋាភិបាលមួយ ហើយនឹងបានប្រើប្រាស់នាពេលបច្ចុប្បន្ននេះដោយរដ្ឋាភិបាលដែលមិនមែនជាសេវាកម្មខាងផ្នែកពាណិជ្ជកម្ម ។

## មាត្រា ៤
## វិសាលភាពនៃការអនុវត្តន៍

ពិធិសារនេះនឹងអនុវត្តលើកលែងតែពិធីសារផ្សេងទៀតដែលបានចែងនៅក្នុងមាត្រានេះដើម្បីធ្វើការទប់ស្កាត់ ធ្វើការស៊ើបអង្កេត ហើយនិងធ្វើការកាត់ទោសនៃបទល្មើសទាំងឡាយដែលបានបង្កើតឡើងដោយអនុលោមទៅតាម មាត្រា ៦ នៃពិធីសារនេះ ដែលបទល្មើសឆ្លងដែនទាំងនេះតាមធម្មតាពាក់ព័ន្ធទៅនឹងក្រុមឧក្រិដ្ឋជនមួយដែលបាន រៀបចំឡើង ព្រមទាំងពាក់ព័ន្ធទៅនឹងកិច្ចការពារសិទ្ធិមនុស្សនៃអ្នកទាំងឡាយដែលមានទោសកម្មផ្នែកបទល្មើសដូច នេះ ។

## មាត្រា ៥
## ការទទួលខុសត្រូវនៃបទឧក្រិដ្ឋផ្នែកជនអន្តោប្រវេសន៍

ជនអន្តោប្រវេសន៍ទាំងអស់នឹងមិនអាចទទួលយកបាននូវការកាត់ទោសផ្នែកបទឧក្រិដ្ឋ ដែលស្ថិតនៅក្រោម ពិធីសារនេះ ចំពោះភាពពិតដែលបានប្រព្រឹត្តនូវទោសកម្មចំពោះមុខដូចបានកំណត់ក្នុងមាត្រា ៦ នៃពិធីសារនេះ ។

## មាត្រា៦
## ការប្រព្រឹត្តនូវឧក្រិដ្ឋកម្ម

១-រដ្ឋនិមួយៗដែលជាសមាជិកគួរតែអនុម័តនូវនីតិបញ្ញត្តិ ហើយនឹងវិធានការផ្សេងទៀតដែលចាំបាច់ដើម្បី បង្កើតឡើងនូវបទល្មើសឧក្រិដ្ឋនៅពេលដែលជនទាំងឡាយណាដែលបានប្រព្រឹត្តដោយចេតនា ហើយនិងទទួលយកនូវ ផលប្រយោជន៍ផ្នែកសម្ភារៈ ឬក៏ផ្នែកហិរញ្ញវត្ថុដទៃទៀតដោយផ្ទាល់ ឬដោយប្រយោល ។

(a)-ការជួញដូរជនអន្តោប្រវេសន៍

(b)-ការប្រព្រឹត្តនោះក្នុងគោលបំណងរត់ពន្ធជនអន្តោប្រវេសន៍

(i)-ការបន្លំឯកសារធ្វើដំណើរ ឬអត្តសញ្ញាណ

(ii)-ការផ្គត់ផ្គង់ ការផ្តល់អោយនូវឯកសារ ឬក៏ជាឯកសារផ្ទាល់ខ្លួន

(c)-ចំពោះជនណាដែលមិនមានសញ្ជាតិ ឬក៏នៅតែបន្តការស្នាក់នៅជាអចិន្ត្រៃយ៍នៅក្នុងរដ្ឋដែល ពាក់ព័ន្ធដោយមិនអនុវត្តតាមនូវសេចក្តីតម្រូវការជាចាំបាច់ចំពោះច្បាប់ជាធរមាននៅក្នុងរដ្ឋនោះ តាមអត្ថន័យដែលបានពោល ខាងលើនៅក្នុងវាក្យខ័ណ្ឌ (b) នៃកថាខ័ណ្ឌនេះ ឬក៏វិធីខុសច្បាប់ ដទៃផ្សេងទៀត ។

២-រដ្ឋនីមួយៗដែលជាសមាជិកគួរតែអនុម័តនូវច្បាប់ ហើយនឹងវិធានការដទៃផ្សេងទៀតផងដែរដែលចាំបាច់ ដើម្បីបង្កើតឡើងនូវបទល្មើសផ្នែកឧក្រិដ្ឋ ។

(a)-ប្រធានបទចំពោះទស្សនៈជាមូលដ្ឋាននៃប្រព័ន្ធច្បាប់របស់វា មានគោលបំណងប្រព្រឹត្តនូវបទ ល្មើសដែលបានបង្កើតឡើង ដោយអនុលោមទៅតាមវាក្យខ័ណ្ឌ ១ នៃមាត្រានេះ ។

(b)-ការចូលរួមជុំគំនិតនៅក្នុងបទល្មើសណាមួយ ដែលបានបង្កើតឡើងដោយអនុលោមទៅតាម កថាខ័ណ្ឌ ១ (a), (b)(i) ឬក៏ (c) នៃមាត្រានេះ ហើយក៏ជាប្រធានបទចំពោះទស្សនៈជាមូលដ្ឋាន នៃប្រព័ន្ធច្បាប់របស់ខ្លួនការចូលរួមជុំគំនិតនៅក្នុងបទល្មើសណាមួយដែលបានបង្កើតឡើងដោយ អនុលោម ទៅតាមកថាខ័ណ្ឌ ១ (b) (ii) នៃមាត្រានេះ ។

(c)-ការចាត់តាំង ឬក៏ការរៀបចំនូវបណ្តាជនដទៃទៀត ដើម្បីប្រព្រឹត្តនូវបទល្មើសដែលបានបង្កើត ឡើងដោយអនុលោមទៅតាមកថាខ័ណ្ឌ ១ នៃមាត្រានេះ ។

៣-រដ្ឋនីមួយៗដែលជាសមាជិកគួរតែអនុម័តទៅតាមការតាក់តែងច្បាប់នេះ ហើយនិងវិធានការដទៃទៀត ដែលចាំបាច់ ដើម្បីបង្កើតឡើងតាមកាលៈទេសៈដ៏សុគស្មាញ ចំពោះបណ្តាបទល្មើសដែលបានបង្កើតឡើងដោយអនុ-លោមទៅតាមកថាខ័ណ្ឌ ២ (b) និង (c) នៃមាត្រានេះដោយយោងទៅតាមកាលៈទេសៈ ។

(a)-ការដែលធ្វើអោយមានគ្រោះថ្នាក់ ឬក៏ដូចជាធ្វើអោយមានគ្រោះថ្នាក់ដល់អាយុជីវិត ឬក៏ផ្នែកសុវត្ថិភាពដែលពាក់ព័ន្ធទៅនឹងផ្នែកជនអន្តោប្រវេសន៍ ។

(b)-ការដែលធ្វើអោយមានភាពអមនុស្សធម៌ ឬក៏ការមិនយកចិត្តទុកដាក់ផ្នែកសេវាសុខភាពព្រម-ទាំងមានការកេងប្រវ័ញ្ចចំពោះជនអន្តោប្រវេសន៍ ។

៤-នៅក្នុងពិធីសារនេះគ្មាន អ្វីដែលរាំងចំពោះរដ្ឋមួយដែលចាត់នូវរាល់វិធានការប្រឆាំងទៅនឹងបុគ្គលណាមួយដែលជាអ្នកប្រព្រឹត្តនូវបទល្មើសមួយដែលផ្ទុយទៅនឹងច្បាប់ប្រទេសរបស់ខ្លួន ។

## II-ការរត់ពន្ធផ្នែកជនអន្តោប្រវេសន៍នៅតាមដែនសមុទ្រ

### មាត្រា ៧

### កិច្ចសហប្រតិបត្តិការ

បណ្តារដ្ឋដែលជាសមាជិកទាំងអស់ នឹងធ្វើកិច្ចសហប្រតិបត្តិការដើម្បីបំពេញនូវវិសាលភាពដែលអាចធ្វើទៅបានក្នុងកិច្ចការពារ និងទប់ស្កាត់រាល់អំពើរត់ពន្ធជនអន្តោប្រវេសន៍ទៅតាមដែនសមុទ្រ ដោយយោងទៅតាមច្បាប់ដែនសមុទ្រអន្តរជាតិ ។

### មាត្រា ៨

### បណ្តាវិធានការប្រឆាំងនៅនឹងអំពើរត់ពន្ធ ជនអន្តោប្រវេសន៍នៅតាមដែនសមុទ្រ

១-រដ្ឋមួយដែលជាសមាជិកមានហេតុផលក្នុងពីបទសង្ស័យថានាវាមួយនោះកំពុងតែដោយទង់ជាតិរបស់ខ្លួន ឬក៏ អះអាងថាបានចុះឈ្មោះក្នុងបញ្ជីរបស់ខ្លួនដោយពុំបានបញ្ជាក់ពីសញ្ជាតិពិតប្រាកដ ឬប្រើទោះបីជាការប្រើប្រាស់ទង់ជាតិ បរទេស ឬក៏បដិសេធមិនបង្ហាញទង់ជាតិ និងសញ្ជាតិពិតប្រាកដដែលពាក់ព័ន្ធទៅនឹងរដ្ឋជាសមាជិកដែលបានសន្យា ក្នុងការរត់ពន្ធជនអន្តោប្រវេសន៍តាមដែនសមុទ្រ អាចសំណូមពរអោយមានការជួយពីបណ្តារដ្ឋដែលជាសមាជិកផ្សេង ក្នុងការទប់ស្កាត់នូវគោលបំណងនៃការប្រើប្រាស់នាវានោះ ។ បណ្តារដ្ឋដែលជាសមាជិកក៏បានសំណូមពរផងដែរនឹងផ្តល់នូវការជួយឧបត្ថម្ភទៅតាមលទ្ធភាព និងមធ្យោបាយរបស់គេ ។

២-រដ្ឋមួយជាសមាជិកដែលមានហេតុផលពិតប្រាកដ ពីបទសង្ស័យទៅលើនាវាមួយដែលបើកបរដោយសេរីអនុលោមតាមច្បាប់អន្តរជាតិ ហើយប្រើប្រាស់ទង់ជាតិ ឬក៏បង្ហាញនូវសញ្ញាដែលចុះទៅក្នុងបញ្ជីនៃរដ្ឋដែលជាសមាជិកមួយផ្សេងទៀតដែលបានជាប់ពាក់ព័ន្ធការរត់ពន្ធជនអន្តោប្រវេសន៍តាមដែនសមុទ្រ អាចនឹងបង្ហាញនូវទង់ជាតិរបស់រដ្ឋនោះ ស្នើសុំអោយមានការអះអាងនៃការចុះបញ្ជី ប្រសិនបើមានការអះអាងរួចហើយធ្វើការស្នើសុំទៅអាជ្ញាធរពីទង់ជាតិនៃរដ្ឋនោះដើម្បីចាត់នូវវិធានការដ៏ត្រឹមត្រូវជាមួយនឹងនាវានោះ ។ ទង់ជាតិនៃរដ្ឋនោះអាចនឹងអនុញ្ញាតទៅតាមសំណូមពរនៃរដ្ឋមួយទៀត ។

(a)-ការជិះនៅលើនាវា

(b)-ការស្រាវជ្រាវនៅលើនាវា ហើយនឹង

(c)-ប្រសិនបើរកឃើញភស្តុតាងថានាវានោះត្រូវបានជាប់ពាក់ព័ន្ធ ក្នុងការរត់ពន្ធជនអន្តោប្រវេសន៍តាមដែនសមុទ្រគួរតែចាត់នូវរាល់វិធានការអោយបានសមស្រប ចំពោះនាវាដែលដឹកជញ្ជូនមនុស្ស និងទំនិញនៅលើនាវា នោះតាមការអនុញ្ញាតដោយទង់ជាតិនៃរដ្ឋនីមួយៗ ។

៣-រដ្ឋមួយដែលជាសមាជិកបានអនុវត្តទៅតាមវិធានការណាមួយ ដោយអនុលោមទៅតាមកថាខ័ណ្ឌ ២ នៃមាត្រានេះ នឹងជូនដំណឹងជាមុននូវទង់ជាតិរដ្ឋដែលពាក់ព័ន្ធនឹងលទ្ធផលនៃវិធានការទាំងអស់នោះ ។

៤-រដ្ឋមួយដែលជាសមាជិកនឹងឆ្លើយតបជាបន្ទាន់ ចំពោះសំណូមពរពីបណ្ដារដ្ឋដែលជាសមាជិកមួយផ្សេងទៀតដើម្បីធ្វើការសំរេចចិត្តថាតើនាវានោះ ដែលបានធ្វើការអះអាងថាការចុះបញ្ជីឈ្មោះរបស់ខ្លួន ឬក៏ប្រើប្រាស់ទង់ជាតិរបស់ខ្លួនត្រូវបានផ្ដល់សិទ្ធិអោយធ្វើដូច្នេះ ហើយនិងស្នើសុំសិទ្ធិអនុវត្តដោយអនុលោមទៅតាមវគ្គ ២ នៃមាត្រានេះ ។

៥-ទង់ជាតិនៃរដ្ឋមួយអាចនឹងស្របទៅតាមមាត្រា ៧ នៃពិធីសារនេះ ប្រធានបទនៃការផ្ដល់សិទ្ធិអោយចំពោះលក្ខខ័ណ្ឌណាមួយដែលត្រូវបានយល់ព្រមដោយរដ្ឋ ហើយនិងរដ្ឋមួយទៀតដែលស្នើសុំដោយរាប់បញ្ចូលទាំងលក្ខខ័ណ្ឌដែលទាក់ទិនទៅនឹងការទទួលខុសត្រូវ ហើយនិងអនុវត្តវិធានការដ៏មានប្រសិទ្ធភាព ។ រដ្ឋមួយដែលជាសមាជិកនិង មិនត្រូវចាត់នូវរាល់វិធានការបន្ថែមដោយគ្មានការបង្ហាញនូវសេចក្ដីអនុញ្ញាតនៃទង់ជាតិនៃរដ្ឋនោះ លើកលែងតែបញ្ហាទាំងនោះមិនអាចជៀសរួច ដើម្បីជួយសង្គ្រោះដល់អាយុជីវិតរបស់មនុស្សដែលមានគ្រោះថ្នាក់ភ្លាមៗ ឬក៏បញ្ហានោះបណ្ដាលមកពីការ ពាក់ព័ន្ធទៅនឹងកិច្ចព្រមព្រៀងរវាងទ្វេភាគី ឬក៏ពហុភាគី ។

៦-រដ្ឋនីមួយៗដែលជាសមាជិកនឹងត្រូវកំណត់ទុកជាមុននូវអាជ្ញាធរដែលមានសមត្ថកិច្ច ឬក៏ក្នុងករណីចាំបាច់ណាមួយអ្នកមានសមត្ថកិច្ចទាំងនោះទទួល និងឆ្លើយតបទៅតាមការស្នើសុំជំនួយដោយធ្វើ ការបញ្ជាក់អះអាងនូវបញ្ជីឈ្មោះ ឬការផ្ដល់សិទ្ធិអោយនាវានោះបង្ហាញទង់ជាតិរបស់ខ្លួន ហើយចំពោះការផ្ដល់សិទ្ធិនោះត្រូវចាត់នូវវិធានការអោយបានសមស្រប ។ តាមការកំណត់ទុកជាមុននេះនឹងត្រូវបានជូនដំណឹងតាមរយៈអគ្គលេខាធិការរបស់បណ្ដារដ្ឋដែលជាសមាជិកទាំងអស់ក្នុងរយៈពេលកំណត់មួយខែម្ដង ។

៧-រដ្ឋមួយដែលជាសមាជិកមានមូលបទសមហេតុផលពីបទសង្ស័យថា នាវាមួយនោះត្រូវបានជាប់ពាក់ព័ន្ធក្នុងការរត់ពន្ធជនអន្តោប្រវេសន៍តាមដែនសមុទ្រហើយនិងមិនបានបញ្ជាក់នូវសញ្ជាតិ ឬក៏អាចនឹងប្រហាក់ប្រហែលទៅនឹងវានាដែលមិនបានបញ្ជាក់ពីសញ្ជាតិអាចនឹងជិះ ហើយនិងស្រាវជ្រាវនៅលើនាវានោះ ។

ប្រសិនបើមានការបញ្ជាក់នូវភស្ដុតាងពីបទសង្ស័យ ដែលត្រូវបានរកឃើញនោះ រដ្ឋមួយដែលជាសមាជិកនឹងត្រូវចាត់វិធានការអោយបានសមស្រប ដោយអនុលោមទៅតាមការពាក់ព័ន្ធទៅនឹងច្បាប់របស់ប្រទេសរបស់ខ្លួន និងច្បាប់អន្តរជាតិ ។

## មាត្រា ៩
## ផ្នែកនៃកិច្ចការពារ

១-រដ្ឋមួយដែលជាសមាជិក ដែលបានចាត់វិធានការប្រឆាំងនឹងនាវាមួយដោយអនុលោមទៅតាមមាត្រា ៨ នៃពិធីសារនេះនឹងត្រូវៈ

(a)-ធានានូវសុវត្ថិភាព ហើយនិងយកចិត្តទុកដាក់ថែទាំដោយក្ដីមនុស្សធម៌ដល់មនុស្សគ្រប់រូបដែលជិះនៅលើនាវានោះ ។

(b)-ទទួលខុសត្រូវនូវរាល់សេចក្ដីត្រូវការ ដោយមិនបង្កអោយមានគ្រោះថ្នាក់ផ្នែកសន្តិសុខដល់នាវា ឬក៏នាវាដឹកជញ្ជូនទំនិញខ្លួន ។

(c)-ទទួលខុសត្រូវនូវរាល់សេចក្ដីត្រូវការ មិនធ្វើអោយប៉ះពាល់ដល់ផ្នែកពាណិជ្ជកម្ម ឬក៏ចាប់អារម្មណ៍ទៅលើទង់ជាតិនៃរដ្ឋមួយដែលស្របច្បាប់ ឬក៏ចាប់អារម្មណ៍ទៅលើរដ្ឋដទៃផ្សេងទៀត ។

(d)-ធានានូវមធ្យោបាយដែលអាចធ្វើទៅបាននៃវិធានការណាមួយដែលនាវានោះធ្វើអោយឮសំលេងប៉ះពាល់ដល់បរិស្ថាន ។

២-ហេតុផលទាំងឡាយសំរាប់ចាត់វិធានការដោយអនុលោមទៅតាមមាត្រា ៨ ដែលបានបង្ហាញក្នុងពិធីសារនេះមិនត្រូវបានបង្កើតឡើង នាវានោះនឹងត្រូវបានសងថ្លៃជំងឺចិត្តចំពោះការបាត់បង់ ឬក៏ការខូចខាតណាមួយដែលអាច

នឹងត្រូវបានទទួលរ៉ាប់រង ហើយប្រគល់នូវការសងជំងឺចិត្តដល់នាវាណាដែលមិនបានប្រព្រឹត្តនូវអំពើណាមួយ ដោយបង្ហាញនូវហេតុផលត្រឹមត្រូវទៅតាមវិធានការដែលបានអនុវត្ត ។

៣-វិធានការណាមួយដែលបានរៀបចំឡើងបានអនុម័ត ឬក៏បានអនុវត្តដោយអនុលោមទៅតាមជំពូកនេះនឹងត្រូវទទួលខុសត្រូវនូវរាល់សេចក្តីត្រូវការណាដែលមិនបង្កនូវការជ្រៀតជ្រែក ឬក៏ប៉ះពាល់ដល់ :

(a)-សិទ្ធិ និងកាតព្វកិច្ចព្រមទាំងការអនុវត្តន៍នូវសិទ្ធិស្របច្បាប់នៃដែនសមុទ្ររបស់បណ្តារដ្ឋដោយអនុលោមទៅតាមច្បាប់ដែនសមុទ្រអន្តរជាតិ ឬក៏....

(b)-ការអនុញ្ញាតអោយប្រើប្រាស់ទង់ជាតិរបស់រដ្ឋ ដើម្បីអនុវត្តទៅតាមផ្លូវច្បាប់ ហើយនឹងត្រួត-ពិនិត្យទៅក្នុងផ្នែករដ្ឋបាល ផ្នែកបច្ចេកទេស និងបញ្ហាសង្គមដែលពាក់ព័ន្ធទៅនឹងនាវា ។

៤-ការចាត់នូវវិធានការណាមួយនៅតាមដែនសមុទ្រ ដោយអនុលោមទៅតាមជំពូកនេះនឹងត្រូវបានអនុវត្តចំពោះតែនាវាចំបាំង ឬក៏យន្តហោះចំបាំងរបស់យោធាតែប៉ុណ្ណោះ ឬក៏បណ្តានាវាដទៃផ្សេងទៀត និងយន្តហោះដទៃដែលបានធ្វើសញ្ញាច្បាស់លាស់ ព្រមទាំងអាចបញ្ជាក់ថាជាសេវាកម្មរបស់រដ្ឋាភិបាល ហើយនឹងបានអនុញ្ញាតអោយដោយមានប្រសិទ្ធិភាព ។

## III- កិច្ចការពារ កិច្ចសហប្រតិបត្តិការ ហើយនឹងបណ្តាវិធានការដទៃផ្សេងទៀត

### មាត្រា១០

### ពត៌មាន

១-គ្មានអ្វីដែលធ្វើអោយប៉ះពាល់ដល់មាត្រា ២៧ ហើយនិងមាត្រា ២៨ នៃអនុសញ្ញារបស់បណ្តារដ្ឋដែលជាសមាជិកនេះទេ ជាពិសេសបណ្តារដ្ឋទាំងនោះដែលមានទីតាំង ឬក៏ព្រំដែនរួមគ្នាដែលជាផ្លូវតំពន្ធជនអន្តោប្រវេសន៍ និងជាគោលបំណងនៃការសំរេចទិសដៅរបស់ពិធីសារនេះ ការផ្លាស់ប្តូរក្នុងចំណោមពួកគេស្របទៅតាមប្រព័ន្ធរដ្ឋបាល ហើយនិងច្បាប់ប្រទេសរៀង១ខ្លួនរបស់ពួកគេ ពត៌មានដែលពាក់ព័ន្ធទៅនឹងហេតុការណ៍ជាច្រើននោះមានដូចខាងក្រោមនេះ :

(a)-ចំណុចនៃការចុះនាវា ហើយនិងគោលដៅព្រមទាំងផ្លូវគ្រឿងដឹកជញ្ជូននិងមធ្យោបាយដឹកជញ្ជូនដែលត្រូវបានគេស្គាល់ថាឬក៏ត្រូវបានគេសង្ស័យថាបានប្រើប្រាស់ដោយក្រុមឧក្រិដ្ឋជនមួយដែលបានចាត់តាំងឡើងពាក់ព័ន្ធទៅក្នុងការប្រព្រឹត្តដូចដែលបានកំណត់ទុកក្នុងមាត្រា ៦ នៃពិធីសារនេះ ។

(b)-ការចាត់ចែងឡើងនូវរបៀបកម្មវិធី និងផ្នែកអត្តសញ្ញាណ ឬក៏បានរៀបចំឡើងនូវបណ្តាក្រុមឧក្រិដ្ឋជនដែលត្រូវបានគេស្គាល់ ឬក៏បានសង្ស័យថាបានជាប់ពាក់ព័ន្ធនៅក្នុងការប្រព្រឹត្តដូចដែលមានចែង នៅក្នុងមាត្រា ៦ នៃពិធីសារនេះ ។

(c)-បែបបទនៃឯកសារធ្វើដំណើរមានភាពត្រឹមត្រូវទៅតាមច្បាប់ពិតប្រាកដ ដែលបានចេញអោយប្រើប្រាស់ដោយរដ្ឋមួយដែលជាសមាជិក ឬក៏ការពាក់ព័ន្ធទៅនឹងការធ្វើដំណើរដោយគ្មានភាពត្រឹមត្រូវ និងការលួចបន្លំឯកសារអត្តសញ្ញាណ ឬក៏ឯកសារធ្វើ ដំណើរមិនត្រឹមត្រូវ ។

(d)-ការលាក់បំបាំងនូវរាល់របៀបវិធី ហើយនិងរាល់មធ្យោបាយ និងការដឹកជញ្ជូនមនុស្សការបំផ្លែងភេទមិនត្រឹមត្រូវតាមលក្ខណៈច្បាប់ ការរៀបចំឡើងវិញ ឬក៏ការរកបានមក ឬក៏ការធ្វើដំណើរដោយមិនត្រឹមត្រូវដទៃទៀតដែលបានប្រើប្រាស់ក្នុងការប្រព្រឹត្តដូចដែលមានចែងនៅក្នុងមាត្រា ៦ នៃពិធីសារនេះ ហើយនិង រាល់វិធីនៃការស៊ើបអង្កេតនូវបណ្តាហេតុការណ៍ទាំងឡាយ ។

(e)-បទពិសោធន៍នៃការតាក់តែងច្បាប់ ហើយនិងការអនុវត្តន៍នូវវិធានការដើម្បីការពារ ហើយនិងប្រយុទ្ធប្រឆាំងទៅនឹងការប្រព្រឹត្តដូចដែលមានចែងនៅក្នុងមាត្រា ៦ នៃពិធីសារនេះ ឬក៏....

(f)-ផ្នែកពត៌មានវិទ្យា ហើយនិងផ្នែកវិទ្យាសាស្ត្រមានអត្ថប្រយោជន៍ចំពោះការអនុវត្តន៍ច្បាប់ក៏ដូច ជាការបង្កើនឡើងនូវសមត្ថភាពរវាងគ្នាទៅវិញទៅមកដើម្បីស្រាវជ្រាវ ព្រមទាំងស៊ើបអង្កេត នូវការប្រព្រឹត្តដូចដែលមានចែងនៅក្នុងមាត្រា ៦ នៃពិធីសារនេះ ហើយនិងផ្តន្ទាទោសចំពោះ អំពើដែលពាក់ព័ន្ធទាំងនោះ ។

២-រដ្ឋមួយដែលជាសមាជិកដែលទទួលបានពត៌មាននឹងត្រូវអនុវត្តទៅតាម សេចក្តីស្នើសុំណាមួយដោយភាគី រដ្ឋមួយជាសមាជិកផ្សេងទៀតដែលបានបញ្ជូនពត៌មានតាមទីកន្លែងជាក់លាក់ស្តីពីការប្រើប្រាស់របស់ខ្លួន ។

## មាត្រា ១១
## បណ្តាវិធានការនៅតាមព្រំដែន

១-គ្មានអ្វីដែលធ្វើអោយប៉ះពាល់ដល់ការអនុវត្តន៍ជាលក្ខណៈអន្តរជាតិ ក្នុងទំនាក់ទំនងចំពោះចលនាសេរីភាព របស់ប្រជាជន បណ្តារដ្ឋដែលជាសមាជិកត្រូវតែពង្រឹងអោយអស់ពីលទ្ធភាព ដូចជាការត្រួតពិនិត្យនៅតាមព្រំដែន ដែលចាំបាច់ដើម្បីការពារ ហើយនិងស៊ើបអង្កេតនូវការរត់ពន្ធជនអន្តោប្រវេសន៍ ។

២-រដ្ឋនីមួយៗដែលជាសមាជិកនឹងត្រូវអនុម័តច្បាប់ ឬក៏បណ្តាវិធានការសមស្របដទៃទៀតដើម្បីការពារ អោយអស់លទ្ធភាពនូវរាល់មធ្យោបាយដឹកជញ្ជូន ដែលបានប្រព្រឹត្តដោយឈ្មួញពាណិជ្ជកម្ម ពីការប្រើប្រាស់ក្នុងការ ប្រព្រឹត្តនូវបទល្មើសដែលបានបង្កើតឡើងដោយអនុលោមទៅតាមមាត្រា ៦ កថាខ័ណ្ឌ ១ (a) នៃពិធីសារនេះ ។

៣-អ្វីដែលជាភាពសមរម្យហើយនឹងគ្មានការប៉ះពាល់ដល់ការអនុវត្តន៍នៃអនុសញ្ញាអន្តរជាតិ ក៏ដូចជាបណ្តា វិធានការទាំងឡាយដែលត្រូវបាប់បញ្ចូលនូវការបង្កើនឡើងកាតព្វកិច្ចនៃឈ្មួញពាណិជ្ជកម្ម រួមមាន ក្រុមហ៊ុនដឹកជញ្ជូន ណាមួយ ឬក៏ម្ចាស់ក្រុមហ៊ុន ឬក៏អ្នកប្រព្រឹត្តរាល់មធ្យោបាយដឹកជញ្ជូនណាមួយ ដើម្បីបញ្ជាក់អោយច្បាស់ថារាល់ អ្នកធ្វើដំណើរទាំងឡាយត្រូវតែតម្រូវអោយមានឯកសារធ្វើដំណើរផ្ទាល់ខ្លួនក្នុងការចូលទៅរដ្ឋដែលជាម្ចាស់ផ្ទះ ។

៤-រដ្ឋនីមួយៗដែលជាសមាជិកនឹងត្រូវចាត់នូវរាល់វិធានការជាចាំបាច់ ដោយអនុលោមតាមច្បាប់ក្នុងស្រុក របស់ខ្លួន និងផ្តល់ការដាក់ទណ្ឌកម្មក្នុងករណីដែលរំលោភទៅលើកាតព្វកិច្ចដូចដែលមានចែងក្នុងកថាខ័ណ្ឌ ៣ នៃមា-ត្រានេះ ។

៥-រដ្ឋនីមួយៗដែលជាសមាជិកនឹងត្រូវពិចារណា ក្នុងការចាត់នូវរាល់វិធានការដែលបានអនុញ្ញាតដោយយោង ទៅតាមច្បាប់ប្រទេសរបស់ខ្លួន ការបដិសេធនៃការចូល ឬក៏មោឃភាពនៃទិដ្ឋាការនូវរាល់ជនទាំងឡាយណាដែល បានជាប់ពាក់ព័ន្ធទៅនឹងការប្រព្រឹត្តបទល្មើសដែលបានបង្កើតឡើងដោយអនុលោមទៅតាមពិធីសារនេះ ។

៦-គ្មានអ្វីដែលធ្វើអោយប៉ះពាល់ដល់មាត្រា ២៧ នៃអនុសញ្ញានេះទេ បណ្តារដ្ឋដែលជាសមាជិកនឹងត្រូវ ពិចារណាពង្រឹងនូវកិច្ចសហប្រតិបត្តិការក្នុងចំណោមទីភ្នាក់ងារត្រួតពិនិត្យព្រំដែនរវាងគ្នាទៅវិញទៅមកក្នុងការបង្កើត ឡើង ហើយនិងការថែរក្សាដោយផ្ទាល់នូវប្រព័ន្ធទំនាក់ទំនង ។

## មាត្រា ១២
## សន្តិសុខ និងការគ្រប់គ្រងឯកសារ

រដ្ឋនីមួយៗដែលជាសមាជិក ត្រូវចាត់នូវរាល់វិធានការចាំបាច់ទៅតាមមធ្យោបាយដែលអាចយកជាការបាន។

(a)-ដើម្បីធានានូវរាល់ឯកសារធ្វើដំណើរ ឬក៏អត្តសញ្ញាណនានាដែលត្រូវបានចេញអោយប្រើប្រាស់ ដោយខ្លួនឯងក្នុងលក្ខណៈដែលគេមិនអាចប្រើប្រាស់ផ្លូវខុសដោយងាយៗនោះទេ ហើយមិនត្រូវបានគេធ្វើ អោយខុស ឬត្រូវបានកែប្រែខុសច្បាប បានចម្លង ឬក៏បានចេញផ្សាយ និង

(b)-ដើម្បីធានាសេចក្តីសុចរិត និងសន្តិសុខនៃឯកសារធ្វើដំរណើរ ឬអត្តសញ្ញាណបានចេញអោយ ប្រើប្រាស់ ឬតាងនាមភាគីរដ្ឋជាសមាជិក ហើយដើម្បីទប់ស្កាត់ការបង្កើតឡើងដែលខុសច្បាប់របស់ខ្លួននូវ រាល់ការចេញផ្សាយ និងការប្រើប្រាស់ ។

## មាត្រា ១៣
## ធម្មនុញ្ញភាព និងសុពលភាពនៃឯកសារ

តាមសំណូមពរនៃរដ្ឋជាសមាជិកមួយដោយអនុលោមទៅតាមច្បាប់នៅក្នុងប្រទេសរបស់ខ្លួន រដ្ឋជាសមាជិកមួយត្រូវត្រួតពិនិត្យមើលធម្មនុញ្ញភាព និងសុពលភាពនៃឯកសារធ្វើដំណើរ ឬអត្តសញ្ញាណដែលបានចេញអោយការប្រើប្រាស់ ឬមានន័យអោយស្របតាមពេលវេលា ត្រូវបានផ្សព្វផ្សាយក្នុងនាមរបស់ខ្លួន ហើយដែលបានមន្ទិលនូវការដែលបានប្រើប្រាស់ចំពោះបណ្តាគោលបំណងនៃការប្រព្រឹត្តបានចែងក្នុងមាត្រា ៦ នៃពិធីសារនេះ ។

## មាត្រា ១៤
## ការបណ្តុះបណ្តាល និងកិច្ចប្រតិបត្តិការផ្នែកបច្ចេកទេស

១-ភាគីរដ្ឋជាសមាជិកទាំងអស់ត្រូវផ្តល់ ឬពង្រឹងការហ្វឹកហ្វឺនជំនាញចំពោះការធ្វើអន្តោប្រវេសន៍ និងមន្ត្រីដែលពាក់ព័ន្ធដទៃទៀតក្នុងការទប់ស្កាត់បទល្មើសបានចែងក្នុងមាត្រា ៦ នៃពិធីសារនេះ ហើយក្នុងការព្យាបាលមនុស្សជាជនអន្តោប្រវេសន៍ដែលបានជាកម្មវត្ថុនៃការប្រព្រឹត្តនេះ ខណៈដែលគេគោរពសិទ្ធិរបស់ពួកគេដូចមានចែងក្នុងពិធីសារនេះ ។

២-រដ្ឋជាសមាជិកទាំងអស់ត្រូវប្រតិបត្តិការជាមួយគ្នា ហើយតាមរយៈអង្គការអន្តរជាតិដែលមានសមត្ថកិច្ចនានា អង្គការមិនមែនរដ្ឋាភិបាល អង្គការដែលពាក់ព័ន្ធដទៃទៀត និងអង្គការសង្គមស៊ីវិលផ្សេងទៀត ដើម្បីធានាការហ្វឹកហ្វឺនបុគ្គលិកគ្រប់គ្រាន់ក្នុងបូរណភាពទឹកដីរបស់ខ្លួន ដើម្បីទប់ស្កាត់ប្រយុទ្ធប្រឆាំង និងលុបបំបាត់ចោលការប្រព្រឹត្តដែលបានចែងក្នុងមាត្រា ៦ នៃពិធីសារនេះ ហើយដើម្បីការពារសិទ្ធជនអន្តោប្រវេសន៍ដែលបានប្រព្រឹត្តនូវទោសកម្មនេះ ។ ការហ្វឹកហ្វឺននេះត្រូវដាក់បញ្ចូល :

(a)-បង្កើនសន្តិសុខ និងគុណភាពឯកសារធ្វើដំណើរ

(b)-ទទួលស្គាល់ និងស៊ើបអង្កេតឯកសារធ្វើដំណើរ ឬក៏អត្តសញ្ញាណដែលក្លែងបន្លំ

(c)-ប្រមូលផ្តុំការស៊ើបអង្កេតបទល្មើសជាពិសេសទាក់ទិនទៅនឹងអត្តសញ្ញាណនៃក្រុមឧក្រិដ្ឋជនដែលគេស្គាល់ ឬបានសង្ស័យពីការចូលរួមក្នុងការប្រព្រឹត្តបានចែងក្នុងមាត្រា ៦ នៃពិធីសារនេះ ។ បណ្តាមធ្យោបាយដែលបានប្រើប្រាស់ដើម្បីដឹកជញ្ជូនជនអន្តោប្រវេសន៍ដែលត្រូវបានគេជួញដូរការប្រើប្រាស់នូវឯកសារធ្វើដំណើរ ឬអត្តសញ្ញាណនានា ចំពោះបណ្តាគោលបំណងនៃការប្រព្រឹត្តចែងក្នុងមាត្រា ៦ និងមធ្យោបាយនៃការលុបចោលបានប្រើប្រាស់ក្នុងការជួញដូរជនអន្តោប្រវេសន៍ ។

(d)-បង្កើននីតិវិធីដើម្បីស៊ើបអង្កេតជនដែលបានជួញដូរនូវចំណុចដែលមាន ឬគ្មានអនុសញ្ញានៃការចូលនិងចេញ ។

(e)-ការប្រព្រឹត្តក្នុងលក្ខណៈជាមនុស្សរបស់ជនអន្តោប្រវេសន៍ និងការពារសិទ្ធរបស់ពួកគេមានចែងក្នុងពិធីសារនេះ ។

៣-រដ្ឋជាសមាជិកទាំងអស់តាមរយៈជំនាញការដែលពាក់ព័ន្ធត្រូវពិចារណាផ្តល់ជំនួយបច្ចេកទេសដល់បណ្តារដ្ឋដែលជាញឹកញាប់ជាបណ្តាប្រទេសដើមកំណើត ឬអន្តរចំពោះបុគ្គលដែលជាកម្មវត្ថុនៃការប្រព្រឹត្តបានចែងក្នុងមាត្រា ៦ នៃពិធីសារនេះ។ រដ្ឋជាសមាជិកទាំងអស់ត្រូវយកចិត្តទុកដាក់ដើម្បីផ្តល់ប្រភពចាំបាច់ដូចជាយានយន្ត ប្រព័ន្ធកុំព្យូទ័រ និងអ្នកអានឯកសារ ដើម្បីប្រយុទ្ធប្រឆាំងការប្រព្រឹត្តចែងក្នុងមាត្រា ៦ ។

## មាត្រា ១៥
## បណ្តាវិធានការដទៃទៀត

១-បណ្តារដ្ឋជាសមាជិកត្រូវចាត់វិធានការធានាថាខ្លួនផ្តល់ ឬពង្រឹងកម្មវិធីពត៌មាន ដើម្បីបង្កើនការយល់ដឹងជាសាធារណៈនូវហេតុការណ៍ដែលការប្រព្រឹត្តចែងក្នុងមាត្រា ៦ នៃពិធីសារនេះ ជាអំពើល្មើសដែលបានប្រព្រឹត្តបទឧក្រិដ្ឋជាញឹកញាប់ដោយក្រុមឧក្រិដ្ឋជនដើម្បីកម្រៃ ហើយដែលខ្លួនលើកឡើងបញ្ហាគ្រោះថ្នាក់ធ្ងន់ធ្ងរចំពោះជនអន្តោ-

ប្រវេសន៍ដែលគេផ្តោតទៅលើ ។

២-អនុលោមតាមមាត្រាទី ៣១ នៃអនុសញ្ញានេះ រដ្ឋជាសមាជិកទាំងអស់ត្រូវសហប្រតិបត្តិការក្នុងវិស័យពត៌មានសាធារណៈ សម្រាប់គោលបំណងនៃការទប់ស្កាត់ជនអន្តោប្រវេសន៍ដែលមានសក្តានុភាពពីការទម្លាក់ជនរងគ្រោះទៅក្រុមឧក្រិដ្ឋជន ។

៣-រដ្ឋជាសមាជិកនីមួយៗត្រូវជម្រុញ និងពង្រឹងអោយបានសមស្របការអភិវឌ្ឍន៍កម្មវិធី និងកិច្ចសហប្រតិបត្តិការនៅកម្រិតជាតិ កម្រិតតំបន់ និងកម្រិតអន្តរជាតិ ការចាត់វិធានការ ភាពប្រាកដប្រជាផ្នែកសេដ្ឋកិច្ចសង្គមនៃការធ្វើអន្តោប្រវេសន៍ និងផ្តោតការយកចិត្តទុកដាក់ចំពោះតំបន់ដែលមានការអាក់អន់ចិត្តផ្នែកសេដ្ឋកិច្ចនិងសង្គមដើម្បីប្រយុទ្ធប្រឆាំងបណ្តាបុព្វហេតុនៃសេដ្ឋកិច្ចសង្គមជាឫសគល់នៃការជួញដូរជនអន្តោប្រវេសន៍ដូចជាភាពក្រីក្រ និងភាពអន់ថយ ។

## មាត្រា ១៦

## បណ្តាវិធានការការពារ និងការជំនួយ

១-ក្នុងការអនុវត្តពិធីសារនេះរដ្ឋជាសមាជិទាំងអស់ ស្របតាមកាតព្វកិច្ចរបស់ខ្លួនក្រោមច្បាប់អន្តរជាតិ ត្រូវចាត់វិធានការសបស្របការដាក់បញ្ចូលបញ្ញត្តិប្រសិនបើចាំបាច់ ដើម្បីថែរក្សាសិទ្ធបុគ្គលដែលជាអ្នកបានប្រព្រឹត្តល្មើសចែងក្នុងមាត្រា ៦ នៃពិធីសារនេះ ដោយអនុលោមតាមច្បាប់អន្តរជាតិដែលបានអនុវត្តជាពិសេស សិទ្ធិដើម្បីរស់រាន និងសិទ្ធមិនត្រូវបានគេធ្វើទារុណកម្ម ឬអំពើឃោរឃៅដទៃទៀត ការប្រព្រឹត្តដែលមិនមែនជាមនុស្ស ឬការដាក់ទណ្ឌកម្មបញ្ចុះឋានៈ ។

២-រដ្ឋជាសមាជិកនីមួយៗត្រូវចាត់វិធានការសមស្រប ដើម្បីទទួលយកការការពារសមរម្យក្នុងការជាជនអន្តោប្រវេសន៍ ប្រឆាំងអំពើហិង្សាដែលអាចត្រូវបានធ្វើអោយប៉ះពាល់ដល់ពួកគេ ទោះបីដោយបុគ្គល ឬដោយក្រុមដោយសារតែមូលហេតុនៃការប្រព្រឹត្តល្មើសដែលបានចែងក្នុងមាត្រា ៦ នៃពិធីសារនេះ ។

៣-រដ្ឋជាសមាជិកនីមួយៗត្រូវទទួលផ្តល់ជំនួយសមរម្យដល់ជនអន្តោប្រវេសន៍ ដែលជីវិត ឬសុវត្ថិភាពរបស់ពួកគេបានជួបគ្រោះថ្នាក់ដោយសារមូលហេតុនៃការប្រព្រឹត្តល្មើស ដែលបានចែងក្នុងមាត្រា ៦ នៃពិធីសារនេះ ។

៤-ក្នុងការអនុវត្តបញ្ញត្តិនានានៃមាត្រានេះ រដ្ឋជាសមាជិកទាំងអស់ត្រូវចាត់វិធានការចំពោះសេចក្តីត្រូវការពិសេសចំពោះស្ត្រី និងកុមារ ។

៥-ក្នុងករណីនៃការឃុំខ្លួនបុគ្គលម្នាក់ដែលជាអ្នកប្រព្រឹត្តល្មើស បានចែងក្នុងមាត្រា ៦ នៃពីធីសារនេះរដ្ឋជាសមាជិកនីមួយៗត្រូវអនុវត្តតាមកាតព្វកិច្ចរបស់ខ្លួនក្រោមអនុសញ្ញា វីយែនណា លើទំនាក់ទំនងដែលបានប្រឹក្សាដោយអនុវត្តដាក់បញ្ចូលនូវការរាយការទ៏ពីបុគ្គលដែលពាក់ព័ន្ធដោយគ្មានការពន្យារពេល អំពីបទបញ្ញត្តិដែលផ្តោតលើការបញ្ជាក់អះអាងទៅនឹងទំនាក់ទំនងជាមួយមន្ត្រីប្រឹក្សា ។

## មាត្រា ១៧

## កិច្ចព្រមព្រៀង និងការរៀបចំចាត់ចែង

រដ្ឋជាសមាជិកទាំងអស់ត្រូវពិចារណាអំពីការសន្និដ្ឋាននៃកិច្ចព្រមព្រៀងជាឧបតោភាគីឬតាមតំបន់ឬចាត់ចែងប្រតិបត្តិការ ឬការយល់ដឹងមានបំណងចំពោះ :

(a)ការបង្កើតបណ្តាវិធានការដ៏ត្រឹមត្រូវ និងមានប្រសិទ្ធភាពបំផុតដើម្បីទប់ស្កាត់ និងប្រយុទ្ធប្រឆាំងអំពើល្មើសបានចែងក្នុងមាត្រាទី៦ នៃពិធីសារនេះឬ

(b)ធ្វើអោយប្រសើរឡើងនូវបញ្ញត្តិទាំងឡាយនៃពីធីសារនេះរវាងពួកខ្លួន ។

## មាត្រា ១៨

## ការធ្វើមាតុភូមិនិវត្តន៍របស់ជនអន្តោប្រវេសន៍ដែលត្រូវបានគេជួញដូរ

១-រដ្ឋជាសមាជិកនីមួយៗព្រមព្រៀងដើម្បីសំរួល និងទទួលយកដោយគ្មានការពន្យាពេលហួសហេតុ ឬមិនសមហេតុផលនូវការធ្វើមាតុភូមិនិវត្តន៍របស់បុគ្គលដែលជាជនល្មើសចែងក្នុងមាត្រា ៦ នៃពិធីសារនេះ និងអ្នកជាជនជាតិខ្លួន ឬអ្នកដែលមានសិទ្ធិតាំងទីលំនៅអចិន្ត្រៃយ៍ក្នុងទឹកដីរបស់ខ្លួននៅពេលនៃការធ្វើមាតុភូមិនិវត្តន៍ ។

២-រដ្ឋជាសមាជិកនីមួយៗត្រូវពិចារណាអំពីលទ្ធភាពនៃការសំរបសំរួល និងការទទួលយកការបញ្ជូន ត្រឡប់នូវបុគ្គលដែលជាជនប្រព្រឹត្តល្មើសចែងក្នុងមាត្រា ៦ នៃពិធីសារនេះហើយដែលមានសិទ្ធិតាំងទីលំនៅអចិន្ត្រៃយ៍ក្នុងទឹកដីរបស់ខ្លួននៅពេលនៃការចូលក្នុងរដ្ឋដែលកំពុងទទួលអនុលោមតាមច្បាប់ស្រុករបស់ខ្លួន ។

៣-តាមសំណើរបស់រដ្ឋជាសមាជិកដែលកំពុងទទួល រដ្ឋជាសមាជិកដែលបានស្នើសុំត្រូវ (ដោយគ្មានការពន្យាពេលហួសហេតុ ឬមិនសមហេតុផល) មើលបញ្ជាក់ថាតើបុគ្គលដែលជាជនល្មើសចែងក្នុងមាត្រា ៦ នៃពិធីសារនេះជាជាតិខ្លួន ឬមានសិទ្ធិតាំងលំនៅដ្ឋានអចិន្ត្រៃយ៍ក្នុងទឹកដីរបស់ខ្លួន ។

៤-ដើម្បីសំរួលដល់ការធ្វើមាតុភូមិនិវត្តន៍នៃជនដែលបានប្រព្រឹត្តល្មើសបានចែងក្នុងមាត្រា ៦ នៃពិធីសារនេះ ហើយដោយគ្មានឯកសារត្រឹមត្រូវ រដ្ឋជាសមាជិកដែលជននោះជាជនជាតិ ឬដែលគាត់មានសិទ្ធិតាំងទីលំនៅអចិន្ត្រៃយ៍ ត្រូវយល់ព្រមដើម្បីផ្សព្វផ្សាយ (តាមសំណើរបស់ភាគីរដ្ឋដែលកំពុងទទួល) ឯកសារធ្វើដំណើរទាំងនេះ ឬការអនុញ្ញាតដទៃទៀតដែលចាំបាច់ ដើម្បីអាចអោយជននេះធ្វើដំណើរទៅហើយចូលក្នុងទឹកដីរបស់ខ្លួនម្តងទៀត ។

៥-រដ្ឋជាសមាជិកនីមួយៗបានពាក់ព័ន្ធជាមួយការបញ្ជូនត្រឡប់នូវជនល្មើស ដូចបានចែងក្នុងមាត្រា ៦ នៃពិធីសារនេះត្រូវចាត់គ្រប់វិធានការសមរម្យ ដើម្បីធានាមកនូវការបញ្ជូនត្រឡប់ក្នុងលក្ខណៈតាមលំដាប់លំដោយហើយដោយផ្តោតយ៉ាងសម្បើមចំពោះសុវត្ថិភាព និងសេចក្តីថ្លៃថ្នូររបស់ជននោះ ។

៦-រដ្ឋជាសមាជិកទាំងអស់ត្រូវសហប្រតិបត្តិការជាមួយអង្គការអន្តរជាតិដែលពាក់ព័ន្ធក្នុងការអនុវត្តន៍មាត្រានេះ ។

៧-មាត្រានេះមិនត្រូវលំអៀងទៅសិទ្ធិណាមួយ បានផ្តល់ទៅបុគ្គលទាំងឡាយណាដែលបានប្រព្រឹត្តល្មើសចែងក្នុងមាត្រាទី ៦ នៃពិធីសារនេះដោយច្បាប់ក្នុងស្រុករបស់រដ្ឋជាសមាជិកដែលកំពុងទទួល ។

៨-មាត្រានេះនឹងគ្មានធ្វើអោយប៉ះពាល់ដល់រាល់កាតព្វកិច្ចដែលបានដាក់បញ្ចូលនៅក្រោមសន្ធិសញ្ញាណាមួយដទៃទៀតដែលបានអនុវត្តជាទ្វេភាគី ឬពហុភាគី ឬក៏ការអនុវត្តន៍កិច្ចព្រមព្រៀងណា មួយដ៏ទៃទៀតផ្សេងៗទៀតនូវផ្នែកប្រតិបត្តិការ ឬក៏ការចាត់ចែងនោះត្រូវគ្រប់គ្រងទាំងមូល ឬក៏ជាផ្នែក ដូចបានកំពុងទុកនៅក្នុងមាត្រា ៦ នៃពិធីសារនេះ ។

## IV-ចសានប្បញ្ញត្តិ

### មាត្រា ១៩

### ការជួយសង្គ្រោះ

១-នៅក្នុងពិធីសារនិងគ្មានអ្វីធ្វើអោយប៉ះពាល់ដល់សិទ្ធិកាតព្វកិច្ច ហើយនឹងការទទួលខុសត្រូវនានានៃបណ្តារដ្ឋនឹងរាល់បុគ្គលក្រោមច្បាប់អន្តរជាតិដោយរាប់បញ្ចូលទាំងច្បាប់មនុស្សធម៌អន្តរជាតិ ច្បាប់សិទ្ធិមនុស្សអន្តរជាតិជាពិសេសដែលអាចអនុវត្តបាននូវអនុសញ្ញាក្នុងឆ្នាំ ១៩៥១ ហើយនឹងឆ្នាំ ១៩៦៧ នៃពិធីសារដែលទាក់ទិនទៅនឹងស្ថានភាពនៃជនភៀសខ្លួនទាំងឡាយ ព្រមទាំងគោលការណ៍ដែលមិនពាក់ព័ន្ធដូចបានចែងនៅក្នុងនោះ ។

២-រាល់បណ្តាវិធានការណ៍ដែលបានកំណត់ទុកនៅក្នុងពិធីសារនេះនឹងត្រូវបានបលស្រាយ ហើយនឹងអនុវត្ត ទៅតាមវិធីដែលមិនមានការប្រកាន់ពូជសាសន៍ ចំពោះជនទាំងឡាយណានៅលើមូលបទដែលជនទាំងនោះបានប្រព្រឹត្ត នូវទោសកម្មដូចបានកំណត់ទុកក្នុងមាត្រា ៦ នៃពិធីសារនេះ ។ ការបកស្រាយហើយនឹងការអនុវត្តន៍នូវរាល់បណ្តា វិធានការណ៍ទាំងនោះនឹងត្រូវបានអនុលោមទៅតាមគោលការណ៍ដែលបានទទួលស្គាល់ជាលក្ខណៈអន្តរជាតិនៃការមិន ប្រកាន់ពូជសាសន៍ ។

## មាត្រា ២០

## ការដោះស្រាយជម្លោះ

១-បណ្តារដ្ឋដែលជាសមាជិកនឹងត្រូវខិតខំខ្នះខ្នែងដើម្បីដោះស្រាយនូវរាល់ជម្លោះដែលទាក់ទិនការបកស្រាយ ឬក៏ការអនុវត្តន៍នៃពិធីសារនេះតាមរយៈកិច្ចចរចា ។

២-រាល់ជម្លោះណាមួយចាប់ពីពីរឡើងទៅ ឬក៏ច្រើនដែលថែមទៀត រវាងបណ្តារដ្ឋដែលជាសមាជិកដែល ទាក់ទិនទៅនឹងការបកស្រាយ ឬក៏ការអនុវត្តន៍នៃពិធីសារនេះបើមិនអាចដោះស្រាយបានតាមរយៈកិច្ចចរចាទៅតាម ហេតុផលនៃកាលវេលា នៃការស្នើសុំរបស់រដ្ឋមួយក្នុងចំណោមរដ្ឋដែលជាសមាជិកជាច្រើនទៀត ដើម្បីដាក់ដូចពិនិត្យ ទៅគណៈវិនិច្ឆ័យប្រសិនបើរយៈពេល ៦ ខែបន្ទាប់ពីការបរិច្ឆេទនៃការស្នើសុំចំពោះគណៈវិនិច្ឆ័យរាល់បណ្តារដ្ឋដែលជា សមាជិកនៅតែមិនអាចព្រមព្រៀងគ្នានៅលើការចាត់ចែងរបស់គណៈវិនិច្ឆ័យនោះរដ្ឋមួយដែលជាសមាជិកក្នុង ចំណោ មបណ្តារដ្ឋទាំងនោះអាចនឹងបញ្ជូននូវរាល់ជម្លោះនោះជូនទៅដល់តុលាការយុត្តិធម៌អន្តរជាតិទៅតាមសេចក្តីស្នើសុំដោ យអនុលោមទៅតាមលក្ខន្តិកៈរបស់តុលាការ ។

៣-រដ្ឋនីមួយៗដែលជាសមាជិកអាចចុះហត្ថលេខាទៅតាមកាលវេលាសច្ចានុម័ត ការទទួលស្គាល់ ឬក៏អនុម័ត ឬក៏ការយល់ព្រមចំពោះពិធីសារនេះដោយប្រកាសថាច្បាប់នេះមិនទាន់បានធ្វើការពិចារណានិងកែប្រែអោយបានល្អិត ល្អន់ទៅតាមកថាខ័ណ្ឌ ២ នៃមាត្រានេះ ។ បណ្តារដ្ឋដែលជាសមាជិកនឹងមិនអាចកែប្រែទៅតាមកថាខ័ណ្ឌ ២ នៃ មាត្រានេះដោយគោរពទៅតាមរដ្ឋណាមួយដែលជាសមាជិកដែលបានបំរុងទុក ។

៤-រដ្ឋណាមួយដែលជាសមាជិក ដែលបានធ្វើការបំរុងទុកដោយអនុលោមទៅតាមកថាខ័ណ្ឌ ៣ មាត្រានេះ អាចនឹងដកចេញនូវការបំរុងទុកទៅតាមកាលវេលាណាមួយដោយជូនដំណឹងជាមុនដល់អគ្គលេខាធិការអង្គការសហប្រ ជាជាតិ ។

## មាត្រា ២១

## ការចុះហត្ថលេខា សច្ចានុម័ត ការទទួលស្គាល់ ការអនុម័ត ហើយនិងការយល់ព្រម

១-ពិធីសារនេះនឹងត្រូវបានបើកចំហរដល់បណ្តារដ្ឋទាំងអស់សំរាប់ចុះហត្ថលេខាចាប់ពីថ្ងៃទី ១២ ដល់ ខែ ១២ ឆ្នាំ ២០០០ នៅក្នុងរដ្ឋ Palermo ប្រទេសអ៊ីតាលី ហើយបន្ទាប់ពីនោះមកនៅឯទីបញ្ជាការអង្គការសហប្រជាជាតិ នៅក្នុងទីក្រុង ញូយក រហូតដល់ថ្ងៃទី ១២ ខែ ធ្នូ ឆ្នាំ ២០០០ ។

២-ពីធិសារនេះនឹងត្រូវបើកចំហរផងដែរ សំរាប់ចុះហត្ថលេខាទៅតាមអង្គការសមាហរណកម្មសេដ្ឋកិច្ចនៅ តាមតំបន់ដែលបានផ្តល់អោយយ៉ាងហោចណាស់ក៏មានសមាជិករដ្ឋម្នាក់នៅតាមអង្គការចាត់តាំងដែលបានចុះហត្ថលេ ខានូវពិធីសារនេះដោយអនុលោមទៅតាមកថាខ័ណ្ឌ ១ នៃមាត្រានេះ ។

៣-ពិធីសារនេះគឺជាប្រធានបទចំពោះការស្នើសច្ចានុម័តការទទួលស្គាល់ ឬក៏អនុម័ត ការធ្វើសច្ចានុម័តនូវ រាល់ឯកសារច្បាប់ ការទទួលស្គាល់ ឬក៏ការអនុម័តនឹងត្រូវបានដាក់ជូនដល់អគ្គលេខាធិការអង្គការសហប្រជាជាតិ

អង្គការសមាហរណកម្មសេដ្ឋកិច្ចតាមតំបន់ អាចនឹងដាក់នូវការធ្វើសច្ចានុម័តនៃឯកសារច្បាប់របស់ខ្លួន ។ នៅក្នុងការស្នើសច្ចានុម័តនូវឯកសារច្បាប់ ការទទួលស្គាល់ ឬក៏ការអនុម័តទៅតាមអង្គការចាត់តាំងដែលនឹងប្រកាសនូវវិសាល-ភាពនៃសមត្ថភាពរបស់ខ្លួនចំពោះហេតុការណ៍ទាំងឡាយដែលបានគ្រប់គ្រងដោយពិធីសារនេះ ។ ដូចជាការចាត់តាំងនឹងត្រូវបានជំរាបជូនផងដែរដល់អ្នកទទួលបញ្ញើណាមួយដែលពាក់ព័ន្ធទៅនឹងការកែសំរួលនៅក្នុងវិសាលភាពនៃសមត្ថភាពរបស់ខ្លួន ។

៤-ពិធីសារនេះនឹងត្រូវបើកចំហរសំរាប់ការយល់ព្រមទៅតាមរដ្ឋណាមួយ ឬក៏អង្គការសមាហរណកម្មសេដ្ឋកិច្ចតាមតំបន់ដែលយ៉ាងហោចណាស់ក៏ត្រូវរដ្ឋមួយដែលជាសមាជិកចំពោះពិធីសារនេះ ។ ការគ្រប់គ្រងនូវរាល់ឯកសារច្បាប់នឹងត្រូវបានដាក់ជូនអគ្គលេខាធិការអង្គការសហប្រជាជាតិ ។ ការគ្រប់គ្រងរបស់ខ្លួនទៅតាមកាលវេលាអង្គការសមាហរណកម្មសេដ្ឋកិច្ចតាមតំបន់នឹងត្រូវប្រកាសនូវវិសាលភាពនៃសមត្ថភាពរបស់ខ្លួនចំពោះហេតុការណ៍ទាំងឡាយដែលបានចែងនៅក្នុងពិធីសារនេះ ។ ដូចជាការចាត់តាំងនឹងត្រូវបានជំរាបជូនផងដែរដល់អ្នកទទួលបញ្ញើណាមួយដែលពាក់ព័ន្ធទៅនឹងការកែសំរួលនៅក្នុងវិសាលភាពនៃសមត្ថភាពរបស់ខ្លួន ។

## មាត្រា ២២
## ការចូលជាធរមាន

១-ពិធីសារនេះនឹងចូលជាធរមានក្នុងរយៈពេល ៩០ ថ្ងៃ បន្ទាប់ពីដាក់អោយធ្វើសច្ចប័ន នៃការដាក់នូវឯកសារច្បាប់លើកទី ៤០ នៃការធ្វើសច្ចានុម័ត ទទួលស្គាល់ ការអនុម័ត ឬការយល់ព្រមដែលមិនទាន់ចូលជាធរមានមុនពេលការចូលជាធរមាននៃអនុសញ្ញានេះ ។ ចំពោះគោលបំណងនៃកថាខ័ណ្ឌនេះ រាល់ឯកសារច្បាប់ណាមួយដែលបានដាក់ដោយអង្គការសមាហរណកម្មសេដ្ឋកិច្ចតំបន់ នឹងមិនត្រូវបានរាប់បញ្ចូលបន្ថែមទៀតទេ ចំពោះការដាក់បញ្ចូលទាំងនោះដោយបណ្តារដ្ឋជាសមាជិកទៅតាមអង្គការចាត់តាំង ។

២-ចំពោះបណ្តារដ្ឋនីមួយៗ ឬអង្គការសមាហរណកម្មសេដ្ឋកិច្ចតំបន់មួយ ធ្វើសច្ចាប័ន ធ្វើការទទួលស្គាល់ ធ្វើការអនុម័ត ឬក៏ធ្វើការយល់ព្រមចំពោះពិធីសារនេះ បន្ទាប់ពីដាក់នូវឯកសារច្បាប់លើកទី ៤០ ទៅតាមសកម្មភាពនៃពិធីសារនេះ នឹងចូលជាធរមានរយៈពេល ៣០ ថ្ងៃ បន្ទាប់ពីកាលបរិច្ឆេទនៃការដាក់តំកល់ទុកដោយរដ្ឋមួយ ឬក៏អង្គការចាត់តាំងដែលពាក់ព័ន្ធទៅនឹងឯកសារច្បាប់ ឬក៏កាលបរិច្ឆេទនៃពិធីសារនេះចូលជាធរមានដោយអនុលោមទៅតាមកថាខ័ណ្ឌ ១ នៃមាត្រានេះ ឬមួយណាក៏បានជាបន្តបន្ទាប់មក ។

## មាត្រា ២៣
## ការធ្វើវិសោធនកម្ម

១-បន្ទាប់ពីផុតកំណត់រយៈពេល ៥ ឆ្នាំ នូវការចូលជាធរមាននៃពិធីសារនេះ រដ្ឋមួយដែលជាសមាជិកចំពោះពិធីសារនេះអាចដាក់ស្នើនូវការកែប្រែ និងសំណុំឯកសារច្បាប់ជូនដល់អគ្គលេខាធិការអង្គការសហប្រជាជាតិដែលភ្លាមៗនេះនឹងទំនាក់ទំនងស្នើសុំធ្វើវិសោធនកម្មទៅបណ្តារដ្ឋដែលជាសមាជិក ព្រមទាំងជូនដល់សន្និបាតនៃភាគីទាំងអស់ចំពោះអនុសញ្ញាក្នុងគោលបំណងធ្វើការពិចារណា និងការសម្រេចចិត្តស្តីពីសំណើរនោះ ។ បណ្តារដ្ឋជាសមាជិកនៃពិធីសារនេះនឹងជួបប្រជុំគ្នានៅឯសន្និសីទនៃបណ្តាភាគីទាំងអស់ និងបង្កើននូវកិច្ចខិតខំប្រឹងប្រែងគ្រប់បែបដើម្បីសម្រេចនូវការព្រមព្រៀងនៃការធ្វើវិសោធនកម្មនីមួយៗ។ប្រសិនបើរាល់កិច្ចខិតខំប្រឹងប្រែងក្នុងការព្រមព្រៀងមតិគ្នានោះមិនបានសម្រេច ហើយនិងមិនទាន់មានកិច្ចព្រមព្រៀងណាមួយដែលត្រូវបានឈានមកដល់ ការកែប្រែនឹងងាកទៅរកមធ្យោបាយចុងក្រោយបំផុតគឺតម្រូវអោយមានការបោះឆ្នោតក្នុងសម្លេងឆ្នោត ២/៣ នៃបណ្តារដ្ឋជាសមាជិកក្នុងពិធីសារការប្រគល់អោយនិងការបោះឆ្នោតទៅក្នុងការធ្វើសន្និសីទនៃគ្រប់ភាគីទាំងអស់ ។

២-អង្គការសមាហរណកម្មសេដ្ឋកិច្ចក្នុងតំបន់ ក្នុងបញ្ហាដែលស្ថិតនៅលើសមត្ថកិច្ចរបស់គេ នឹងត្រូវអនុវត្តនូវសិទ្ធិក្នុងការបោះឆ្នោតទៅតាមមាត្រានេះ ដោយចំនួននៃការបោះឆ្នោតស្មើទៅនឹងចំនួនសមាជិកនៃរដ្ឋរបស់គេដែលជា

គូភាគីនៃពិធីសារនេះ ។ រាល់ការចាត់តាំងនឹងមិនត្រូវអនុវត្តទៅតាមសិទ្ធិរបស់គេចំពោះការបោះឆ្នោត ប្រសិនបើរដ្ឋជាសមាជិករបស់គេអនុវត្តផុយពីសិទ្ធិដែលអនុញ្ញាត ។

៣-ការធ្វើវិសោធនកម្មមួយត្រូវបានអនុម័តយោងទៅតាមកថាខ័ណ្ឌ ១ នៃមាត្រានេះ ជាប្រធានបទដើម្បីធ្វើសច្ចានុម័ត ការយល់ព្រមទទួល ឬក៏អនុម័តដោយបណ្តារដ្ឋជាសមាជិក ។

៤-ការធ្វើវិសោធនកម្មមួយត្រូវបានអនុម័តយោងទៅតាមកថាខ័ណ្ឌ ១ នៃមាត្រានេះ នឹងត្រូវចូលជាធរមានទៅតាមការគោរពដល់រដ្ឋជាសមាជិកមួយរយៈពេល ៩០ ថ្ងៃបន្ទាប់ពីកាលបរិច្ឆេទនៃការដាក់ជូនទៅដល់អគ្គលេខាធិការអង្គការសហប្រជាជាតិនៃការសុំធ្វើសច្ចាប័ននូវឯកសារច្បាប់ ការទទួលស្គាល់ ឬក៏អនុម័តចំពោះការកែប្រែ ។

៥-នៅពេលដែលការស្នើសុំធ្វើវិសោធនកម្មចូលជាធរមាន ដែលច្បាប់នេះកំពុងតែនឹងកែប្រែដោយបណ្តារដ្ឋជាសមាជិកបានបង្ហាញនូវការយល់ព្រមរបស់គេដើម្បីធ្វើការកែប្រែ ។ បណ្តារដ្ឋជាសមាជិកដទៃទៀតនឹងត្រូវតែកែប្រែទៅតាមបទបញ្ញត្តិពិធីសារនេះ ហើយរាល់ការធ្វើវិសោធនកម្មជាលើដំបូងណាមួយដែលពួកគេបានធ្វើសច្ចាប័ន បានទទួលស្គាល់ ឬបានអនុម័ត ។

## មាត្រា ២៤
## ការប្រកាសទុកជាមោឃៈ

១-រដ្ឋមួយដែលជាសមាជិកអាចប្រកាសដកខ្លួនចេញពីពិធីសារនេះ ដោយជម្រាបអោយដឹងមុនជាលាយលក្ខណ៍អក្សរជូនដល់អគ្គលេខាធិការអង្គការសហប្រជាជាតិ ។ ការប្រកាសទុកជាមោឃៈនឹងត្រូវទទួលយកដោយមានប្រសិទ្ធិភាពរយៈពេល ១ ឆ្នាំ បន្ទាប់កាលបរិច្ឆេទនៃការទទួលនូវការជូនដំណឹងដោយអគ្គលេខា ។

២-អង្គការសមាហរណកម្មសេដ្ឋកិច្ចតំបន់ នឹងត្រូវបញ្ឈប់នូវជាភាគីមួយចំពោះពិធីសារនេះនៅពេលដែលរដ្ឋជាសមាជិករបស់ខ្លួនបានធ្វើការប្រកាសដកខ្លួន ។

## មាត្រា ២៥
## អ្នកចុះបញ្ជី និងភាសា

១-អគ្គលេខាធិការអង្គការសហប្រជាជាតិ ត្រូវបានរៀបចំជាមុន នូវការចុះបញ្ជីនៃពិធីសារនេះ ។

២-ច្បាប់ដើមនៃពិធីសារនេះ នៅក្នុងនោះមានភាសា អារ៉ាប់ ចិន អង់គ្លេស បារាំង អេស្បាញ និងរុស្ស៊ី ។ អត្ថបទទាំងអស់ពិតជាត្រឹមត្រូវទៅតាមច្បាប់ពិតប្រាកដដែលនឹងបានដាក់ចេញដោយអគ្គលេខាធិការអង្គការសហប្រជាជាតិ ។ ដើម្បីជាសាក្សីក្នុងច្បាប់ទាំងនេះរាល់តំណាងទាំងអស់ត្រូវចុះហត្ថលេខានៅខាងក្រោមទៅតាមការអនុញ្ញាតដ៏ត្រឹមត្រូវចំពោះច្បាប់នោះដោយតំណាងរដ្ឋាភិបាលរៀងៗខ្លួនរបស់គេបានចុះហត្ថលេខាលើពិធីសារនេះ ។

# PROTOCOL AGAINST THE SMUGGLING OF MIGRANTS BY LAND, SEA AND AIR, SUPPLEMENTING THE UNITED NATIONS CONVENTION AGAINST TRANSNATIONAL ORGANIZED CRIME

Advance copy of the authentic text. The copy certified by the Secretary-General will be issued at a later time.

UNITED NATIONS

2000

# PROTOCOL AGAINST THE SMUGGLING OF MIGRANTS BY LAND, SEA AND AIR, SUPPLEMENTING THE UNITED NATIONS CONVENTION AGAINST TRANSNATIONAL ORGANIZED CRIME

## Preamble

*The States Parties to this Protocol,*

*Declaring* that effective action to prevent and combat the smuggling of migrants by land, sea and air requires a comprehensive international approach, including cooperation, the exchange of information and other appropriate measures, including socio-economic measures, at the national, regional and international levels,

*Recalling* General Assembly resolution 54/212 of 22 December 1999, in which the Assembly urged Member States and the United Nations system to strengthen international cooperation in the area of international migration and development in order to address the root causes of migration, especially those related to poverty, and to maximize the benefits of international migration to those concerned, and encouraged, where relevant, interregional, regional and subregional mechanisms to continue to address the question of migration and development,

*Convinced* of the need to provide migrants with humane treatment and full protection of their rights,

*Taking into account* the fact that, despite work undertaken in other international forums, there is no universal instrument that addresses all aspects of smuggling of migrants and other related issues,

*Concerned* at the significant increase in the activities of organized criminal groups in smuggling of migrants and other related criminal activities set forth in this Protocol, which bring great harm to the States concerned,

*Also concerned* that the smuggling of migrants can endanger the lives or security of the migrants involved,

*Recalling* General Assembly resolution 53/111 of 9 December 1998, in which the Assembly decided to establish an open-ended intergovernmental ad hoc committee for the purpose of elaborating a comprehensive international convention against transnational organized crime and of discussing the elaboration of, inter alia, an international instrument addressing illegal trafficking in and transporting of migrants, including by sea,

*Convinced* that supplementing the United Nations Convention against Transnational Organized Crime with an international instrument

against the smuggling of migrants by land, sea and air will be useful in preventing and combating that crime,

*Have agreed as follows*:

## I. General provisions

### *Article 1*

### *Relation with the United Nations Convention against Transnational Organized Crime*

1. This Protocol supplements the United Nations Convention against Transnational Organized Crime. It shall be interpreted together with the Convention.

2. The provisions of the Convention shall apply, mutatis mutandis, to this Protocol unless otherwise provided herein.

3. The offences established in accordance with article 6 of this Protocol shall be regarded as offences established in accordance with the Convention.

### *Article 2*

### *Statement of purpose*

The purpose of this Protocol is to prevent and combat the smuggling of migrants, as well as to promote cooperation among States Parties to that end, while protecting the rights of smuggled migrants.

### *Article 3*

### *Use of terms*

For the purposes of this Protocol:

(a) "Smuggling of migrants" shall mean the procurement, in order to obtain, directly or indirectly, a financial or other material benefit, of the illegal entry of a person into a State Party of which the person is not a national or a permanent resident;

(b) "Illegal entry" shall mean crossing borders without complying with the necessary requirements for legal entry into the receiving State;

(c) "Fraudulent travel or identity document" shall mean any travel or identity document:

(i) That has been falsely made or altered in some material way by anyone other than a person or agency lawfully authorized to make or issue the travel or identity document on behalf of a State; or

(ii) That has been improperly issued or obtained through misrepresentation, corruption or duress or in any other unlawful manner; or

(iii) That is being used by a person other than the rightful holder;

(d) "Vessel" shall mean any type of water craft, including non-displacement craft and seaplanes, used or capable of being used as a means of transportation on water, except a warship, naval auxiliary or other vessel owned or operated by a Government and used, for the time being, only on government non-commercial service.

### *Article 4*

### *Scope of application*

This Protocol shall apply, except as otherwise stated herein, to the prevention, investigation and prosecution of the offences established in accordance with article 6 of this Protocol, where the offences are transnational in nature and involve an organized criminal group, as well as to the protection of the rights of persons who have been the object of such offences.

### *Article 5*

### *Criminal liability of migrants*

Migrants shall not become liable to criminal prosecution under this Protocol for the fact of having been the object of conduct set forth in article 6 of this Protocol.

### *Article 6*

### *Criminalization*

1. Each State Party shall adopt such legislative and other measures as may be necessary to establish as criminal offences, when committed intentionally and in order to obtain, directly or indirectly, a financial or other material benefit:

(a) The smuggling of migrants;

(b) When committed for the purpose of enabling the smuggling of migrants:

(i) Producing a fraudulent travel or identity document;

(ii) Procuring, providing or possessing such a document;

(c) Enabling a person who is not a national or a permanent resident to remain in the State concerned without complying with the

necessary requirements for legally remaining in the State by the means mentioned in subparagraph (b) of this paragraph or any other illegal means.

2. Each State Party shall also adopt such legislative and other measures as may be necessary to establish as criminal offences:

(a) Subject to the basic concepts of its legal system, attempting to commit an offence established in accordance with paragraph 1 of this article;

(b) Participating as an accomplice in an offence established in accordance with paragraph 1 (a), (b) (i) or (c) of this article and, subject to the basic concepts of its legal system, participating as an accomplice in an offence established in accordance with paragraph 1 (b) (ii) of this article;

(c) Organizing or directing other persons to commit an offence established in accordance with paragraph 1 of this article.

3. Each State Party shall adopt such legislative and other measures as may be necessary to establish as aggravating circumstances to the offences established in accordance with paragraph 1 (a), (b) (i) and (c) of this article and, subject to the basic concepts of its legal system, to the offences established in accordance with paragraph 2 (b) and (c) of this article, circumstances:

៣-លោក **ប៉ែន ស៊ីថា** អគ្គនាយករងកំពង់ផែស្វយ័តក្រុងព្រះសីហនុ ថវិកាចំនួន ១០.៥០០ ដុល្លារ

៤-សមាគម Toyama Rotary Club ថវិកាចំនួន ២១.០០០ ដុល្លារ

**ខ-មេដាយសំរឹទ្ធស្ថាបនាជាតិ :**

១-លោក **សោម ខាន** ប្រធានការិយាល័យអប់រំយុវជន និងកីឡា ខ័ណ្ឌព្រៃនប់ ថវិកាចំនួន ១.២០០ ដុល្លារ

២-លោក **សេក សារុន** អនុប្រធានការិយាល័យអប់រំ យុវជន និងកីឡា ខ័ណ្ឌព្រៃនប់ ថវិកាចំនួន ១.១០០ ដុល្លារ

៣-លោក **ចែម សែម** នាយកអនុវិទ្យាល័យព្រៃនប់ ថវិកាចំនួន ១.១៥០ ដុល្លារ

៤-លោក **ផាក គីម** អនុប្រធានការិយាល័យរដ្ឋបាលបុគ្គលិក បណ្ដុះបណ្ដាល ថវិកាចំនួន ១.១០០ ដុល្លារ

| | | | |
|---|---|---|---|
| ៥-លោក | **ជាង សេង** | អនុប្រធានការិយាល័យមធ្យមសិក្សាចំណេះទូទៅ | ថវិកាចំនួន ១.២០០ ដុល្លារ |
| ៦-លោក | **គី ស៊ីណា** | អនុប្រធានការិយាល័យបឋមសិក្សា-កុមារតូច | ថវិកាចំនួន ១.៣០០ ដុល្លារ |

**មាត្រា២:** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា និង អភិបាលក្រុងព្រះសីហនុ ត្រូវអនុវត្ត អនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

*រាជធានីភ្នំពេញ, ថ្ងៃទី ០៧ ខែ ៨ ឆ្នាំ ២០០៥*

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

**កន្លែងទទួល:**
-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចក្នុងមាត្រា ១ និង មាត្រា ២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ:.......[illegible]

# អនុក្រឹត្យ

## ស្តីពីការជូនមេដាយស្ថាបនាជាតិ

៙

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពី ការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី០៥ ខែ តុលា ឆ្នាំ១៩៩៥ ស្តីពីការបង្កើតនិងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់ នាយកខុទ្ទកាល័យសម្តេចប្រធានព្រឹទ្ធសភា

## សម្រេច

**មាត្រា១ :** ត្រូវបានបំពាក់ **មេដាយស្ថាបនាជាតិ** តាមលំដាប់ថ្នាក់ ជូនសប្បុរសជន ចំនួន០៨រូប ដែលបានបរិច្ចាគធនធានផ្ទាល់ខ្លួន ក្នុងការចូលរួមអភិវឌ្ឍន៍ប្រទេសជាតិ កន្លងមក ដូចមានរាយនាមខាងក្រោម :-

**ក-មេដាយមាសស្ថាបនាជាតិ :**

| | |
|---|---|
| ១-Mr. PHOLCHAROEN PHRAMAHA SHOW | ថវិកា ចំនួន ១២.៣៧០ ដុល្លារ |
| ២-លោកស្រី **កែវ ស៊ីធូ** | ថវិកា ចំនួន ១១.៣៥០ ដុល្លារ |
| ៣-លោក **ឃួន វណ្ណា** ប្រធានក្រុមហ៊ុន *ឃួន វណ្ណា កុងស្រ្តាក់ស្យុង* | ថវិកា ចំនួន ១០.៧៦០ ដុល្លារ |

**ខ-មេដាយប្រាក់ស្ថាបនាជាតិ :**

| | |
|---|---|
| ១-Mr. PIM-AKORN PHRANAHA TUAN | ថវិកា ចំនួន ៥.៦៦០ ដុល្លារ |
| ២-Mr. PI DORHYANAND PHRANAHA BOON DHAN | ថវិកា ចំនួន ៦.៧៨០ ដុល្លារ |
| ៣-Mr. PHRAS RIPARIYATTI MOLI | ថវិកា ចំនួន ៦.៤៦៥ ដុល្លារ |
| ៤-Mr. JINTHORN PHRANAHA | ថវិកា ចំនួន ៧.២៦០ ដុល្លារ |
| ៥-Mr. NAKPRAT PHRANAHA JURIYA | ថវិកា ចំនួន ៧.៨៥៧ ដុល្លារ |

**មាត្រា២:** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងនាយកខុទ្ទកាល័យសម្តេចប្រធានព្រឹទ្ធសភា ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

*រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ [illegible] ឆ្នាំ ២០០៥*

**ហ៊ុន សែន**

**កន្លែងទទួល:**

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចក្នុងមាត្រា ១ និង មាត្រា ២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ...៨៧០...អនក្រ.តត

# អនុក្រឹត្យ

## ស្ដីពីការជូនមេដាយមុនីសារាភ័ណ្ឌ

### រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី០៥ ខែ តុលា ឆ្នាំ១៩៩៥ ស្ដីពីការបង្កើតនិងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់ អភិបាលខេត្តកណ្ដាល

### សម្រេច

**មាត្រា១:** ត្រូវបានបំពាក់ **មេដាយមុនីសារាភ័ណ្ឌ** ថ្នាក់ **សេនា** ជូនលោក **ឱុច ឆុន** ប្រធានមន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ខេត្តកណ្ដាល ដែលមានស្នាដៃល្អ ក្នុងការបំពេញភារកិច្ចបំរើជាតិមាតុភូមិ កន្លងមក ។

**មាត្រា២:** រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងអភិបាលខេត្តកណ្ដាល ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។/.

រាជធានីភ្នំពេញ ថ្ងៃទី ៣ ខែ ធ្នូ ឆ្នាំ ២០០៥

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

**កន្លែងទទួល:**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្ដេចនាយករដ្ឋមន្ត្រី
- ដូចក្នុងមាត្រា ១ និង មាត្រា ២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ:......២៧១......អនក្រ.បក

# អនុក្រឹត្យ

## ស្តីពីការជូនមេដាយការងារ

៣៧

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី០៥ ខែ តុលា ឆ្នាំ១៩៩៥ ស្តីពីការបង្កើតនិងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់ អភិបាលខេត្តកណ្តាល

## សម្រេច

**មាត្រា១ :** ត្រូវបានបំពាក់ **មេដាយមាសការងារ** ជូនមន្ត្រីរាជការ ចំនួន០៨រូប នៃមន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ខេត្តកណ្តាល ដែលមានស្នាដៃល្អក្នុងការបំពេញភារកិច្ច ជូនជាតិមាតុភូមិ ដូចមានរាយនាមខាងក្រោម :-

| | | | |
|---|---|---|---|
| ១-លោក | **ព្រំ** | **វណ្ណៈ** | អនុប្រធានមន្ទីរ |
| ២-លោក | **គួច** | **ហ៊ុន** | ប្រធានការិយាល័យរដ្ឋបាល និង បុគ្គលិក |
| ៣-លោកស្រី | **អ៊ុច** | **ស៊ីណាត** | ប្រធានការិយាល័យហិរញ្ញវត្ថុ និង ផែនការ |
| ៤-លោក | **រស់** | **សុខុន** | អនុប្រធានមណ្ឌល បូរីកុមារកម្ពុជា បារាំង ហុងគ្រី |
| ៥-លោក | **យ៉ិន** | **បូរិន** | ប្រធានការិយាល័យ សង្គមកិច្ច ស្រុកតាខ្មៅ |
| ៦-លោក | **លាត** | **សារឿន** | ប្រធានការិយាល័យ សង្គមកិច្ច ស្រុកកៀនស្វាយ |
| ៧-លោក | **ចាន់** | **ភឿន** | ប្រធានការិយាល័យ សង្គមកិច្ច ស្រុកខ្សាច់កណ្តាល |
| ៨-លោក | **ហេង** | **នួច** | អនុប្រធានមន្ទីរ |

**មាត្រា២:** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងអភិបាលខេត្តកណ្តាល ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ... ខែ ធ្នូ ឆ្នាំ ២០០៥

**ហ៊ុន សែន**

<u>ចម្លងជូន:</u>
-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចក្នុងមាត្រា ១ និង មាត្រា ២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ: ១៣៧ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពីការជូនមេដាយស្ថាបនាជាតិ

៚

**រាជរដ្ឋាភិបាល**

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី០៥ ខែ តុលា ឆ្នាំ១៩៩៥ ស្តីពីការបង្កើតនិងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់ រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា

**សម្រេច**

**មាត្រា១:** ត្រូវបានបំពាក់ **មេដាយមាសស្ថាបនាជាតិ** ជូនលោក **ISHIZUKA YOHEI** សប្បុរសជនជប៉ុន ដែលបានឧបត្ថម្ភថវិកា តាមរយៈអង្គការ **JHP** នូវទឹកប្រាក់ ចំនួន ៣៣.៥៣៤ ដុល្លារអាមេរិក សំរាប់ជួយកសាងអគារសិក្សា ០១ខ្នង មាន០៥បន្ទប់ បង្គន់អនាម័យ ០១ខ្នង មាន០៤បន្ទប់ និង អណ្តូងទឹកមួយ នៅសាលាបឋម សិក្សា ចំបក់ ក្នុងភូមិចំបក់ ឃុំថ្មពេជ្រ ស្រុកត្បូងឃ្មុំ ខេត្តកំពង់ចាម ។

**មាត្រា២:** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា និង អភិបាលខេត្តកំពង់ចាម ត្រូវអនុវត្ត អនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ ធ្នូ ឆ្នាំ ២០០៥

នាយករដ្ឋមន្ត្រី

**ហ៊ុន សែន**

**កន្លែងទទួល:**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចក្នុងមាត្រា ១ និង មាត្រា ២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ:..៨៧៣...អនក្រ.បក

## អនុក្រឹត្យ

## ស្តីពីការជូនមេដាយស្ថាបនាជាតិ

៚

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី០៥ ខែ តុលា ឆ្នាំ១៩៩៥ ស្តីពីការបង្កើតនិងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់ រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា

## សម្រេច

**មាត្រា១:** ត្រូវបានបំពាក់ **មេដាយមាសស្ថាបនាជាតិ** ចំនួន០១គ្រឿង ជូនលោក SHIGETA YASUMITSU សប្បុរសជនជប៉ុន ដែលបានជួយឧបត្ថម្ភ តាមរយៈអង្គការ JHP នូវថវិកា ចំនួន ៣៥.៩១០ ដុល្លារអាមេរិក សំរាប់សាងសង់អគារសិក្សា ០១ខ្នង មាន០៥បន្ទប់ បំពាក់ដោយសម្ភារៈគ្រប់គ្រាន់ បង្គន់អនាម័យ ០១ខ្នង មាន០៥បន្ទប់ និងអណ្តូងទឹកមួយ នៅអនុវិទ្យាល័យ ក្តីទន្ទឹម ក្នុងភូមិថ្កូវ ឃុំជើងគួន ស្រុកសំរោង ខេត្តតាកែវ ។

**មាត្រា២:** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា និង អភិបាលខេត្តតាកែវ ត្រូវអនុវត្ត អនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ០៦ ខែ ធ្នូ ឆ្នាំ ២០០៥

នាយករដ្ឋមន្ត្រី

**ហ៊ុន សែន**

**កន្លែងទទួល:**

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចក្នុងមាត្រា ១ និង មាត្រា ២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ:......៥៧៣.....អនក្រ.បក

# អនុក្រឹត្យ
## ស្តីពីការជូនមេដាយការងារ

៙

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី០៥ ខែ តុលា ឆ្នាំ១៩៩៥ ស្តីពីការបង្កើតនិងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់ រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា

## សម្រេច

**មាត្រា១ :** ត្រូវបានបំពាក់ **មេដាយថ្នាក់ការងារ** ជូនមន្ត្រីអប់រំ ចំនួន ០៦រូប ដែលមានស្នាដៃល្អក្នុងការបំពេញ បេសកកម្មជួយពង្រឹង និង អភិវឌ្ឍន៍វិស័យអប់រំ នៅខេត្តព្រះវិហារ ដែលជាតំបន់ឆ្ងាយដាច់ស្រយាល ដោយទទួលបានលទ្ធផលល្អប្រសើរ ដូចមានរាយនាមខាងក្រោម :-

១-លោក **ពេញ សុវ៉ៃ** មន្ត្រីអធិការកិច្ច មន្ទីរអប់រំយុវជន និងកីឡា រាជធានីភ្នំពេញ

២-លោក **ហ៊ីង ឡុងសុខា** នាយកសាលាអនុវត្ត នៃសាលាគរុកោសល្យ ខេត្តកំពង់ឆ្នាំង

៣-លោក **សុខ សុនីរ** អនុប្រធានការិយាល័យ អ.យ.ក ស្រុកទឹកផុស ខេត្តកំពង់ឆ្នាំង

៤-លោក **ស៊ុន សុផល** អនុប្រធានការិយាល័យ អ.យ.ក ខណ្ឌទួលគោក

៥-លោក **ប៊ូយ គីមលី** អនុប្រធានការិយាល័យ បឋម និង មត្តេយ្យ ខេត្តកំពង់ចាម

៦-លោកស្រី **យិន សុខា** អនុប្រធានការិយាល័យ អ.យ.ក ខណ្ឌចំការមន

**មាត្រា២:** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និង រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា ត្រូវអនុវត្តអនុក្រឹត្យនេះអោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ០៧ ខែ ធ្នូ ឆ្នាំ ២០០៥

**ហ៊ុន សែន**

**កន្លែងទទួល:**

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចក្នុងមាត្រា ១ និង មាត្រា ២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ:...៨៧៥ អនក្រ.បក

## អនុក្រឹត្យ

## ស្តីពីការផ្ទេរភារកិច្ចជូននាយទាហាន

---

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៧ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងការពារជាតិ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញអនុក្រឹត្យលេខ ៦៥ អនក្រ.បក ចុះថ្ងៃទី ១៤ ខែ កញ្ញា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅរបស់ក្រសួងការពារជាតិ
- បានឃើញអនុក្រឹត្យលេខ ១៦ អនក្រ.បក ចុះថ្ងៃទី ២០ ខែ ធ្នូ ឆ្នាំ ២០០៣ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅរបស់ក្រសួងមហាផ្ទៃ
- យោងតាមសំណូមពរការងារចាំបាច់

## ស ម្រ េច

**មាត្រា ១ :** ត្រូវបានផ្ទេរភារកិច្ចជូនលោកវរសេនីយ៍ឯក **រុន សុវណ្ណា** អត្តលេខ ០០៨៦៩០ នាយមណ្ឌលចិញ្ចឹមនិវត្តន៍ជន និង កូនកំព្រា នាយកដ្ឋានសោធននិវត្តន៍ នៃក្រសួងការពារជាតិ មកបំរើការនៅអគ្គស្នងការដ្ឋាននគរបាលជាតិ ក្រសួងមហាផ្ទៃ ដោយរក្សាឋានន្តរស័ក្តិនៅដដែល ។

**មាត្រា ២ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងការពារជាតិ សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួងស្ថាប័នពាក់ព័ន្ធ និងសាមីខ្លួនត្រូវអនុវត្តអនុក្រឹត្យនេះ អោយមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី ០៨ ខែ ធ្នូ ឆ្នាំ ២០០៥

នាយករដ្ឋមន្ត្រី

**ហ៊ុន សែន**

**កន្លែងទទួល**

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *អគ្គលេខាធិការរាជរដ្ឋាភិបាល*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ដូចមាត្រា ២*
- *ឯកសារ_កាលប្បវត្តិ*

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ:...៨៧៦.អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការតែងតាំងក្រុមប្រឹក្សាភិបាល សំរាប់ដឹកនាំវិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញអនុក្រឹត្យលេខ ១៧ អនក្រ.បក ចុះថ្ងៃទី ០៧ ខែ មេសា ឆ្នាំ ២០០០ ស្តីពី ការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញអនុក្រឹត្យលេខ ៦៥ អនក្រ.បក ចុះថ្ងៃទី ១៧ ខែ តុលា ឆ្នាំ ១៩៩៧ ស្តីពីការបង្កើតវិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា
- យោងតាមសំណើរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

## សំរេច

**មាត្រា ១ :** ត្រូវបានតែងតាំងក្រុមប្រឹក្សាភិបាល សំរាប់ដឹកនាំវិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា ដែលមានសមាសភាពដូចខាងក្រោម :-

១- ឯកឧត្តម **គ្មី សារ៉ុន** តំណាងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ជាប្រធាន

២- ឯកឧត្តម **លី ផល្លា** ប្រធានអគ្គនាយកដ្ឋានចំការកៅស៊ូ ជាសមាជិកស្ម័យប្រវត្តិ

៣- លោក **ម៉ម ប៊ុន** តំណាងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ជាសមាជិក

៤- លោក **យិន សុខ** នាយកវិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា ជាសមាជិកស្ម័យប្រវត្តិ

៥- លោក **ម៉ក់ គីមហុង** តំណាងអ្នកដាំកៅស៊ូ ជាសមាជិក

៦- លោក **ប៉ិច សុវណ្ណា** តំណាងអ្នកដាំកៅស៊ូ ជាសមាជិក

៧- លោក **ភាណា ជេដ្ឋា** តំណាងបុគ្គលិកវិទ្យាស្ថាន ជាសមាជិកស្ម័យប្រវត្តិ

**មាត្រា ២ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ នាយកវិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ សហរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួងស្ថាប័នពាក់ព័ន្ធ និងសាមីខ្លួន ត្រូវអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី០៨ ខែ ធ្នូ ឆ្នាំ ២០០៥

ហ៊ុន សែន

**កន្លែងទទួល**

-ក្រសួងព្រះបរមរាជវាំង

-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា

-អគ្គលេខាធិការដ្ឋានរដ្ឋសភា

-អគ្គលេខាធិការរាជរដ្ឋាភិបាល

-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី

-ដូចមាត្រា ២

-ឯកសារ-កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ:...៧.០.៧.ស.ជ.ក្រ - ០៧

## អនុក្រឹត្យ

## ស្តីពីការជូនមេដាយស្ថាបនាជាតិ

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពី ការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យ ប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី០៥ ខែ តុលា ឆ្នាំ១៩៩៥ ស្តីពីការ បង្កើតនិងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់ សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## សម្រេច

**មាត្រា១:** ត្រូវបានបំពាក់ **មេដាយស្ថាបនាជាតិ** តាមលំដាប់ថ្នាក់ ប្រគេន និងជូនសប្បុរសជន ដែលបានបរិច្ចាគ ធនធាន ជួយកសាងព្រះវិហារ វត្តជីរោទ៍កណ្តាល ឃុំជីរោទ៍ទី១ ស្រុកត្បូងឃ្មុំ ខេត្តកំពង់ចាម ដូចមាន រាយព្រះនាមនិងនាមខាងក្រោម :-

**ក-មេដាយមាសស្ថាបនាជាតិ :**

| | | | |
|---|---|---|---|
| ១-ព្រះតេជគុណ | **ម៉ឹង សេន** | ចៅអធិការវត្តជីរោទ៍កណ្តាល | បច្ច័យចំនួន ១១.២០០ ដុល្លារ |
| ២-ឧបាសិកា | **តូច គីន** | នៅសហរដ្ឋអាមេរិក | ថវិកា ចំនួន ១១.៥០០ ដុល្លារ |
| ៣-លោក | **ខាំ សំអុល** | នៅសហរដ្ឋអាមេរិក | ថវិកា ចំនួន ១១.០០០ ដុល្លារ |
| ៤-លោកស្រី | **សេង គីមអ៊ន់** | នៅសហរដ្ឋអាមេរិក | ថវិកា ចំនួន ១០.០០០ ដុល្លារ |
| ៥-នាង | **ម៉ា យ៉ុង** | នៅខេត្តកំពង់ចាម | ថវិកា ចំនួន ១០.០០០ ដុល្លារ |

**ខ-មេដាយប្រាក់ស្ថាបនាជាតិ :**

| | | | |
|---|---|---|---|
| ១-ឧបាសិកា | **ម៉ុល ឡឿន** | នៅក្រុងភ្នំពេញ | ថវិកា ចំនួន ៥.២០០ ដុល្លារ |

២-លោក **ឆិត សន** អនុប្រធានការិយាល័យសង្គមកិច្ច និង អតីតយុទ្ធជន ស្រុកត្បូងឃ្មុំ ថវិកា ចំនួន ៥.១០០ ដុល្លារ

៣-លោកស្រី **ម៉ីន ពៅ** នៅសហរដ្ឋអាមេរិក ថវិកា ចំនួន ៥.០០០ ដុល្លារ

**មាត្រា២៖** រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងអភិបាលខេត្តកំពង់ចាម ត្រូវអនុវត្ត អនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

*រាជធានីភ្នំពេញ, ថ្ងៃទី ០៧ ខែ ៨ ឆ្នាំ ២០០៥*

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល៖**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្ដេចនាយករដ្ឋមន្ត្រី
- ដូចក្នុងមាត្រា ១ និង មាត្រា ២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**
លេខៈ...១១៣៨...អនក្រ.បក

# អនុក្រឹត្យ
## ស្តីពីការជូនមេដាយស្ថាបនាជាតិ
៚

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី០៥ ខែ តុលា ឆ្នាំ១៩៩៥ ស្តីពីការបង្កើតនិងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## សម្រេច

**មាត្រា១:** ត្រូវបានបំពាក់ **មេដាយមាសស្ថាបនាជាតិ** ចំនួន១១គ្រឿង ប្រគេន និងជូនសប្បុរសជនទៅក្នុងនិងក្រៅ ប្រទេស ដែលបានបរិច្ចាគធនធានផ្ទាល់ខ្លួន ដើម្បីជួយកសាងព្រះវិហារ សាលាហោត្រៃយ៍ សាលាបាលី សាលាឆាន់ របងវត្ត ទូកង និងចាក់ដី នៅវត្តសែនសេរី ស្ថិតក្នុងឃុំស្រយ៉ូវ ស្រុកស្ទឹងសែន ខេត្តកំពង់ធំ ដូចមានរាយព្រះនាមនិងនាមខាងក្រោម :-

១-ព្រះតេជគុណ **តុ អាន** ចៅអធិការវត្តសែនសេរី បច្ច័យ ៥៨.៧០០ ដុល្លារ

២-លោក **តុខ សេខ** និងលោកស្រី **កែ អេខ** អគ្គនាយកសណ្ឋាគារបុប្ផាទិព្វ និងជាថាងហ្វាងផលិតកម្មប្រាសាទពេជ្រភាពយន្ត ថវិកា ១១៩.៧០០ ដុល្លារ

៣-លោកឧកញ៉ា **ស៊ុត នារា** សប្បុរសជននៅរាជធានីភ្នំពេញ ថវិកា ២១.០០០ ដុល្លារ

៤-លោក **ហ៊ីង ចាន** អភិបាលរងខេត្តកណ្តាល ថវិកា ១២.០០០ ដុល្លារ

៥-លោក **ឃុន សឿ** នាយកក្រុមហ៊ុនសំណង់សុវណ្ណភូមិរាជធានីភ្នំពេញ ថវិកា ១៤.៥០០ ដុល្លារ

៦-លោក **គុជ ម៉ូលី** និងលោកស្រី **ស៊ុយ ម៉ុនធឿន** សប្បុរសជននៅរាជធានីភ្នំពេញ ថវិកា ១៥.៣០០ ដុល្លារ

៧-លោក **ហ៊ុច ហ៊ន** និងលោកស្រី **ឌុំ យិន** សប្បុរសជនខ្មែររស់នៅសហរដ្ឋអាមេរិក ថវិកា ២២.៣០០ ដុល្លារ

៨-លោក **ម្រែខ សាខុធ** និងលោកស្រី **យស់ ចាននារី** ប្រធានមន្ទីរផែនការខេត្តកំពង់ធំ ថវិកា ១១.២០០ ដុល្លារ

/៦

៩-លោក គឹម សួរ ប្រធានមន្ទីរធម្មការ និងសាសនា ខេត្តកំពង់ធំ ថវិកា ១០.៥០០ ដុល្លារ

១០-លោក ខ្និ អឿ និងលោកស្រី ខាត់ សុភាព ប្រធានការិ.សង្គមកិច្ចស្រុកកំពង់ស្វាយ ថវិកា ១១.៥០០ ដុល្លារ

១១-លោក ឡុង សុគន្ធ និងលោកស្រី ស៊ុយ ចៀង ស្នងការរងខេត្តកំពង់ធំ ថវិកា ១០.៨០០ ដុល្លារ

**មាត្រា២:** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និង អភិបាលខេត្តកំពង់ធំ ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។ ៕

*រាជធានីភ្នំពេញ ថ្ងៃទី ០៦ ខែ ធ្នូ ឆ្នាំ ២០០៥*

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

**កន្លែងទទួល:**
-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចក្នុងមាត្រា ១ និង មាត្រា ២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ..............

## សេចក្ដីសម្រេច

## ស្ដីពី

## ការកែសម្រួលប្រាក់ឧបត្ថម្ភគោលនយោបាយធានារ៉ាប់រងសង្គមសំរាប់មន្ត្រីរាជការស៊ីវិល

## រាជរដ្ឋាភិបាលកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស.រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលបានប្រកាសអោយប្រើច្បាប់ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ២៦ ខែ តុលា ឆ្នាំ ១៩៩៤ ដែលបានប្រកាសអោយប្រើច្បាប់ ស្ដីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១២៩៧/២៧៣/ ចុះថ្ងៃទី ០១ ខែ ធ្នូ ឆ្នាំ ១៩៩៧ ស្ដីពីគោលការណ៍រួមនៃការរៀបចំខុទ្ទកាល័យ ដោយ ... ... នៅលើ ... ...
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៤/២៨៤ ចុះថ្ងៃទី ២៧ ខែ កញ្ញា ឆ្នាំ ២០០៤ ស្ដីពីការបង្កើតឧត្ដមក្រុមប្រឹក្សាកំណែទំរង់រដ្ឋ
- បានឃើញអនុក្រឹត្យលេខ ៥១ អនក្រ.បក ចុះថ្ងៃទី ១០ ខែ មិថុនា ឆ្នាំ ១៩៩៩ ស្ដីពីការបង្កើតក្រុមប្រឹក្សាកំណែទំរង់រដ្ឋបាល
- បានឃើញអនុក្រឹត្យលេខ ៧១ អនក្រ.បក ចុះថ្ងៃទី ២៦ ខែ តុលា ឆ្នាំ ២០០៤ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់អគ្គលេខាធិការដ្ឋាន នៃក្រុមប្រឹក្សាកំណែទំរង់រដ្ឋបាល
- បានឃើញសេចក្ដីសំរេចលេខ ២៤៩ សសរ. ចុះថ្ងៃទី ០៥ ខែ វិច្ឆិកា ឆ្នាំ ១៩៨៨ របស់ក្រុមប្រឹក្សារដ្ឋមន្ត្រី ស្ដីពីរបបគោលនយោបាយធានារ៉ាប់រងសង្គម សំរាប់កម្មាភិបាល បុគ្គលិក កម្មកររដ្ឋ និវត្តជន និងជនបាត់បង់សមត្ថភាពពលកម្ម
- តាមសំណើរបស់ប្រធានក្រុមប្រឹក្សាកំណែទំរង់រដ្ឋបាល ;

សម្រេច

ប្រការ ១.-

សេចក្តីសំរេចនេះ មានគោលដៅកែសម្រួលប្រាក់ឧបត្ថម្ភគោលនយោបាយធានារ៉ាប់រងសង្គម សំរាប់មន្ត្រីរាជការស៊ីវិលដែលទទួលមរណភាព និងសំរាលកូន ដែលបានកំណត់ក្នុងសេចក្តីសំរេចលេខ ២៤៥សសរ. ចុះថ្ងៃទី ០៥ ខែ វិច្ឆិកា ឆ្នាំ ១៩៨៨ របស់ក្រុមប្រឹក្សារដ្ឋមន្ត្រី ស្តីពីរបបគោលនយោបាយធានារ៉ាប់រងសង្គម សំរាប់កម្មាភិបាល បុគ្គលិក កម្មកររដ្ឋ និវត្តជន និងជនបាត់បង់សមត្ថភាពពលកម្ម ។

ប្រការ ២.-

ត្រូវបានឧបត្ថម្ភជាថវិកា ដើម្បីរួមចំណែក និងជួយដល់គ្រួសារសពមន្ត្រីរាជការស៊ីវិលដែលទទួលមរណភាព សំរាប់ធ្វើពិធីបុណ្យតាមប្រពៃណី ក្នុងម្នាក់ៗ ដូចខាងក្រោម :

- ទទួលមរណភាពដោយជំងឺធម្មតា ចំនួន *១ ២០០ ០០០ រៀល ( មួយលាន ពីរសែន រៀល)*
- ទទួលមរណភាពក្នុងពេលបំពេញបេសកកម្ម ឬ គ្រោះថ្នាក់ការងារ ចំនួន *១ ៥០០ ០០០ រៀល ( មួយលាន ប្រាំសែន រៀល )* ។

ប្រការ ៣.-

មន្ត្រីរាជការស៊ីវិលជាស្ត្រីភេទដែលសំរាលកូន និងសំរាកលំហែមាតុភាព ត្រូវបានទទួលថវិកាឧបត្ថម្ភក្នុងម្នាក់ចំនួន *៦០០ ០០០ រៀល ( ប្រាំមួយរយ ពាន់ រៀល)* ។

ប្រការ ៤.-

ផលប្រយោជន៍ផ្សេងៗទៀតរបស់មន្ត្រីរាជការស៊ីវិលដែលទទួលមរណភាព និងសំរាលកូន នឹងមានកំណត់ដោយឡែក ។

ប្រការ ៥.-

នីតិវិធី និងបែបបទនៃការអនុវត្តសេចក្តីសម្រេចនេះ នឹងកំណត់ដោយប្រកាសរបស់ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា និងដោយមានការពិគ្រោះយោបល់ជាមួយក្រុមប្រឹក្សាកំណែទំរង់រដ្ឋបាល ។

ប្រការ ៦.-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ប្រធានក្រុមក្រុមប្រឹក្សាកំណែទំរង់រដ្ឋបាល រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័ន ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសម្រេចនេះ តាមភារកិច្ចរៀងៗខ្លួន ។

**ប្រការ ៧.-**

សេចក្តីសម្រេចនេះ មានប្រសិទ្ធភាពអនុវត្តចាប់ពីថ្ងៃទី០១ ខែ មករា ឆ្នាំ ២០០៦ តទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី០៦ ខែ ធ្នូ ឆ្នាំ ២០០៥

ហ៊ុន សែន

បានយកសេចក្តីជំរាបជូន

សម្តេចនាយករដ្ឋមន្ត្រី សូមមេត្តាចុះហត្ថលេខា

ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី

និងជាប្រធានក្រុមប្រឹក្សាកំណែទំរង់រដ្ឋបាល

**សុខ អាន**

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល
- អគ្គស្នងការដ្ឋានឧត្តមក្រុមប្រឹក្សាកំណែទំរង់រដ្ឋ
- ដូចប្រការ ៦
- ឯកសារ កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ...៥៣...សសរ

# សេចក្តីសំរេច
## ស្តីពី
## ការបង្កើតគណៈកម្មាធិការពិនិត្យវាយតំលៃការពិត សញ្ញាប័ត្រ និង លិខិតបញ្ជាក់ការសិក្សា

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យ លេខ នស / រកត / ០៧០៤ /១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៩ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការបង្កើតទីស្តីការគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០១ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការបង្កើតក្រសួងអប់រំ យុវជន និងកីឡា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣០៣/១២៩ ចុះថ្ងៃទី៣១ ខែ មីនា ឆ្នាំ២០០៣ ស្តីពីការទទួលស្គាល់គុណភាពអប់រំឧត្តមសិក្សា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០២០៥/០៩៧ ចុះថ្ងៃទី ២២ ខែ កុម្ភៈ ឆ្នាំ ២០០៥ ស្តីពីការកែសម្រួល មាត្រា១០មាត្រា១១ មាត្រា១៤ មាត្រា១៥ និង មាត្រា១៦ នៃព្រះរាជក្រឹត្យ ស្តីពីការទទួលស្គាល់គុណភាពអប់រំឧត្តមសិក្សា

-យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា

## សម្រេច

**ប្រការ១:** បង្កើត **គណៈកម្មាធិការពិនិត្យវាយតំលៃការពិតសញ្ញាប័ត្រ និង លិខិតបញ្ជាក់ការសិក្សា** ដែលមានសមាសភាពដូចខាងក្រោម÷

១- ឯកឧត្តម **ពិត ចំណាន** រដ្ឋលេខាធិការ ក្រសួងអប់រំ យុវជន និងកីឡា **ប្រធាន**

២-ឯកឧត្តម បណ្ឌិតរដ្ឋ **តិច សំណាង** អគ្គលេខាធិការ នៃគណៈកម្មាធិការទទួលស្គាល់គុណភាពអប់រំនៃកម្ពុជា **អនុប្រធានអចិន្ត្រៃយ៍**

៣- ឯកឧត្តម **ប៉ក់ ថាវិន** អគ្គនាយក នៃអគ្គនាយកដ្ឋានឧត្តមសិក្សា បច្ចេកទេស និង វិជ្ជាជីវៈ ក្រសួងអប់រំ យុវជន និងកីឡា **សមាជិក**

៤- ឯកឧត្តម **រស់ ចន្ទ្រាបុត្រ** អនុប្រធានរាជបណ្ឌិតសភាកម្ពុជា **សមាជិក**

៥- ឯកឧត្តម **កឹម រ័ត្នវិសិដ្ឋ** ទីប្រឹក្សាឯកឧត្តម ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី **សមាជិក**

៦- ឯកឧត្តម **ឡៅ ហ៊ុម** អគ្គនាយកនៃអគ្គនាយកដ្ឋានអប់រំបណ្តុះបណ្តាល បច្ចេកទេស និងវិជ្ជាជីវៈ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ **សមាជិក**

៧- ឧត្តមសេនីយ៍ទោ **នាង អេង** អគ្គនាយករង អគ្គនាយកដ្ឋានយោធសេវា និង ជានាយកនាយកដ្ឋានអប់រំ ក្រសួងការពារជាតិ **សមាជិក**

៨- លោកបណ្ឌិត **ជេត ជាលី** អគ្គលេខាធិការរង នៃគណៈកម្មាធិការទទួលស្គាល់គុណភាពអប់រំនៃកម្ពុជា **សមាជិក**

៩- លោក **ប៉ែន ស៊ីថុល** ប្រធាននាយកដ្ឋាន ស្តង់ដារ និងការទទួលស្គាល់គុណភាពអប់រំនៃគណៈកម្មាធិការទទួលស្គាល់គុណភាពអប់រំនៃកម្ពុជា **សមាជិក**

១០- លោក **ស សាម៉ុឌី** ប្រធាននាយកដ្ឋាននីតិកម្ម និង វិវាទមុខងារសាធារណៈ រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ **សមាជិក**

១១- លោក **យក់ សុផាន់ណា** សាកលវិទ្យាធិការរងនៃសាកលវិទ្យាល័យវិទ្យាសាស្ត្រសុខាភិបាល **សមាជិក**

១២- លោក **ចាន់ សារុទ្ធ** អនុប្រធាននាយកដ្ឋាន បុគ្គលិក និងអភិវឌ្ឍន៍ធនធានមនុស្ស ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ **សមាជិក**

១៣-លោកស្រី **ម៉ក់ ណាង** អនុប្រធាននាយកដ្ឋានឧត្តមសិក្សានៃក្រសួងអប់រំ យុវជន និងកីឡា **សមាជិក**

១៤- លោក **ហ៊ីង យ៉ាន** ព្រឹទ្ធបុរសពុទ្ធិកមហាវិទ្យាល័យព្រះសីហនុរាជ ក្រសួងធម្មការ និងកិច្ចការសាសនា **សមាជិក**

១៥- លោក **ឡុង ប៊ុណ្ណាស៊ីរីវឌ្ឍ** ព្រឹទ្ធបុរសរង មហាវិទ្យាល័យបុរាណវិទ្យា នៃសាកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈ ក្រសួងវប្បធម៌ និង វិចិត្រសិល្បៈ **សមាជិក**

**ប្រការ២:** ប្រធាន អនុប្រធាន និង សមាជិកទាំងអស់របស់គណៈកម្មាធិការនេះ ត្រូវមានសញ្ញាប័ត្រយ៉ាងទាបបំផុតពីថ្នាក់បរិញ្ញាប័ត្រជាន់ខ្ពស់ឡើងទៅ។

**ប្រការ៣:** គណៈកម្មាធិការនេះមានភារកិច្ចៈ

- វាយតំលៃកំរិតសញ្ញាប័ត្រ និង លិខិតបញ្ជាក់ការសិក្សា ក្នុងនិងក្រៅប្រទេស តាមសំណើសុំវាយតំលៃពីបុគ្គល ឬ ពីបណ្តាស្ថាប័ននានាទូទាំងប្រទេស ។

- កសាងលក្ខណៈវិនិច្ឆ័យសំរាប់វាយតំលៃករិតសញ្ញាប័ត្រ និង លិខិតបញ្ជាក់ការសិក្សាក្នុងនិងក្រៅប្រទេស ។

**ប្រការ៤:** អនុប្រធាន សមាជិកគណៈកម្មាធិការ ត្រូវចូលរួមប្រជុំការងារតាមការអញ្ជើញរបស់ប្រធាន។

ក្នុងករណីប្រធានជាប់បំពេញបេសកកម្មក្រៅប្រទេស ឬ សុំច្បាប់ឈប់សំរាកពីការងារ ដោយមានធុរៈផ្សេងៗ អនុប្រធានអចិន្ត្រៃយ៍ត្រូវបំពេញតួនាទីជាប្រធានស្តីទី ។

ក្នុងពេលប្រជុំវាយតំលៃករិតសញ្ញាប័ត្រ និង លិខិតបញ្ជាក់ការសិក្សា បុគ្គល ឬ ស្ថាប័នជាភាគីស្នើអាចចាត់តាំងតំណាង ឬ អោយសាមីជនមកជួបបំភ្លឺ និង ផ្តល់ពត៌មានដែលចាំបាច់ជូនគណៈកម្មាធិការ ។

**ប្រការ៥:** គណៈកម្មាធិការត្រូវបង្កើតលេខាធិការដ្ឋានអចិន្ត្រៃយ៍មួយ មានទីស្នាក់ការនៅទីស្តីការគណៈរដ្ឋមន្ត្រី និងមានសិទ្ធិប្រើត្រារបស់គណៈកម្មាធិការទទួលស្គាល់គុណភាពអប់រំនៃកម្ពុជា ដើម្បីសំរួលការងារ ។

សមាសភាព និងតួនាទីភារកិច្ច របស់លេខាធិការដ្ឋានអចិន្ត្រៃយ៍ត្រូវកំណត់ដោយគណៈកម្មាធិការ ។

**ប្រការ៦:** សេចក្តីសំរេចលេខ ៣៤ សសរ ចុះថ្ងៃទី ០៩ ខែ មេសា ឆ្នាំ ១៩៩៩ របស់រាជរដ្ឋាភិបាល និង បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងបទប្បញ្ញត្តិ នៃសេចក្តីសំរេចនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**ប្រការ៧:** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និង កីឡា រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងការពារជាតិ រដ្ឋមន្ត្រីក្រសួងសុខាភិបាល រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ រដ្ឋមន្ត្រីក្រសួងធម្មការ និង កិច្ចការសាសនា រដ្ឋមន្ត្រីក្រសួងវប្បធម៌ និង វិចិត្រសិល្បៈ រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រាជបណ្ឌិតសភាកម្ពុជា រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ គណៈកម្មាធិការទទួលស្គាល់គុណភាពអប់រំនៃកម្ពុជា និង សមាសភាព ដូចមានចែងក្នុងប្រការ១ ត្រូវអនុវត្តសេចក្តីសំរេចនេះ ឱ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ០៧ ខែ ៨ ឆ្នាំ ២០០៥

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល:**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច និងឯកឧត្តម ឧបនាយករដ្ឋមន្ត្រី
- ដូចប្រការ៧
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ...៤៤...សសរ

# សេចក្តីសំរេច

## ស្តីពី

## ការបង្កើតគណៈកម្មការអន្តរក្រសួង ដោះស្រាយបញ្ហាពាក់ព័ន្ធនឹងការសាងសង់ព្រះពុទ្ធបដិមាអង្គធំ នៅវត្តឯកភ្នំ ឃុំពាមឯក ស្រុកឯកភ្នំ ខេត្តបាត់ដំបង

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ នស / រកត / ០៧០៤ / ១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២ / នស / ៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២៦ ចុះថ្ងៃទី ២៦ ខែ មករា ឆ្នាំ ១៩៩៦ ប្រកាសអោយប្រើច្បាប់ ស្តីពីកិច្ចការពារបេតិកភ័ណ្ឌវប្បធម៌

-បានឃើញអនុក្រឹត្យលេខ ៩៨ អនក្រ.បក ចុះថ្ងៃទី ១៧ ខែ កញ្ញា ឆ្នាំ ២០០២ ស្តីពីការអនុវត្តច្បាប់កិច្ចការពារបេតិកភ័ណ្ឌវប្បធម៌

-យោងតាមការចាំបាច់របស់រាជរដ្ឋាភិបាល

## សម្រេច

**ប្រការ១:** បង្កើតគណៈកម្មការអន្តរក្រសួង ដោះស្រាយបញ្ហាពាក់ព័ន្ធនឹងការសាងសង់ព្រះពុទ្ធបដិមាអង្គធំ នៅវត្តឯកភ្នំ ឃុំពាមឯក ស្រុកឯកភ្នំ ខេត្តបាត់ដំបង ដែលមានសមាសភាពដូចខាងក្រោម:

១. ឯកឧត្តម **ជុំច ភឿន** រដ្ឋលេខាធិការ ក្រសួងវប្បធម៌ និង វិចិត្រសិល្បៈ **ប្រធាន**

២. ឯកឧត្តម **ជា ប៉េងឈាង** រដ្ឋលេខាធិការ ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ **អនុប្រធាន**

៣. ឯកឧត្តម **នូ ភឿង** អនុរដ្ឋលេខាធិការ ក្រសួងមហាផ្ទៃ **អនុប្រធាន**

៤. ឯកឧត្តម **ផ្លោក ផន** អនុរដ្ឋលេខាធិការ ក្រសួង ធម្មការ និង សាសនា **អនុប្រធាន**

៥. ឯកឧត្តម **សាយ សុផានិត្យ** អនុរដ្ឋលេខាធិការ ក្រសួងវប្បធម៌ និង វិចិត្រសិល្បៈ **សមាជិក**

៦. ឯកឧត្តម **កើត សារ៉េត** អនុរដ្ឋលេខាធិការ ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ **សមាជិក**

៧.ឯកឧត្តម **ខឹម វិសិដ្ឋ** សមាជិកក្រុមអង្កេតការណ៍ សេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ និងជា

ប្រធាននាយកដ្ឋានអប់រំ វប្បធម៌ និងសង្គមកិច្ច ទីស្តីការគណៈរដ្ឋមន្ត្រី **សមាជិក**

៨. ឯកឧត្តម **ចាន់ សាវុត** អនុរដ្ឋលេខាធិការ ក្រសួងពត៌មាន **សមាជិក**

៩. ឯកឧត្តម **ប្រាជ្ញ ច័ន្ទ** អភិបាលខេត្តបាត់ដំបង **សមាជិក**

១០. លោក **អឿម សុផុន** អភិបាលស្រុកឯកភ្នំ **សមាជិក**

**ប្រការ២:** ប្រធានគណៈកម្មការមានសិទ្ធិជ្រើសរើសលេខាមួយរូប ក្នុងក្រសួងវប្បធម៌ និង វិចិត្រសិល្បៈ ដើម្បីជួយការងាររបស់ខ្លួន។

**ប្រការ៣:** គណៈកម្មការនេះ មានតួនាទីភារកិច្ច ដូចខាងក្រោម :

-ពង្រឹងការអនុវត្តច្បាប់ ស្តីពីកិច្ចការពារបេតិកភ័ណ្ឌវប្បធម៌ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធដទៃទៀត ដល់រដ្ឋអំណាចមូលដ្ឋាន ដែលបណ្តែតបណ្តោយអោយសាងសង់ព្រះពុទ្ធដិមាអង្គធំ និងសំណង់ផ្សេងៗ ក្នុងតំបន់ហាមឃាត់នៃវត្តឯកភ្នំ និងដល់គណៈកម្មការសាងសង់

-សិក្សាបច្ចេកទេស និងការចំណាយសំរាប់រំកិល ព្រះពុទ្ធរូបអង្គធំ និងសំណង់ពាក់ព័ន្ធមកទីតាំងថ្មី

-ផ្លាស់ប្តូរទីតាំងនៃការសាងសង់ព្រះពុទ្ធរូបអង្គធំ និងសំណង់ពាក់ព័ន្ធដទៃទៀត ពីតំបន់ស្នូលហាមឃាត់ ទៅតំបន់២ ឬ តំបន់៣ ដោយគិតចម្ងាយពីមាត់ស្រះ ១៣០ ម៉ែត្រ យ៉ាងតិច

-ធ្វើការពិភាក្សា និងសម្របសម្រួល ជាមួយប្រជាពលរដ្ឋ និងគណៈកម្មការសាងសង់ព្រះពុទ្ធបដិមាអង្គធំ ដើម្បីដោះបញ្ហានេះដោយសន្តិវិធី

-ធ្វើរបាយការណ៍អំពីលទ្ធផលការងារ ជូនរាជរដ្ឋាភិបាល។

**ប្រការ៤:** -គណៈកម្មការមានសិទ្ធិប្រើប្រាស់ត្រា ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ ដើម្បីសំរួលការងារ

-ការចំណាយថវិកា និងមធ្យោបាយធ្វើដំណើរ ក្នុងការចុះបំពេញបេសកម្មជាបន្ទុករបស់ក្រសួងសាមីនីមួយៗ។

**ប្រការ៥:** សមាជិកទាំងអស់គណៈកម្មការត្រូវចូលរួមប្រជុំ និងចុះបំពេញភារកិច្ច តាមការអញ្ជើញ និងការចាត់តាំងរបស់ប្រធាន។

**ប្រការ៦:** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ រដ្ឋមន្ត្រីក្រសួងធម្មការ និង សាសនា រដ្ឋមន្ត្រីក្រសួងពត៌មាន រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង-ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួន ដូចមានចែងក្នុងប្រការ១ ត្រូវអនុវត្តសេចក្តីសំរេចនេះឱ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី ០៧ ខែ ធ្នូ ឆ្នាំ ២០០៥

នាយករដ្ឋមន្ត្រី

**ហ៊ុន សែន**

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច និង ឯកឧត្តម ឧបនាយករដ្ឋមន្ត្រី
- ដូចប្រការ៦
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

ជាតិ សាសនា ព្រះមហាក្សត្រ

MINISTRY OF ECONOMY AND FINANCE

**ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**

លេខ: ០០៩ សហវ

*រាជធានីភ្នំពេញ ថ្ងៃទី ០១ ខែ ធ្នូ ឆ្នាំ ២០០៥*

# សារាចរណែនាំ

## ស្តីពី

## ការគ្រប់គ្រងទំនិញនាំចូលគ្មានលក្ខណៈពាណិជ្ជកម្ម

៚ * ៚

កន្លងមកក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុបានសង្កេតឃើញបាតុភាពអសកម្មមួយចំនួន ពាក់ព័ន្ធនឹងការនាំចូលទំនិញគ្មានលក្ខណៈពាណិជ្ជកម្មដូចជាទំនិញមានលក្ខណៈពាណិជ្ជកម្មមួយចំនួនធំ ត្រូវបាននាំចូលក្នុងរូបភាពជាទំនិញគ្មានលក្ខណៈពាណិជ្ជកម្ម ហើយតម្លៃគិតពន្ធគយត្រូវបានកំណត់ដោយបំបែកវិក័យប័ត្រ ដើម្បីតម្រូវតាមសមត្ថកិច្ចរបស់ខ្លួន ឬគេចPSI ។ ករណីជាច្រើន ការនាំចូលពុំបានធ្វើឡើងដោយក្រុមហ៊ុនមានលេខអត្តសញ្ញាណកម្ម អាករលើតំលៃបន្ថែម (VAT IN) ត្រឹមត្រូវឡើយ ទោះបីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក៏ដូចជាទីចាត់ការគយនិងរដ្ឋាករ បានចេញនូវបទបញ្ញត្តិ និងការណែនាំនានាជាបន្តបន្ទាប់ក្តី ។ ដើម្បីកាត់បន្ថយនូវបាតុភាពអសកម្មនេះ និងដើម្បីឱ្យការអនុវត្តន៍យន្តការផ្តល់ប្រព្រឹត្តិកម្មស្មើភាពដល់ច្រកតំបន់ឱ្យដូចច្រកអន្តរជាតិបានរលូននោះ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ សូមធ្វើការរំលឹក និងណែនាំបន្ថែមដល់គ្រប់អង្គភាពគយនិងរដ្ឋាករដូចខាងក្រោម÷

១- ត្រូវអនុវត្តឱ្យបានម៉ឺងម៉ាត់តាមខ្លឹមសារនៃច្បាប់ និងបទបញ្ញត្តិជាធរមាននានា ជាពិសេសសារាចរលេខ ០០១ ចុះថ្ងៃទី ២៣ ខែកុម្ភៈ ឆ្នាំ ២០០០ របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ស្តីពីការបញ្ជាក់បន្ថែម និងការសំរួលនីតិវិធីនៃការកំណត់តម្លៃគិតពន្ធគយ និងតារាងតម្លៃគិតពន្ធគយជាធរមាននានាជាដើម ។

២- ទំនិញគ្មានលក្ខណៈពាណិជ្ជកម្ម គឺជាទំនិញដែលត្រូវបាននាំចូលម្តងម្កាលដោយអ្នកដំណើរ ឬត្រូវបាននាំចូលដោយប្រជាពលរដ្ឋដែលមានលំនៅដ្ឋានជាអចិន្ត្រៃយ៍ក្នុងតំបន់ព្រំដែន សំរាប់ការប្រើប្រាស់ផ្ទាល់ខ្លួន ឬការប្រើប្រាស់ក្នុងតំបន់ព្រំដែន ។

៣- ការនាំចូលម្តងម្កាលរបស់អ្នកដំណើរ ដែលត្រូវចាត់ទុកថាគ្មានលក្ខណៈពាណិជ្ជកម្ម ត្រូវបំពេញបែបបទគយតាមច្បាប់ជាធរមាន ដោយត្រូវបង្ហាញនូវលិខិតឆ្លងដែន ដែលមានការបញ្ជាក់ពីការចេញ- ចូលប្រទេសពីស្ថាប័នមានសមត្ថកិច្ចច្រកទ្វារ ហើយត្រូវប្រថាប់ត្រា ឬសរសេរលើបង្កាន់ដៃពន្ធថា “គ្មានលក្ខណៈពាណិជ្ជកម្ម- សំរាប់ការប្រើប្រាស់ផ្ទាល់ខ្លួន” និងពុំបាច់បិទត្រាគយឡើយ។ ក្នុងករណី

ដែលអ្នកដំណើរម្ដងម្កាលនោះនាំចូលទំនិញហើយ ប្រកាសថាមានលក្ខណៈពាណិជ្ជកម្មសំរាប់ធ្វើអាជីវកម្ម ការកំណត់តម្លៃគិតពន្ធគយត្រូវបូកបន្ថែម ២០ភាគរយ លើតម្លៃគិតពន្ធគយជាធរមាន និងត្រូវប្រថាប់ត្រា ឬសរសេរលើបង្កាន់ដៃពន្ធថា "មានលក្ខណៈពាណិជ្ជកម្ម" ហើយត្រូវបិទត្រាគយជូនប្រសិនបើមុខទំនិញនោះស្ថិតក្រោមប្រព័ន្ធត្រាគយ ដើម្បីអាចចរាចរលើទីផ្សារបាន ។

៤- ចំពោះការនាំចូលរបស់ប្រជាជនដែលមានលំនៅដ្ឋានជាអចិន្ត្រៃយ៍ក្នុងតំបន់ព្រំដែន ត្រូវបំពេញបែបបទគយតាមការកំណត់ជាធរមាន ហើយត្រូវប្រថាប់ត្រា ឬសរសេរលើបង្កាន់ដៃពន្ធថា "សំរាប់ចរាចរក្នុងតំបន់ព្រំដែន" ។ ប្រជាជនតំបន់ព្រំដែន ដែលធ្វើអាជីវកម្មនាំចេញ- នាំចូលទំនិញមានលក្ខណៈពាណិជ្ជកម្មសំរាប់ចរាចរទៅទូទាំងប្រទេសនោះ ត្រូវតែបង្កើតជាក្រុមហ៊ុនដែលមានលេខអត្តសញ្ញាណកម្ម អាករលើតំលៃបន្ថែម និងត្រូវមានប័ណ្ណប៉ាតង់ឆ្នាំចុងក្រោយដូចអ្នកនាំចេញ- នាំចូលធម្មតា ហើយក្នុងករណីចាំបាច់ ត្រូវអនុវត្តដូចការណែនាំក្នុងចំណុចទី ៣ ខាងលើនេះ ។

៥- ការនាំចេញ- នាំចូលផ្សេងទៀត ក្រៅពីមានចែងក្នុងចំណុច ៣ និង ៤ ខាងលើ ត្រូវតែធ្វើឡើងដោយបុគ្គលដែលមានលេខអត្តសញ្ញាណកម្ម អាករលើតម្លៃបន្ថែម និងមានប័ណ្ណប៉ាតង់ឆ្នាំចុងក្រោយ ។ ករណីផ្ទុយពីនេះ ត្រូវមានការអនុញ្ញាតដោយឡែកពីទីចាត់ការគយនិងរដ្ឋាករ ។

៦- ការប្រើប្រាស់ច្បាប់ចំលងនៃវិញ្ញាបនប័ត្រចុះបញ្ជីអាករលើតម្លៃបន្ថែម និងប័ណ្ណប៉ាតង់ឆ្នាំចុងក្រោយ ត្រូវមានការបញ្ជាក់ជាលាយល័ក្ខអក្សរលើនោះពីបណ្ណាធិការក្រុមហ៊ុន អមដោយលិខិតផ្ទេរសិទ្ធិច្បាប់ដើម អត្តសញ្ញាណប័ណ្ណរបស់អ្នកទទួលសិទ្ធិ ឬបំពេញបែបបទគយ ដែលចុះហត្ថលេខាដោយបណ្ណាធិការ និងមានប្រថាប់ត្រាសាម៉ីក្រុមហ៊ុនលើនោះ ហើយក្នុងករណីចាំបាច់ត្រូវទំនាក់ទំនងផ្ទៀងផ្ទាត់ជាមួយក្រុមហ៊ុននោះឡើងវិញ ។

ទីចាត់ការគយនិងរដ្ឋាករ ត្រូវចាត់ចែងផ្សព្វផ្សាយ និងណែនាំដល់គ្រប់អង្គភាពគយនិងរដ្ឋាករដែលមានការពាក់ព័ន្ធ ឱ្យទទួលអនុវត្តតាមខ្លឹមសារនេះឱ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃទី ០១ ខែ មករា ឆ្នាំ ២០០៦ តទៅ ។

**ទេសរដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

**និងជាប្រធានគណៈកម្មការអន្តរក្រសួងទប់ស្កាត់និងបង្ក្រាបអំពើរត់គេចពន្ធ**

**គាត ឈន់**

**ចម្លងជូន :**

- គ្រប់សភាពាណិជ្ជកម្ម ខេត្ត- ក្រុង
  "ដើម្បីជ្រាប និងចូលរួមផ្សព្វផ្សាយ អនុវត្ត"
- ឯកសារ- កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

លេខ ០៦២៧ សហវ

រាជធានីភ្នំពេញ.ថ្ងៃទី ០១ ខែ ធ្នូ ឆ្នាំ ២០០៥

# សេចក្តីជូនដំណឹង

## ស្តីពី

## ការបិទត្រាពន្ធគយលើទំនិញមួយចំនួនដែលនាំចូល ក្រោមរបបនាំចូលស្អាតរ ដោយបង់ពន្ធ និង អាករ តាមច្បាប់ជាធរមាន

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ សូមជូនដំណឹងដល់អាជីវករទាំងអស់ដែលជាអ្នកនាំចេញ នាំចូល ម្ចាស់អាជីវកម្មដ្ឋាន សន្និធិ ចរាចរ ចែកចាយដុំ ឬ រាយ ឱ្យបានជ្រាបថា មុខទំនិញនាំចូលដោយបង់ពន្ធ អាករ តាមច្បាប់ជាធរមាន ហើយត្រូវ បិទត្រាពន្ធគយ ចាប់ពីថ្ងៃទី ០១ ខែ មករា ឆ្នាំ ២០០៦តទៅ មានដូចខាងក្រោម:

| ល.រ | មុខទំនិញ | របៀបបិទត្រាពន្ធគយ |
|---|---|---|
| ០១ | ស្រាគ្រប់ប្រភេទ | បិទលើដប |
| ០២ | ស្រាបៀរ | បិទលើកេស |
| ០៣ | ទឹកក្រូច | បិទលើកេស ឬសំបកវេចខ្ចប់ |
| ០៤ | ទឹកសណ្តែក ចាហួយ ទឹកត្រចៀកកាំ | បិទលើកេស |
| ០៥ | ទឹកដមផ្លែឈើ | បិទលើកេស |
| ០៦ | ទឹកដោះគោខាប់ | បិទលើកេស |
| ០៧ | ទឹកដោះគោគ្រប់ប្រភេទក្រៅពីទឹកដោះគោខាប់ | បិទលើកេស |
| ០៨ | ទឹកបរិសុទ្ធម៉ាក EVIAN | បិទលើកេស |
| ០៩ | ទឹកបរិសុទ្ធម៉ាកផ្សេងទៀតក្រៅពី EVIAN | បិទលើកេស |
| ១០ | ភេសជ្ជៈផ្សេងទៀត | បិទលើកេស |
| ១១ | ផ្លែឈើស្រស់ និង ក្រៀមគ្រប់ប្រភេទ(ផ្ទុកក្នុងកេស) | បិទលើកេស |
| ១២ | បន្លែ ឬ ផ្លែឈើកំប៉ុង | បិទលើកេស |
| ១៣ | ត្រី ឬ សាច់កំប៉ុង | បិទលើកេស |
| ១៤ | នំគ្រប់ប្រភេទដាក់ក្នុងកេស ឬធុងចំណុះលើសពី១០លីត្រ | បិទលើកេស ឬសំបកវេចខ្ចប់ |

| | | |
|---|---|---|
| ១៥ | មី ឬ គុយទាវកញ្ចប់ កំប៉ុង | បិទលើកេស ឬសំបកវេចខ្ចប់ |
| ១៦ | ម្សៅមី បាវ ឬ កញ្ចប់ | បិទលើបាវ ឬសំបកវេចខ្ចប់ |
| ១៧ | ប៊ីចេងដាក់កេស ឬ កញ្ចប់ | បិទលើកេស ឬសំបកវេចខ្ចប់ |
| ១៨ | ទឹកត្រី ទឹកស៊ីអ៊ីវ ទឹកជ្រលក់ គ្រប់ប្រភេទ | បិទលើកេស |
| ១៩ | ប្រេងឆាកំប៉ុង ដប ផ្ទុកក្នុងកេស ឬផ្ទុកក្នុងសំបកវេចខ្ចប់ចំណុះលើសពី១០លីត្រ | បិទលើកេស ឬសំបកវេចខ្ចប់ |
| ២០ | គ្រឿងឧបភោគ បរិភោគ ផ្សេងៗទៀត | បិទលើកេស |
| ២១ | បារី HERO | បិទលើកេស |
| ២២ | បារី JET | បិទលើកេស |
| ២៣ | បារី 555, MALBORO & MILD SEVEN | បិទលើកេស |
| ២៤ | បារីផ្សេងៗទៀត | បិទលើកេស |
| ២៥ | ប្រេងម៉ាស៊ីន កំប៉ុង ដបដែលផ្ទុកក្នុងកេស ឬផ្ទុកក្នុងសំបកវេចខ្ចប់ចំណុះលើសពី១០លីត្រ | បិទលើកេស ឬសំបកវេចខ្ចប់ |
| ២៦ | ក្រណាត់ | បិទលើចុងក៏ រ៉ូឡូ ឬសំបកវេចខ្ចប់ |
| ២៧ | ម៉ាស៊ីន VTR , VCD , DVD | បិទលើកេស |
| ២៨ | ទូរទស្សន៍ពណ៌ | បិទលើកេស |
| ២៩ | ទូរទស្សន៍ ស ខ្មៅ | បិទលើកេស |
| ៣០ | ម៉ាញេ៉គ្រប់ប្រភេទ | បិទលើកេស |
| ៣១ | ម៉ាស៊ីនត្រជាក់ | បិទលើកេស |
| ៣២ | ឆ្នាំងអគ្គិសនីសំរាប់ចំអិនអាហារ | បិទលើកេស |
| ៣៣ | ចង្ក្រានចំអិនអាហារ ( ប្រើឧស្ម័ន ឬ អគ្គិសនី) | បិទលើកេស |
| ៣៤ | ម៉ាស៊ីនបោកគក់ | បិទលើកេស |
| ៣៥ | ម៉ាស៊ីនថតគ្រប់ប្រភេទ ( រូបភាព . វីដេអូ ) | បិទលើកេស( មួយសឡឹកសំរាប់មួយគ្រឿង) |
| ៣៦ | ទូទឹកកក ទូត្រជាក់ ប្រើអគ្គិសនី | បិទលើកេស |
| ៣៧ | អាគុយចាប់ពី 40Aឡើង | បិទលើកេស |
| ៣៨ | អាគុយក្រោម 40A | បិទលើកេស |
| ៣៩ | សំបកកង់រថយន្ត | បិទលើសំបកកង់ |
| ៤០ | សំបកកង់ម៉ូតូថ្មី | បិទលើសំបកកង់ |
| ៤១ | សាប៊ូគ្រប់ប្រភេទ ( ម្សៅ ដុំ និង រាវ ដាក់ក្នុងកេស) | បិទលើកេស |
| ៤២ | ទឹកអប់គ្រប់ប្រភេទ | បិទលើកេស |
| ៤៣ | ក្រែម ម្សៅ ឡេ គ្រប់ប្រភេទ | បិទលើកេស |
| ៤៤ | គ្រឿងតុបតែងកែលំអ អនាម័យខ្លួនប្រាណផ្សេងទៀត ដាក់ក្នុងកេស | បិទលើកេស |

| | | |
|---|---|---|
| ៤៥ | ថ្នាំដុសធ្មេញដាក់ក្នុងកេស | បិទលើកេស |
| ៤៦ | ប្រេងកូឡាគ្រប់ប្រភេទ | បិទលើកេស |
| ៤៧ | ប្រេងខ្យល់គ្រប់ប្រភេទ | បិទលើកេស |
| ៤៨ | ថ្នពិលដាក់ក្នុងកេស | បិទលើកេស |
| ៤៩ | ក្រដាសគ្រប់ប្រភេទ រ៉ូឡូ កេស ឬ រ៉ាមលើសពី១០គ.ក្រ | បិទលើរ៉ូឡូ កេស រ៉ាមធំ (បិទលើរ៉ាម) |

ក្រដាសត្រាពន្ធគយដែលមានបោះត្រាសំគាល់លើនោះដោយការិយាល័យ ឬសាខាគយ និង រដ្ឋាករ ដែលពាក់ព័ន្ធ ត្រូវបិទមួយសន្លឹកលើកេស ឬសំបកវេចខ្ចប់ទំនិញ ដូចមានបញ្ជាក់ក្នុងតារាងខាងលើត្រង់កន្លែងណាមួយក៏បាន និងកំណត់តំលៃ ៥០ .០០ ក្នុងមួយសន្លឹក ។

ចំពោះទំនិញនាំចូលតាមកុងតឺន័រ មន្ត្រីគយ-រដ្ឋាករ មានសមត្ថកិច្ច ត្រូវប្រគល់ត្រាពន្ធគយតាម បរិមាណស្របតាម បង្កាន់ដៃពន្ធជូនម្ចាស់ឬ តំណាងម្ចាស់ទំនិញនាពេលអនុញ្ញាតឱ្យយកទំនិញចេញពីគយ ។ ម្ចាស់ ឬតំណាងម្ចាស់ទំនិញ ត្រូវចាត់ចែង បិទត្រាពន្ធគយទាំងនោះភ្លាមនាពេលរើទំនិញចេញពីកុងតឺន័ររបស់ខ្លួន ។

បណ្តាអាជីវករដែលពាក់ព័ន្ធ ត្រូវអនុវត្តអោយបានត្រឹមត្រូវតាមសេចក្តីជូនដំណឹងនេះសំរាប់ទំនិញដែលផ្ទុកចូលមធ្យោបាយដឹកជញ្ជូនដើម្បីនាំចូលមកកម្ពុជា ចាប់ពីថ្ងៃទី ០១ ខែ មករា ឆ្នាំ ២០០៦ នេះតទៅជាកំហិត ។ ក្នុងករណីដែលមន្ត្រីគយ និងរដ្ឋាករ មានសមត្ថកិច្ចរកឃើញថា ទំនិញទាំងនោះមិនមានបិទត្រាពន្ធគយ ស្របតាមការកំណត់ខាងលើទេ ទោះជាកំពុងចរាចរ លើផ្ទៃប្រទេស ឬកំពុង ស្ថិតនៅក្នុងភណ្ឌាគារទំនិញនានាក៏ដោយ នឹងត្រូវចាត់ទុកជាទំនិញល្មើស ដែលនឹងត្រូវរងនូវការបង្ខំអោយបង់ពន្ធ និង ពិន័យតាមច្បាប់ជាធរមាន ។

សេចក្តីជូនដំណឹងទាំងឡាយណាដែលពាក់ព័ន្ធនឹងការប្រើប្រាស់ត្រាពន្ធគយដែលមានកន្លងមក និង មានខ្លឹមសារផ្ទុយត្រូវចាត់ទុកជានិរាករណ៍ ។

អាស្រ័យហេតុនេះ សូមលោកឧកញ៉ា លោកជំទាវ អស់លោក លោកស្រី ទាំងអស់ដែលជាអាជីវករពាក់ព័ន្ធ មេត្តាសហការអនុវត្តតាមសេចក្តីជូនដំណឹងនេះអោយមានប្រសិទ្ធភាព ដើម្បីលើកស្ទួយសីលធម៌ពន្ធដារក្នុងសង្គមកម្ពុជាយើងជាបណ្តើរៗបន្ថែមទៀត ចូលរួមកាត់បន្ថយអោយបានជាអតិបរមានូវអំពើរត់គេចពន្ធ ឬ ការឆ្លៀតឱកាសល្មើសច្បាប់នានាជាមិនខាន ។

**ចម្លងជូន :**

- ទីចាត់ការគយ និង រដ្ឋាករ

(ដើម្បីផ្សព្វផ្សាយ និង អនុវត្ត)

- សភាពាណិជ្ជកម្មរាជធានីភ្នំពេញ

(ជូនជ្រាប និង សុំកិច្ចសហការផ្សព្វផ្សាយ)

- ឯកសារ-កាលប្បវត្តិ

**ទេសរដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**

**និងជាប្រធានគណៈកម្មការ អន្តរក្រសួង ទប់ស្កាត់**

**បង្ក្រាបអំពើរត់គេចពន្ធ**

**គាត ឈន់**

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King

ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល
Ministry of Industry, Mines and Energy
Nº ៩៦៧ ឧ.រ.ថ.ក.ទ.ព្រ

រាជធានីភ្នំពេញ, ថ្ងៃទី ០១ ខែ ធ្នូ ឆ្នាំ ២០០៥

# ប្រកាស

## រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/ រកត / ០៧០៤/ ១២៤ ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/ ០១៩៦/ ០៥ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើត ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល
- បានឃើញអនុក្រឹត្យលេខ ៣៥ អនក្រ.បក ចុះថ្ងៃទី២៦ ខែមេសា ឆ្នាំ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅរបស់ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល
- បានឃើញលិខិតលេខ ៣៦២២/០៥ គ.វ.ក ចុះថ្ងៃទី ២៦.១០.២០០៥ របស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- យោងពាក្យស្នើរបស់ក្រុមហ៊ុន អ៊ី ហ្គាមេន ចុះថ្ងៃទី១១.១០.២០០៥

# សំរេច

ប្រការ១: អនុញ្ញាតឱ្យក្រុមហ៊ុន អ៊ី ហ្គាមេន ( E GARMENT CO., LTD.) តំណាងដោយ លោក HUI KWOK LEUNG, LOUIS សញ្ជាតិអង់គ្លេស អាយុ៥១ឆ្នាំ កាន់លិខិតឆ្លងដែនលេខ GBR 761005038 ចុះថ្ងៃទី១២.១១.២០០១ បង្កើតរោងចក្រ "កាត់ដេរ និងចាក់សម្លៀកបំពាក់" ដែលមានឈ្មោះថា "អ៊ី ហ្គាមេន ( E GARMENT )" មានទីតាំងស្ថិតនៅ ឃុំស្វាយរលំ ស្រុកស្អាង ខេត្តកណ្តាល ។

៤៥ មហាវិថីព្រះនរោត្តម ខ័ណ្ឌដូនពេញ ភ្នំពេញ ទូរស័ព្ទ : (៨៥៥) ២៣.២១១១៤១ . ទូរសារ : ៨៥៥.២៣.៤២៨២៦៣
45 Preah Norodom Boulevard, Khan Daun Penh, Phnom Penh, Phone : 855.23.211141 , Fax : 855.23.428263

ប្រការ២: ក្នុងកិច្ចដំណើរការក្រុមហ៊ុនត្រូវរៀបចំរោងចក្រទៅតាមប្លង់ ដែលបានតំកល់ទុកនៅក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ហើយក្រុមហ៊ុនត្រូវផ្តល់លិខិតអនុញ្ញាតសាងសង់មកក្រសួង ក្នុងរយៈពេល២ខែ យ៉ាងយូរ។

ប្រការ៣: រោងចក្រនេះត្រូវបានអនុញ្ញាតឱ្យ "កាត់ដេរ និងចាក់សម្លៀកបំពាក់" ហើយត្រូវធ្វើរបាយការណ៍ប្រចាំខែ អំពីស្ថានភាពផលិតកម្មរបស់រោងចក្រ ជូនក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ។

ប្រការ៤: ក្រុមហ៊ុនត្រូវលើកបង្ហាញ "ផ្លាកឈ្មោះរោងចក្រ " របស់ខ្លួនជាអក្សរខ្មែរមានទំហំធំជាង និងនៅពីលើអក្សរផ្សេងទៀត នៅកន្លែងដែលងាយមើលឃើញនៅខាងមុខរោងចក្រ ។

ប្រការ៥: ការពង្រីកផលិតកម្ម ផ្លាស់ប្តូរមុខផលិតផល ផ្លាស់ប្តូរទីតាំងរោងចក្រ ឬ បង្កើតសាខារោងចក្រ ក្រុមហ៊ុនត្រូវសុំការអនុញ្ញាត ពីក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ។

ប្រការ៦: ក្រុមហ៊ុន ត្រូវធានាសុវត្ថិភាពឧស្សាហកម្ម និង គុណភាពផលិតផល ព្រមទាំងត្រូវគោរពឱ្យបានម៉ឺងម៉ាត់ នូវច្បាប់ និងបទប្បញ្ញត្តិនានា ដែលពាក់ព័ន្ធនឹងផលិតកម្ម អាជីវកម្ម របស់ក្រុមហ៊ុន ។

ប្រការ៧: ក្រុមហ៊ុន ត្រូវសហការជាមួយមន្ត្រីមានសមត្ថកិច្ចនៃក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ក្នុងគោលបំណងអនុវត្តប្រកាសនេះ ឱ្យមានប្រសិទ្ធភាព ។

ប្រការ៨: ក្នុងករណីរោងចក្រផ្អាកដំណើរការជាប់ៗគ្នាក្នុងរយៈពេល១២ខែ ឬ ប្រព្រឹត្តល្មើសច្បាប់ ឬ ល្មើសធ្ងន់ធ្ងរនឹងប្រការណាមួយ ដែលបានចែងខាងលើ ប្រកាសនេះនឹងត្រូវដកហូត ដោយគ្មានសំណងអ្វីឡើយ ។

ប្រការ៩: អគ្គនាយកឧស្សាហកម្ម ប្រធាននាយកដ្ឋានពាក់ព័ន្ធ ប្រធានមន្ទីរឧស្សាហកម្ម រ៉ែ និង ថាមពល ខេត្តកណ្តាល និងប្រធានក្រុមហ៊ុន អ៊ី ហ្គាមេន ត្រូវអនុវត្តប្រកាសនេះ តាមមុខការរៀង១ខ្លួន ។

ប្រការ១០: ប្រកាសនេះមានអនុភាពគតិយុត្តិ ចាប់ពីថ្ងៃចុះហត្ថលេខា តទៅ ។

រដ្ឋមន្ត្រី

ស៊ុយ_សែម

ចម្លងជូន :
-ទីស្តីការគណៈរដ្ឋមន្ត្រី
-រាជកិច្ច
-ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
-ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
-ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ
-ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់
-ក្រសួងបរិស្ថាន
-ក្រសួងពាណិជ្ជកម្ម
-សាលាខេត្តកណ្តាល
" ដើម្បីជូនជ្រាប "
-ដូចប្រការ ៩ " ដើម្បីអនុវត្ត"
-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
**Kingdom of Cambodia**
Nation Religion King

ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល
Ministry of Industry, Mines and Energy
Nº ៩២៧ ឧរច.គឧ.ប្រក.

រាជធានីភ្នំពេញ, ថ្ងៃទី ០៦ ខែ ធ្នូ ឆ្នាំ ២០០៥

# ប្រកាស

## រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/ រកត / ០៧០៤/ ១២៤ ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/ ០១៩៦/ ០៥ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើត ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល
- បានឃើញអនុក្រឹត្យលេខ ៣៥ អនក្រ.បក ចុះថ្ងៃទី២៦ ខែមេសា ឆ្នាំ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល
- បានឃើញលិខិតលេខ ៣៥៤៣/០៥ ក.វ.ក ចុះថ្ងៃទី២១.១០.២០០៥ របស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- យោងពាក្យស្នើរបស់ក្រុមហ៊ុន នូវ ខប ចុះថ្ងៃទី១០.១០.២០០៥

# សំរេច

ប្រការ១: អនុញ្ញាតឱ្យក្រុមហ៊ុន នូវ ខប (NOW CORP) តំណាងដោយលោក JEONG HYUN WOO សញ្ជាតិកូរ៉េ អាយុ៤៤ឆ្នាំ កាន់លិខិតឆ្លងដែនលេខ SQ0068387 ចុះថ្ងៃទី១៤.០២.២០០៥ បង្កើតរោងចក្រ "កាត់ដេរសម្លៀកបំពាក់" ដែលមានឈ្មោះថា "នូវ ខប (NOW CORP)" មានទីតាំងស្ថិតនៅភូមិជើងអក ឃុំលំហាច ស្រុកអង្គស្នួល ខេត្តកណ្តាល។

ប្រការ២: ក្នុងកិច្ចដំណើរការ ក្រុមហ៊ុនត្រូវរៀបចំរោងចក្រទៅតាមប្លង់ ដែលបានតំកល់ទុកនៅក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ។ ល។

៤៥ មហាវិថីព្រះនរោត្តម ខ័ណ្ឌដូនពេញ ភ្នំពេញ ទូរស័ព្ទ : (៨៥៥) ២៣.២១១១៤១ , ទូរសារ : ៨៥៥.២៣.៤២៨២៦៣
45 Preah Norodom Boulevard, Khan Daun Penh, Phnom Penh, Phone : 855.23.211141 , Fax : 855.23.428263

ប្រការ៣: រោងចក្រនេះត្រូវបានអនុញ្ញាតឱ្យ “កាត់ដេរសម្លៀកបំពាក់” ហើយត្រូវធ្វើរបាយការណ៍ប្រចាំខែអំពីស្ថានភាពផលិតកម្មរបស់រោងចក្រ ជូនក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ។

ប្រការ៤: ក្រុមហ៊ុនត្រូវលើកបង្ហាញ “ផ្លាកឈ្មោះរោងចក្រ ” របស់ខ្លួនជាអក្សរខ្មែរមានទំហំធំជាង និងនៅពីលើអក្សរផ្សេងទៀត នៅកន្លែងដែលងាយមើលឃើញនៅខាងមុខ រោងចក្រ ។

ប្រការ៥: ការពង្រីកផលិតកម្ម ផ្លាស់ប្តូរមុខផលិតផល ផ្លាស់ប្តូរទីតាំងរោងចក្រ ឬ បង្កើតសាខារោងចក្រ ក្រុមហ៊ុនត្រូវសុំការអនុញ្ញាតពីក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ។

ប្រការ៦: ក្រុមហ៊ុនត្រូវធានាសុវត្ថិភាពឧស្សាហកម្ម និង គុណភាពផលិតផល ព្រមទាំងត្រូវគោរពឱ្យបានម៉ឺងម៉ាត់ នូវច្បាប់ និងបទប្បញ្ញត្តិនានា ដែលពាក់ព័ន្ធនឹងផលិតកម្ម អាជីវកម្ម របស់ក្រុមហ៊ុន ។

ប្រការ៧: ក្រុមហ៊ុន ត្រូវសហការជាមួយមន្ត្រីមានសមត្ថកិច្ចនៃក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ក្នុងគោលបំណងអនុវត្តប្រកាសនេះ ឱ្យមានប្រសិទ្ធភាព ។

ប្រការ៨: ក្នុងករណីរោងចក្រ ផ្អាកដំណើរការជាប់១គ្នា ក្នុងរយៈពេល១២ខែ ឬប្រព្រឹត្តល្មើសច្បាប់ ឬ ល្មើសចំពោះនឹងប្រការណាមួយដែលបានចែងខាងលើ ប្រកាសនេះនឹងត្រូវដកហូត ដោយគ្មានសំណងអ្វីឡើយ ។

ប្រការ៩: អគ្គនាយកឧស្សាហកម្ម ប្រធាននាយកដ្ឋានពាក់ព័ន្ធ ប្រធានមន្ទីរឧស្សាហកម្ម រ៉ែ និង ថាមពល ខេត្តកណ្តាល និងប្រធានក្រុមហ៊ុន នូវ ឧប ត្រូវអនុវត្តប្រកាសនេះ តាមមុខការរៀង១ខ្លួន ។

ប្រការ១០: ប្រកាសនេះមានអនុភាពគតិយុត្តិ ចាប់ពីថ្ងៃចុះហត្ថលេខា តទៅ ។

រដ្ឋមន្ត្រី

ស៊ុយ សែម

ចម្លងជូន :
-ទីស្តីការគណៈរដ្ឋមន្ត្រី
-រាជកិច្ច
-ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
-ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
-ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ
-ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់
-ក្រសួងបរិស្ថាន
-ក្រសួងពាណិជ្ជកម្ម
-សាលាខេត្តកណ្តាល
“ ដើម្បីជូនជ្រាប”
-ដូចប្រការ ៩ “ ដើម្បីអនុវត្ត”
-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King

ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល
Ministry of Industry, Mines and Energy
N° [illegible]

រាជធានីភ្នំពេញ. ថ្ងៃទី[illegible] ខែ [illegible] ឆ្នាំ២០០៥

# ប្រកាស

## រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/ រកត / ០៧០៤/ ១២៤ ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/ ០១៩៦/ ០៥ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើត ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល
- បានឃើញអនុក្រឹត្យលេខ ៣៥ អនក្រ.បក ចុះថ្ងៃទី២៦ ខែមេសា ឆ្នាំ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅរបស់ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល
- បានឃើញលិខិតលេខ ៣៨៩៤/០៥ គ.វ.ក ចុះថ្ងៃទី ២៨.១១.២០០៥ របស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- យោងពាក្យស្នើរបស់ក្រុមហ៊ុន សាងវូ (ខេមបូឌា) ចុះថ្ងៃទី ២៨.០៩.២០០៥

# សំរេច

ប្រការ១: អនុញ្ញាតឱ្យក្រុមហ៊ុន សាងវូ (ខេមបូឌា) (SANGWOO (CAMBODIA) CO., LTD.) តំណាងដោយលោក JI SOO JANG សញ្ជាតិកូរ៉េ អាយុ៤០ឆ្នាំ កាន់លិខិតឆ្លងដែនលេខ JR1814240 ចុះថ្ងៃ ទី២៤.០៨.២០០១ បង្កើតរោងចក្រ "កាត់ដេរសម្លៀកបំពាក់" ដែលមានឈ្មោះថា "សាងវូ (ខេមបូឌា) ( SANGWOO (CAMBODIA) )"មានទីតាំងស្ថិតនៅ ភូមិត្រពាំងវែង និងធ្លក ឃុំត្រពាំងគង ស្រុកសំរោងទង ខេត្តកំពង់ស្ពឺ ។

៤៥ មហាវិថីព្រះនរោត្តម ខ័ណ្ឌដូនពេញ ភ្នំពេញ ទូរស័ព្ទ : (៨៥៥) ២៣.២១១១៤១ . ទូរសារ : ៨៥៥.២៣.៤២៨២៦៣
45 Preah Norodom Boulevard, Khan Daun Penh, Phnom Penh, Phone : 855.23.211141 , Fax : 855.23.428263

ប្រការ២: ក្នុងកិច្ចដំណើរការក្រុមហ៊ុនត្រូវរៀបចំរោងចក្រទៅតាមប្លង់ ដែលបានតំកល់ទុកនៅក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ហើយក្រុមហ៊ុនត្រូវផ្តល់លិខិតអនុញ្ញាតសាងសង់មកក្រសួង ក្នុងរយៈពេល២ខែ យ៉ាងយូរ ។

ប្រការ៣: រោងចក្រនេះត្រូវបានអនុញ្ញាតឱ្យ "កាត់ដេរសម្លៀកបំពាក់" ហើយត្រូវធ្វើរបាយការណ៍ប្រចាំខែអំពីស្ថានភាព ផលិតកម្មរបស់រោងចក្រ ជូនក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ។

ប្រការ៤: ក្រុមហ៊ុនត្រូវលើកបង្ហាញ "ផ្លាកឈ្មោះរោងចក្រ " របស់ខ្លួនជាអក្សរខ្មែរមានទំហំធំជាង និងនៅពីលើអក្សរ ផ្សេងទៀត នៅកន្លែងដែលងាយមើលឃើញនៅខាងមុខរោងចក្រ ។

ប្រការ៥: ការពង្រីកផលិតកម្ម ផ្លាស់ប្តូរមុខផលិតផល ផ្លាស់ប្តូរទីតាំងរោងចក្រ ឬ បង្កើតសាខារោងចក្រ ក្រុមហ៊ុនត្រូវ សុំការអនុញ្ញាត ពីក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ។

ប្រការ៦: ក្រុមហ៊ុន ត្រូវធានាសុវត្ថិភាពឧស្សាហកម្ម និង គុណភាពផលិតផល ព្រមទាំងត្រូវគោរពឱ្យបានម៉ឺងម៉ាត់ នូវច្បាប់ និងបទប្បញ្ញត្តិនានា ដែលពាក់ព័ន្ធនឹងផលិតកម្ម អាជីវកម្ម របស់ក្រុមហ៊ុន ។

ប្រការ៧: ក្រុមហ៊ុន ត្រូវសហការជាមួយមន្ត្រីមានសមត្ថកិច្ចនៃក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ក្នុងគោលបំណងអនុវត្ត ប្រកាសនេះ ឱ្យមានប្រសិទ្ធភាព ។

ប្រការ៨: ក្នុងករណីរោងចក្រផ្អាកដំណើរការជាប់ៗគ្នាក្នុងរយៈពេល១២ខែ ឬ ប្រព្រឹត្តល្មើសច្បាប់ ឬ ល្មើសធ្ងន់ធ្ងរនឹងប្រការ ណាមួយ ដែលបានចែងខាងលើ ប្រកាសនេះនឹងត្រូវដកហូត ដោយគ្មានសំណងអ្វីឡើយ ។

ប្រការ៩: អគ្គនាយកឧស្សាហកម្ម ប្រធាននាយកដ្ឋានពាក់ព័ន្ធ ប្រធានមន្ទីរឧស្សាហកម្ម រ៉ែ និង ថាមពល ខេត្តកំពង់ស្ពឺ និងប្រធានក្រុមហ៊ុន សាងវ៉ូ (ខេមបូឌា) ត្រូវអនុវត្តប្រកាសនេះ តាមមុខការរៀងៗខ្លួន ។

ប្រការ១០: ប្រកាសនេះមានអនុភាពគតិយុត្តិ ចាប់ពីថ្ងៃចុះហត្ថលេខា តទៅ ។

រដ្ឋមន្ត្រី
ប្រតិភូរាជរដ្ឋាភិបាល (?) 

សុីធ-ប្រាំង

ចម្លងជូន :
- ទីស្តីការគណៈរដ្ឋមន្ត្រី
- រាជកិច្ច
- ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ
- ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់
- ក្រសួងបរិស្ថាន
- ក្រសួងពាណិជ្ជកម្ម
- សាលាខេត្តកំពង់ស្ពឺ

" ដើម្បីជូនជ្រាប "
- ដូចប្រការ ៩ " ដើម្បីអនុវត្ត"
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King

ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល
Ministry of Industry, Mines and Energy
Nº

រាជធានីភ្នំពេញ, ថ្ងៃទី ខែ ឆ្នាំ ២០០៥

# ប្រកាស

## រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/ រកត / ០៧០៤/ ១២៤ ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/ ០១៩៦/ ០៥ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើត ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល
- បានឃើញអនុក្រឹត្យលេខ ៣៩ អនក្រ.បក ចុះថ្ងៃទី២៦ ខែមេសា ឆ្នាំ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅរបស់ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល
- បានឃើញលិខិតលេខ ៣៨៧២/០៥ ក.អ.ក ចុះថ្ងៃទី១៨.១០.២០០៥ របស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- យោងពាក្យស្នើរបស់ក្រុមហ៊ុន វូស៊ូ ស៊ីអិនអេស (ខេមបូឌា) ចុះថ្ងៃទី១៩.០៩.២០០៥

## សំរេច

ប្រការ១: អនុញ្ញាតឱ្យក្រុមហ៊ុន វូស៊ូ ស៊ីអិនអេស (ខេមបូឌា)(WOOSU CNS (CAMBODIA) CO., LTD.) តំណាងដោយ លោក CHOI BYUNG KAB សញ្ជាតិកូរ៉េ អាយុ៤៦ឆ្នាំ កាន់លិខិតឆ្លងដែនលេខ JR2836302 ចុះថ្ងៃទី០៣.០៨.២០០៤ បង្កើតរោងចក្រ "កាត់ដេរសម្លៀកបំពាក់" ដែលមានឈ្មោះថា "វូស៊ូ ស៊ីអិនអេស (ខេមបូឌា ) (WOOSU CNS (CAMBODIA) )" មានទីតាំងស្ថិតនៅផ្លូវវ៉ែងដា ភូមិត្រពាំងរំចេក សង្កាត់ចោមចៅ ខណ្ឌដង្កោ រាជធានីភ្នំពេញ ។

៤៥ មហាវិថីព្រះនរោត្តម ខ័ណ្ឌដូនពេញ ភ្នំពេញ ទូរស័ព្ទ : (៨៥៥) ២៣.២១១១៤១ , ទូរសារ : ៨៥៥.២៣.៤២៨២៦៣
45 Preah Norodom Boulevard, Khan Daun Penh, Phnom Penh, Phone : 855.23.211141 , Fax : 855.23.428263

ប្រការ២: ក្នុងកិច្ចដំណើរការ ក្រុមហ៊ុនត្រូវរៀបចំរោងចក្រទៅតាមប្លង់ ដែលបានតំកល់ទុកនៅក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល និងត្រូវផ្តល់លិខិតអនុញ្ញាតសាងសង់រោងចក្រ មកក្រសួងក្នុងរយៈពេល២ខែ យ៉ាងយូរ ។

ប្រការ៣: រោងចក្រនេះ ត្រូវបានអនុញ្ញាតឱ្យ "កាត់ដេរសម្លៀកបំពាក់" ហើយត្រូវធ្វើរបាយការណ៍ប្រចាំខែអំពីស្ថានភាព ផលិតកម្មរបស់រោងចក្រ ជូនក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ។

ប្រការ៤: ក្រុមហ៊ុនត្រូវលើកបង្ហាញ "ផ្លាកឈ្មោះរោងចក្រ " របស់ខ្លួនជាអក្សរខ្មែរមានទំហំធំជាង និងនៅពីលើអក្សរ ផ្សេងទៀត នៅកន្លែងដែលងាយមើលឃើញនៅខាងមុខរោងចក្រ ។

ប្រការ៥: ការពង្រីកផលិតកម្ម ផ្លាស់ប្តូរមុខផលិតផល ផ្លាស់ប្តូរទីតាំងរោងចក្រ ឬ បង្កើតសាខារោងចក្រ ក្រុមហ៊ុនត្រូវ សុំការអនុញ្ញាត ពីក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ។

ប្រការ៦: ក្រុមហ៊ុន ត្រូវធានាសុវត្ថិភាពឧស្សាហកម្ម និង គុណភាពផលិតផល ព្រមទាំងត្រូវគោរពឱ្យបានម៉ឺងម៉ាត់ នូវច្បាប់ និងបទប្បញ្ញត្តិនានា ដែលពាក់ព័ន្ធនឹងផលិតកម្ម អាជីវកម្ម របស់ក្រុមហ៊ុន ។

ប្រការ៧: ក្រុមហ៊ុន ត្រូវសហការជាមួយមន្ត្រីមានសមត្ថកិច្ចនៃក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ក្នុងគោលបំណងអនុវត្ត ប្រកាសនេះ ឱ្យមានប្រសិទ្ធភាព ។

ប្រការ៨: ក្នុងករណីរោងចក្រផ្អាកដំណើរការជាប់១ឆ្នាំក្នុងរយៈពេល១២ខែ ឬ ប្រព្រឹត្តល្មើសច្បាប់ ឬ ល្មើសធ្ងន់ធ្ងរនឹងប្រការ ណាមួយ ដែលបានចែងខាងលើ ប្រកាសនេះនឹងត្រូវដកហូត ដោយគ្មានសំណងអ្វីឡើយ ។

ប្រការ៩: អគ្គនាយកឧស្សាហកម្ម ប្រធាននាយកដ្ឋានពាក់ព័ន្ធ ប្រធានមន្ទីរឧស្សាហកម្ម រ៉ែ និង ថាមពល រាជធានីភ្នំពេញ និងប្រធានក្រុមហ៊ុន វ៉ូស៊ូ ស៊ីអិនអេស (ខេមបូឌា) ត្រូវអនុវត្តប្រកាសនេះ តាមមុខការរៀង១ខ្លួន ។

ប្រការ១០: ប្រកាសនេះមានអនុភាពគតិយុត្តិ ចាប់ពីថ្ងៃចុះហត្ថលេខា តទៅ ។

រដ្ឋមន្ត្រី
ក្រសួងឧស្សាហកម្មរ៉ែនិងថាមពល

ស៊ុយ-សែម

ចម្លងជូន :
- ទីស្តីការគណៈរដ្ឋមន្ត្រី
- រាជកិច្ច
- ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ
- ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់
- ក្រសួងបរិស្ថាន
- ក្រសួងពាណិជ្ជកម្ម
- សាលាក្រុងភ្នំពេញ
  " ដើម្បីជូនជ្រាប "
- ដូចប្រការ ៩ " ដើម្បីអនុវត្ត"
- ឯកសារ-កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងការងារ និង បណ្តុះបណ្តាលវិជ្ជាជីវៈ

លេខ: ១៩៩៧ ក.ក.ប.វ

*រាជធានីភ្នំពេញ, ថ្ងៃទី០២ ខែ ធ្នូ ឆ្នាំ២០០៥*

## ប្រកាស
## ស្តីពី
## ការឈប់បុណ្យដែលត្រូវមានប្រាក់ឈ្នួល ប្រចាំឆ្នាំ២០០៦

## រដ្ឋមន្ត្រីក្រសួងការងារ និង បណ្តុះបណ្តាលវិជ្ជាជីវៈ

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រម លេខ នស/រកម/០៧០៤/០០១ ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ២០០៤ ដែលប្រកាសឱ្យប្រើច្បាប់រដ្ឋធម្មនុញ្ញ សំដៅធានាដំណើរការជាប្រក្រតីនៃស្ថាប័នជាតិ

-បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រមលេខ ជស/រកម/០៣៩៧/០១ ចុះថ្ងៃទី ១៣ ខែ មីនា ឆ្នាំ១៩៩៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការងារ

-បានឃើញអនុក្រឹត្យ លេខ ១២១ អនក្រ/បក. ចុះថ្ងៃទី ២០ ខែ តុលា ឆ្នាំ២០០៥ ស្តីពីប្រតិទិនឈប់សំរាកការងាររបស់មន្ត្រីរាជការ និយោជិត កម្មករ ប្រចាំឆ្នាំ២០០៦

## ស ម្រេ ច

**ប្រការ១.-** ថ្ងៃបុណ្យដែលត្រូវឈប់ ហើយមានប្រាក់ឈ្នួលនៅ ឆ្នាំ២០០៦ ដោយត្រូវអនុញ្ញាតឱ្យកម្មករនិយោជិត នៃសហគ្រាស គ្រឹះស្ថាន ទាំងអស់ដែលមានចែងក្នុងមាត្រា១នៃច្បាប់ស្តីពីការងារ បានឈប់សម្រាកការងារដោយមានប្រាក់ឈ្នួល តាមការកំណត់ដូចតទៅ:

-បុណ្យទិវាចូលឆ្នាំសកលចំនួនមួយថ្ងៃ គឺថ្ងៃទី០២ ខែ មករា ជំនួសថ្ងៃទី ០១ ខែ មករា ដែលចំថ្ងៃអាទិត្យ

-បុណ្យទិវាជ័យជំនះលើរបបប្រល័យពូជសាសន៍ចំនួនមួយថ្ងៃ គឺថ្ងៃទី ០៧ ខែ មករា

-បុណ្យមាឃបូជាចំនួនមួយថ្ងៃ គឺថ្ងៃទី ១៣ ខែ កុម្ភៈ

-បុណ្យទិវានារីអន្តរជាតិចំនួនមួយថ្ងៃ គឺថ្ងៃទី ០៨ ខែ មីនា

-បុណ្យចូលឆ្នាំខ្មែរប្រពៃណីជាតិចំនួនបីថ្ងៃ គឺថ្ងៃទី១៤ .១៥ និងថ្ងៃទី ១៧ ខែ មេសា ជំនួសថ្ងៃទី ១៦ ខែ មេសា ដែលចំថ្ងៃអាទិត្យ

-បុណ្យទិវាពលកម្មអន្តរជាតិចំនួនមួយថ្ងៃ គឺថ្ងៃទី ០១ ខែ ឧសភា

-បុណ្យវិសាខបូជាចំនួនមួយថ្ងៃ គឺថ្ងៃទី ១២ ខែ ឧសភា

-ព្រះរាជពិធីបុណ្យចម្រើនព្រះជន្ម ព្រះករុណាព្រះបាទសម្តេច ព្រះបរមនាថ **នរោត្តមសីហមុនី** ព្រះមហាកត្សនៃព្រះរាជាណាចក្រកម្ពុជា ចំនួនបីថ្ងៃ គឺថ្ងៃទី១៣ ១៥ និងថ្ងៃទី ១៦ ខែ ឧសភា ជំនួសថ្ងៃទី ១៤ ខែ ឧសភា ដែលចំថ្ងៃអាទិត្យ

-ព្រះរាជពិធីបុណ្យច្រត់ព្រះនង្គ័លចំនួនមួយថ្ងៃ គឺថ្ងៃទី ១៧ ខែ ឧសភា ជំនួសថ្ងៃទី ១៦ ខែ ឧសភា

-ព្រះរាជពិធីបុណ្យចំរើនព្រះជន្មសម្តេចព្រះមហាក្សត្រីព្រះវររាជមាតា **នរោត្តមមុនីនាថ សីហនុ** ចំនួនមួយថ្ងៃ គឺថ្ងៃទី ១៩ ខែ មិថុនា ជំនួសថ្ងៃទី ១៨ ខែ មិថុនា ដែលចំថ្ងៃអាទិត្យ

-បុណ្យភ្ជុំបិណ្ឌចំនួនបីថ្ងៃ គឺថ្ងៃទី ២១ ២២ និងថ្ងៃទី ២៣ ខែ កញ្ញា

-បុណ្យទិវាប្រកាសរដ្ឋធម្មនុញ្ញចំនួនមួយថ្ងៃ គឺថ្ងៃទី ២៥ ខែ កញ្ញា ជំនួសថ្ងៃទី ២៤ ខែ កញ្ញា ដែលចំថ្ងៃអាទិត្យ

-ព្រះរាជពិធីគ្រងរាជសម្បត្តិរបស់ព្រះករុណា ព្រះបាទសម្តេចបរមនាថ **នរោត្តមសីហមុនី** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ចំនួនមួយថ្ងៃ គឺថ្ងៃទី ៣០ ខែ តុលា ជំនួសថ្ងៃទី ២៩ ខែ តុលា ដែលចំថ្ងៃអាទិត្យ

-ព្រះរាជពិធីបុណ្យចំរើនព្រះជន្ម ព្រះវររាជបិតា ព្រះបាទសម្តេចព្រះ **នរោត្តមសីហនុ** ចំនួនមួយថ្ងៃ គឺថ្ងៃទី ៣១ ខែ តុលា

-ព្រះរាជពិធីបុណ្យអុំទូក បណ្តែតប្រទីប សំពះព្រះខែ និងអកអំបុក ចំនួនបីថ្ងៃ គឺថ្ងៃទី ០៤ ០៦ និងថ្ងៃទី០៧ ខែ វិច្ឆិកា ជំនួសថ្ងៃទី ០៥ ខែ វិច្ឆិកា ដែលចំថ្ងៃអាទិត្យ

-បុណ្យឯករាជ្យជាតិចំនួនមួយថ្ងៃ គឺថ្ងៃទី ០៩ ខែ វិច្ឆិកា

-បុណ្យទិវាសិទ្ធិមនុស្សអន្តរជាតិ ចំនួនមួយថ្ងៃ គឺថ្ងៃទី ១១ ខែ ធ្នូ ជំនួសថ្ងៃទី ១០ ខែ ធ្នូ ដែលចំថ្ងៃអាទិត្យ ។

**ប្រការ២.-** ក្រៅពីថ្ងៃបុណ្យដូចមានចែងក្នុងប្រការ ១ ខាងលើ តាមគោលការណ៍ដែលមានចែងក្នុងមាត្រា មាត្រា១៤៧ នៃច្បាប់ស្តីពីការងារ ត្រូវឱ្យឈប់នៅថ្ងៃអាទិត្យសំរាប់កម្មករនិយោជិត ទាំងអស់ ។

**ប្រការ៣.-** ប្រកាសរបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ លេខ ៣៣៣ ក.ក.ប.វ ចុះថ្ងៃទី ១១ ខែ មីនា ឆាំ ២០០៥ ត្រូវចាត់ទុកជានិរាករណ៍ ។

**ប្រការ៤.-** ប្រកាសនេះ មានប្រសិទ្ធិភាពអនុវត្តចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

**រដ្ឋមន្ត្រី**

**ញៀប-ប៊ុនជិន**

**ចម្លងជូន**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យ សម្តេចនាយករដ្ឋមន្ត្រី
- ទីស្តីការគណៈរដ្ឋមន្ត្រី
- គ្រប់ក្រសួងពាក់ព័ន្ធ "ដើម្បីជូនជ្រាប"
- គ្រប់មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ខេត្ត-ក្រុង "ដើម្បីផ្សព្វផ្សាយ និងអនុវត្ត"
- សមាគមនិយោជក
- សហព័ន្ធសហជីព កម្មករនិយោជិត "ដើម្បីជ្រាប និងអនុវត្ត"
- កាលប្បវត្តិ និងឯកសារ

# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

ទីស្តីការក្រសួងយុត្តិធម៌

លេខ: ០៣-កឧ-សាណន/២០០៥

ភ្នំពេញ ថ្ងៃទី ១៩ ខែ ធ្នូ ឆ្នាំ ២០០៥

## រដ្ឋមន្ត្រីក្រសួងយុត្តិធម៌

## សូមជំរាបមក

- ប្រធានតុលាការកំពូល
- អគ្គព្រះរាជអាជ្ញាអមតុលាការកំពូល
- ប្រធានសាលាឧទ្ធរណ៍
- អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍
- ប្រធានតុលាការខេត្ត-ក្រុង
- ព្រះរាជអាជ្ញាអមតុលាការខេត្ត-ក្រុង
- ប្រធានតុលាការយោធា
- ព្រះរាជអាជ្ញាអមតុលាការយោធា
- មន្ត្រីនគរបាលយុត្តិធម៌

សូមជ្រាប។

កម្មវត្ថុ: - សេចក្តីណែនាំអំពីការអនុវត្តន៍គោលការណ៍នានាក្នុងច្បាប់ជាតិ និងអន្តរជាតិដែលកំពុងនៅជាធរមាន ទាក់ទងនឹងការការពារជនរងគ្រោះ នៃបទល្មើសព្រហ្មទណ្ឌ។

យោង: - រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- ច្បាប់ស្តីពីនីតិវិធីព្រហ្មទណ្ឌ
- ច្បាប់ស្តីពីវិសោធនកម្មនៃនីតិវិធីព្រហ្មទណ្ឌ
- ច្បាប់ព្រហ្មទណ្ឌអន្តរកាល

- ច្បាប់ស្តីពីរបបសារពត៌មាន
- ច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន
- ច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់សាលាជំរះក្តី
- ច្បាប់ស្តីពីអាពាហ៍ពិពាហ៍ និងគ្រួសារ
- អនុសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ
- អនុសញ្ញាស្តីពីសិទ្ធិកុមារ
- សេចក្តីថ្លែងការណ៍របស់អង្គការសហប្រជាជាតិ ស្តីពីគោលការណ៍ជាមូលដ្ឋានសំរាប់ជនរងគ្រោះនៃបទល្មើសព្រហ្មទណ្ឌ
- សេចក្តីថ្លែងការណ៍របស់អង្គការសហប្រជាតិស្តីពីអំពើហឹង្សាប្រឆាំងលើស្ត្រី
- បទបញ្ញត្តិជាបទដ្ឋានអប្បបរិមារបស់អង្គការសហប្រជាជាតិស្តីពីវិធានការមិនឃុំខ្លួន
- គោលការណ៍ណែនាំរបស់អង្គការសហប្រជាជាតិស្តីពីតួនាទីរបស់ព្រះរាជអាជ្ញា
- ប្រកាសលេខ ២៧ ចុះថ្ងៃទី ១១ ខែ មិថុនា ឆ្នាំ ២០០៤ របស់ក្រសួងយុត្តិធម៌ ស្តីពីរបៀបរបបធ្វើការងាររបស់មន្ត្រីនគរបាលយុត្តិធម៌
- ក្បួននីតិវិធីប្រតិបត្តិការរបស់នគរបាលយុត្តិធម៌

កន្លងមក ក្រសួងយុត្តិធម៌ បានកត់សំគាល់ឃើញថា មានបទល្មើសជាច្រើនបានកើនឡើងដែលជាហេតុធ្វើឱ្យមានព្យសនកម្មលើជនរងគ្រោះគ្រប់បែបយ៉ាង ប៉ុន្តែយើងពុំទាន់បានអនុវត្តច្បាប់និងគោលការណ៍នានា សំរាប់ការពារជនរងគ្រោះនៃបទល្មើសព្រហ្មទណ្ឌនេះបានល្អនៅឡើយ ទោះបីមានគោលការណ៍ច្បាប់ បទប្បញ្ញត្តិច្បាប់ជាតិ និងអន្តរជាតិមួយចំនួនកំពុងនៅជាធរមាន ដែលរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាយើងបានទទួលស្គាល់រួចមកហើយនោះក៏ដោយ ក៏យើងមិនទាន់បានលើកយកមកអនុវត្តឱ្យបានពេញលេញនៅឡើយទេ។ ដូច្នេះ ក្រសួងយុត្តិធម៌ សូមលើកយកគោលការណ៍ច្បាប់ជាតិ និងអន្តរជាតិ ដែលមានចែងទាក់ទងនឹងការការពារជនរងគ្រោះនៃបទល្មើសព្រហ្មទណ្ឌ តាមលំដាប់លំដោយដូចខាងក្រោមនេះ ដើម្បីធ្វើការណែនាំ ក្នុងការអនុវត្តន៍គោលការណ៍ទាំងនេះ ដូចតទៅ:-

## គោលការណ៍ស្តីពីការការពារជនរងគ្រោះនៃបទល្មើសព្រហ្មទណ្ឌ

## ក ៖ គោលការណ៍ណែនាំរបស់អង្គការសហប្រជាជាតិស្តីពីតួនាទីរបស់ព្រះរាជអាជ្ញា ចំពោះជនរងគ្រោះនៃបទល្មើសព្រហ្មទណ្ឌ

ជនរងគ្រោះ គឺជាជនដែលទទួលការឈឺចាប់ ដោយអំពើបំពារបំពាន រួមមានការទទួលរងរបួសទាំងផ្លូវកាយ ឬផ្លូវចិត្ត ការឈឺចាប់ខាងអារម្មណ៍ ការខូចខាតដល់សិទ្ធិជាមូលដ្ឋាន ឬការបាត់បង់នូវសិទ្ធិសេដ្ឋកិច្ច តាមរយៈអំពើ ឬការខកខានមិនបានបំពេញកាតព្វកិច្ច ដែលឈានដល់ការរំលោភច្បាប់ព្រហ្មទណ្ឌ ។

- សេចក្តីថ្លែងការណ៍របស់អង្គការសហប្រជាជាតិស្តីពីគោលការណ៍យុត្តិធមិជាមូលដ្ឋាន សំរាប់ជនរងគ្រោះនៃបទល្មើសព្រហ្មទណ្ឌ មាត្រា ១

## ខ. គោលការណ៍ទូទៅដើម្បីអនុវត្ត និងដើម្បីពិនិត្យតាមដាន

មន្ត្រីអនុវត្តច្បាប់ រួមមាន មន្ត្រីនគរបាលយុត្តិធមិ ព្រះរាជអាជ្ញា ចៅក្រម និងក្រឡាបញ្ជី ត្រូវធានាឱ្យមានការពិនិត្យតាមដាន និងអនុវត្តនូវរាល់គោលការណ៍ដែលមាន ជាពិសេសទាក់ទងនឹងជនរងគ្រោះនៃបទល្មើសព្រហ្មទណ្ឌ ។

ជនរងគ្រោះ ត្រូវទទួលបានការយកចិត្តទុកដាក់ និងថែទាំដោយក្តីមេត្តាករុណា នឹងដោយគោរពនូវសេចក្តីថ្លៃថ្នូររបស់គេ ។

- សេចក្តីថ្លែងការណ៍របស់អង្គការសហប្រជាជាតិស្តីពីគោលការណ៍យុត្តិធមិជាមូលដ្ឋាន សំរាប់ជនរងគ្រោះនៃបទល្មើសព្រហ្មទណ្ឌ មាត្រា ៤

ជនរងគ្រោះ ត្រូវទទួលបានការជូនដំណឹងអំពីសិទ្ធិរបស់គេ ក្នុងការស្វែងរកដំណោះស្រាយតាមផ្លូវច្បាប់ទាក់ទងនឹងអំពើបំពារបំពាន និងទទួលបាននូវសេវាសុខភាព និងសង្គម ព្រមទាំងការជួយទំនុកបំរុងពាក់ពន្ធ័ដទៃទៀត ។

- សេចក្តីថ្លែងការណ៍របស់អង្គការសហប្រជាជាតិស្តីពីគោលការណ៍យុត្តិធមិជាមូលដ្ឋាន សំរាប់ជនរងគ្រោះនៃបទល្មើសព្រហ្មទណ្ឌ មាត្រា ៥ និង ១៥

ជនរងគ្រោះ ត្រូវទទួលបានការជូនដំណឹងអំពីតួនាទី វិសាលភាព ពេលវេលា និងការវិវឌ្ឍន៍នៃដំណើរការរឿងក្តី ព្រមទាំងការសម្រេចអំពីរឿងក្តី ។

- សេចក្តីថ្លែងការណ៍របស់អង្គការសហប្រជាជាតិស្តីពីគោលការណ៍យុត្តិធម៌ជាមូលដ្ឋាន សំរាប់ជនរងគ្រោះនៃបទល្មើសព្រហ្មទណ្ឌ មាត្រា ៦(ក)

ជនរងគ្រោះ អាចបញ្ចេញទស្សនៈ និងបង្ហាញអំពីការព្រួយបារម្ភរបស់ខ្លួន ព្រមទាំងឱ្យពួកគេអាចពិចារណាអំពីដំណើរការរឿងក្តីទៅតាមដំណាក់កាលសមស្រប ក្នុងករណីដែលមានការប៉ះពាល់ដល់ផលប្រយោជន៍របស់គេផ្ទាល់(ដោយគ្មានការលំអៀងទៅនឹងជនជាប់ចោទ ហើយត្រូវស្របតាមច្បាប់)។

- សេចក្តីថ្លែងការណ៍របស់អង្គការសហប្រជាជាតិស្តីពីគោលការណ៍យុត្តិធម៌ជាមូលដ្ឋាន សំរាប់ជនរងគ្រោះនៃបទល្មើសព្រហ្មទណ្ឌ មាត្រា ៦(ខ)

ជនរងគ្រោះ ត្រូវទទួលបានការជួយគាំទ្រត្រឹមត្រូវ តាមរយៈដំណើរការច្បាប់ រួមមានការជួយគាំទ្រខាងសំភារៈ ខាងការព្យាបាល ខាងសង្គម និងខាងផ្លូវចិត្ត ប្រសិនបើចាំបាច់។

- សេចក្តីថ្លែងការណ៍របស់អង្គការសហប្រជាជាតិស្តីពីគោលការណ៍យុត្តិធម៌ជាមូលដ្ឋាន សំរាប់ជនរងគ្រោះនៃបទល្មើសព្រហ្មទណ្ឌ មាត្រា ៦(គ) និង១៤

ជនរងគ្រោះ ត្រូវទទួលបានការការពារមិនឱ្យមានការរំខាន ការរំលោភសិទ្ធិឯកជន ហើយនឹងធានាឱ្យមានសុវត្ថិភាព ព្រមទាំងធានាឱ្យក្រុមគ្រួសារ និងសាក្សីរបស់គេជៀសផុតពីអំពើសងសឹក និងការបំភិតបំភ័យ។ ជនរងគ្រោះ មិនត្រូវទទួលការឈឺចាប់បន្ថែមទៀតពីអំពើអាជីវកម្ម ឬការទទួលរងគ្រោះលើកទីពីរដោយលទ្ធផលរបស់គេចូលរួមក្នុងដំណើរការព្រហ្មទណ្ឌ។

- សេចក្តីថ្លែងការណ៍របស់អង្គការសហប្រជាជាតិស្តីពីគោលការណ៍យុត្តិធម៌ជាមូលដ្ឋានសំរាប់ជនរងគ្រោះនៃបទល្មើសព្រហ្មទណ្ឌ មាត្រា ៦(ឃ)

រឿងក្តីរបស់ជនរងគ្រោះ ប្រសិនបើមិនមានការចាំបាច់ មិនត្រូវមានការពន្យារពេលដំណើការរឿងក្តីនោះឡើយ។ ប្រសិនបើមិនមានការចាំបាច់ទេ រាល់ការអនុវត្តនីបទបញ្ជាទាំងឡាយណាដែលធ្វើឡើងសំរាប់ជនរងគ្រោះ ត្រូវអនុវត្តដោយ គ្មានការបង្អង់ឡើយ។

- សេចក្តីថ្លែងការណ៍របស់អង្គការសហប្រជាជាតិស្តីពីគោលការណ៍យុត្តិធម៌ជាមូលដ្ឋានសំរាប់ជនរងគ្រោះនៃបទល្មើសព្រហ្មទណ្ឌ មាត្រា ៦(ង)

ជនរងគ្រោះ មានសិទ្ធិទទួលបាននូវសំណងសមស្រប និងប្រកបដោយយុត្តិធមិសំរាប់ខ្លួនគេផ្ទាល់ គ្រួសារ និងអ្នកស្ថិតក្នុងបន្ទុករបស់គេ រួមមានដូចជា ការប្រគល់ឱ្យវិញនូវទ្រព្យសម្បត្តិ ឬការទូទាត់សង ដោយសារអំពើបំពារបំពាន ឬការបាត់បង់អ្វីមួយ ការទូទាត់ឱ្យវិញ នូវសោហ៊ុយចំណាយដោយសារភាពរងគ្រោះរបស់ខ្លួន ផ្តល់សេវាផ្សេងៗ និងការលើកស្ទួយនូវសិទ្ធិផ្សេងៗ ។

- សេចក្តីថ្លែងការណ៍របស់អង្គការសហប្រជាជាតិស្តីពីគោលការណ៍យុត្តិធមិជាមូលដ្ឋានសំរាប់ជនរងគ្រោះនៃបទល្មើសព្រហ្មទណ្ឌ មាត្រា ៨

## គ. គោលការណ៍ជាក់លាក់ ដែលត្រូវគោរព និងអនុវត្តឱ្យបានហ្មត់ចត់

មន្ត្រីអនុវត្តច្បាប់ រួមមាន មន្ត្រីនគរបាលយុត្តិធមិ ព្រះរាជអាជ្ញា ចៅក្រម និងក្រឡាបញ្ជី ត្រូវធានាឱ្យមានការអនុវត្តន៏ឱ្យបានហ្មត់ចត់ នូវរាល់គោលការណ៍ដែលមាន ជាពិសេសទាក់ទងនឹងជនរងគ្រោះនៃបទល្មើសព្រហ្មទណ្ឌ ។

### គ.១ មន្ត្រីនគរបាលយុត្តិធមិ

ជានិច្ចកាល មន្ត្រីនគរបាលយុត្តធមិ ត្រូវចាត់វិធានការជាបន្ទាន់ ចំពោះបណ្តឹងដែលធ្វើ ឡើងដោយជនរងគ្រោះនៃបទល្មើសណាមួយ ជាពិសេស ករណីអំពើហឹង្សាខាងផ្លូវភេទ និងអំពើហឹង្សា ក្នុងគ្រួសារ ។ ម្យ៉ាងវិញទៀត មន្ត្រីនគរបាលយុត្តិធមិត្រូវចាត់វិធានការស៊ើបអង្កេតដោយហ្មត់ចត់ នឹងតាមជំនាញវិជ្ជាជីវៈ លើករណីអំពើបៀតបៀនខាងផ្លូវភេទ និងអំពើហឹង្សាក្នុងគ្រួសារ ដោយមិនគិតពីឋានៈ ជនរងគ្រោះ និងជនល្មើស និងដោយមិនគិតថា បទចោទប្រកាន់នោះប្រឆាំងនឹងមន្ត្រីសាធារណៈ មន្ត្រីយោធា ឬក៏ជនណាមួយ ហើយនិងដោយមិនគិតថា អំពើដែលទទួលការចោទប្រកាន់នោះ បានកើតឡើងនៅក្នុងផ្ទះ ក្នុងសហគមន៏ ក្នុងស្ថាប័នសាធារណៈ ឬនៅទីកន្លែងណាមួយឡើយ ។

- សេចក្តីថ្លែងការណ៍របស់អង្គការសហប្រជាជាតិស្តីពីអំពើហឹង្សាប្រឆាំងលើស្ត្រី មាត្រា ៤

មន្ត្រីនគរបាលយុត្តិធមិមិនត្រូវសួរអំពីកិច្ចការអាពាហ៍ពិពាហ៍ ឬស្នើសុំប្រយោជន៍ណាមួយពីជនរងគ្រោះឡើយ ។

មន្ត្រីនគរបាលយុត្តិធមិមិនត្រូវផ្អិបទុកសំណុំរឿងព្រហ្មទណ្ឌ ដោយមិនបានបញ្ជូនទៅព្រះរាជអាជ្ញា ដើម្បីចាត់ការតាមច្បាប់ឡើយ ទោះបីជាសំណុំរឿងព្រហ្មទណ្ឌនោះ មានការសំរុះសំរួលឯកភាពត្រូវរ៉ូវគ្នា អំពីសំណងរដ្ឋប្បវេណី រវាងជនរងគ្រោះ និងជនជាប់ចោទក៏ដោយ ។ មន្ត្រីនគរបាលយុត្តិធមិមិនត្រូវធ្វើកិច្ចសន្យាណាមួយជាមួយនឹងជនល្មើស ទាក់ទង នឹងការមិនឱ្យប្រព្រឹត្តបទល្មើសឡើងវិញនោះឡើយ ។

- ច្បាប់ស្តីពីនីតិវិធីព្រហ្មទណ្ឌ មាត្រា ៧-៣៣-៤៨
- ប្រកាសលេខ ២៧ ចុះថ្ងៃទី ១១ ខែ មិថុនា ឆ្នាំ ២០០៤ របស់ក្រសួងយុត្តិធម៌ ស្តីពីរបៀបរបបធ្វើការងាររបស់មន្ត្រីនគរបាលយុត្តធមិ

មន្ត្រីនគរបាលយុត្តិធមិ ត្រូវជូនដំណឹងដល់ជនរងគ្រោះ អំពីភាពចាំបាច់ក្នុងការផ្តល់ចម្លើយ និងភាពចាំបាច់ដែលជនរងគ្រោះត្រូវផ្តល់ភស្តុតាងឱ្យមន្ត្រីនគរបាលយុត្តិធមិ ។ មន្ត្រីនគរបាលយុត្តិធមិអាចធ្វើកំណត់ហេតុយកចម្លើយ ឬភស្តុតាងណាមួយពីជនរងគ្រោះបាន លុះត្រាណាតែលក្ខខណ្ឌខាងផ្លូវកាយ និងខាងផ្លូវចិត្តរបស់ជនរងគ្រោះអំណោយផលឱ្យធ្វើ ។

- ក្បួននីតិវិធីប្រតិបត្តិការរបស់នគរបាលយុត្តិធមិ

ក្នុងករណី ធ្វើសម្ភាសន៍ជនរងគ្រោះជាកុមារ មន្ត្រីនគរបាលយុត្តិធមិ ត្រូវអនុញ្ញាតឱ្យឪពុកម្តាយ អាណាព្យាបាល ឬជនឯករាជ្យមានវត្តមានក្នុងពេលធ្វើសម្ភាសន៍ (ប្រសិនបើ ឪពុកម្តាយ ឬ អាណាព្យាបាលនោះ មិនមែនជាជនល្មើសពាក់ព័ន្ធក្នុងរឿងក្តីនោះ ។

- ក្បួននីតិវិធីប្រតិបត្តិការរបស់នគរបាលយុត្តិធមិ

ប្រសិនបើជនរងគ្រោះ ជាកុមារដែលគ្មានអ្នកកំដរជាមួយ មន្ត្រីនគរបាលយុត្តិធមិ គប្បីចាត់វិធានការចាំបាច់ តាមការណែនាំ និងសម្របសម្រួលរបស់ព្រះរាជអាជ្ញា ដើម្បីស្វែងរកគ្រួសាររបស់កុមារ ។

ប្រសិនបើចាំបាច់ មន្ត្រីនគរបាលយុត្តិធមិ ត្រូវចាត់តាំងមន្ត្រីនគរបាលយុត្តិធមិជាស្ត្រីម្នាក់ សំរាប់ធ្វើការទំនាក់ទំនងជាមួយនឹងជនរងគ្រោះជាស្ត្រី ហើយមន្ត្រីនគរបាលយុត្តិធមិស្ត្រីរូបនោះ ត្រូវមានវត្តមានក្នុងអំឡុងពេលធ្វើការទំនាក់ទំនង ជាមួយនឹងជនរងគ្រោះ ។

- ក្បួននីតិវិធីប្រតិបត្តិការរបស់នគរបាលយុត្តិធម៌

ក្នុងករណីធ្វើសម្ភាសន៍ជនរងគ្រោះនៃអំពើរំលោភផ្លូវភេទ មន្ត្រីនគរបាលយុត្តិធម៌ ត្រូវធ្វើការជួបសម្ភាសន៍ ជាលក្ខណៈឯកជន នៅទីកន្លែងដែលមានទំនុកចិត្ត ហើយកំណត់ចំនួនមនុស្សដែលត្រូវចូលរួម។ មន្ត្រីនគរបាលយុត្តិធម៌ ត្រូវពន្យល់ឱ្យជនរងគ្រោះយល់ពីរបៀបរបប និងមូលហេតុដែលត្រូវ ធ្វើសម្ភាសន៍ ហើយធានាទទួលខុសត្រូវ ចំពោះស្ថានភាពព្រួយបារម្ភរបស់គេ។ មន្ត្រីនគរបាលយុត្តិធម៌ គួរពិចារណាអំពីសភាវគតិ របស់ជនរងគ្រោះ ទាំងផ្លូវកាយ និងផ្លូវចិត្ត។ មន្ត្រីនគរបាលយុត្តិធម៌ គួរព្យាយាមលុបបំបាត់នូវភាពអាម៉ាស់ សេចក្តីខ្មាស់អៀន ឬការបន្ទោសខ្លួនឯងរបស់ ជនរងគ្រោះ។

- ក្បួននីតិវិធីប្រតិបត្តិការរបស់នគរបាលយុត្តិធម៌

ក្នុងករណី ធ្វើសម្ភាសន៍ជនរងគ្រោះនៃអំពើរំលោភខាងផ្លូវភេទ មន្ត្រីនគរបាលយុត្តិធម៌ ដែលទទួលបន្ទុកធ្វើសម្ភាសន៍ គួរបន្តធ្វើការជាមួយនឹងអ្នកស៊ើបអង្កេតបទល្មើសផ្សេងៗទៀត ហើយត្រូវជូន ព័ត៌មាន និងគាំទ្រដល់ជនរងគ្រោះ តាមរយៈដំណើរការស៊ើបអង្កេត និងចោទប្រកាន់។

- ក្បួននីតិវិធីប្រតិបត្តិការរបស់នគរបាលយុត្តិធម៌

នៅពេលធ្វើរបាយការណ៍ ស្តីពីបទល្មើសអាជីវកម្មផ្លូវភេទលើកុមារ មន្ត្រីនគរបាលយុត្តិធម៌គួរពិនិត្យផ្ទៀងផ្ទាត់ទៅតាមនីតិវិធីនានា ដែលមានចែងក្នុងក្បួននីតិវិធីប្រតិបត្តិការរបស់នគរបាលយុត្តិធម៌ អំពីការយល់ដឹង និងការស៊ើបអង្កេតអំពើអាជីវកម្មផ្លូវភេទលើកុមារ។

មន្ត្រីនគរបាលយុត្តិធម៌ គប្បីចមួងកំណត់ហេតុយកចម្លើយមួយច្បាប់ឱ្យទៅជនរងគ្រោះ។

- ក្បួននីតិវិធីប្រតិបត្តិការរបស់នគរបាលយុត្តិធម៌

មន្ត្រីនគរបាលយុត្តិធម៌ គប្បីប្រាប់ជនរងគ្រោះអំពីលទ្ធភាពគាំទ្រដែលមាន ដូចជា ខាងសំភារៈ ខាងផ្លូវចិត្ត ខាងសង្គម និងខាងការព្យាបាល ហើយប្រសិនបើចាំបាច់ ត្រូវបញ្ជូនជនរងគ្រោះ ដែលទទួលរងការឈឺចាប់ ខាងផ្លូវកាយ ឬខាងផ្លូវចិត្ត ទៅភ្នាក់ងារសមស្របណាមួយ ដើម្បីជួយគាំទ្រ ដល់ជនរងគ្រោះ។ ដើម្បីអនុវត្តឱ្យបានល្អប្រសើរ ការិយាល័យនគរបាលយុត្តិធម៌ ឬមន្ត្រីនគរបាលយុត្តិធម៌ថ្នាក់ប៉ុស្តិ៍ គួររក្សាទុកបញ្ជី ឬអាស័យដ្ឋាន និងលេខទូរស័ព្ទរបស់ភ្នាក់ងារនានាដែលមាន សំរាប់ធ្វើការទំនាក់ទំនងនៅពេល

ដែលត្រូវការឱ្យភ្នាក់ងារនោះជួយ។ ប្រសិនបើចាំបាច់ មន្ត្រីនគរបាលយុត្តិធម៌ គប្បីរៀបចំការដឹកជញ្ជូនជនរងគ្រោះ យកទៅដាក់នៅទីកន្លែងដែលមានសុវត្ថិភាព។ ប្រសិនបើ ជនរងគ្រោះ វិលត្រលប់មកកាន់ទីកន្លែងដែលស្ថិតនៅជិតកន្លែងកើតហេតុ មន្ត្រីនគរបាលយុត្តិធម៌ ត្រូវតែធានាឱ្យទីកន្លែងនោះមានសុវត្ថិភាព ហើយប្រសិនបើចាំបាច់ ត្រូវល្បាត និងពិនិត្យអំពីសន្តិសុខនៅទីកន្លែងនោះផងដែរ។

- ក្បួននីតិវិធីប្រតិបត្តិការរបស់នគរបាលយុត្តិធម៌
- សេចក្តីថ្លែងការណ៍របស់អង្គការសហប្រជាជាតិស្តីពីគោលការណ៍យុត្តិធម៌ជាមូលដ្ឋាន សំរាប់ជនរងគ្រោះនៃបទល្មើសព្រហ្មទណ្ឌ មាត្រា ១៤ និង ១៥

នៅពេលមានករណីអំពើហិង្សាកើតឡើង ហើយក្រោយពីនីតិវិធីរដ្ឋបាល ការព្យាបាល និងនីតិវិធីដទៃទៀតត្រូវបានអនុវត្តរួចរាល់ហើយនោះ មន្ត្រីនគរបាលយុត្តិធម៌ត្រូវធានាសន្តិសុខដល់ជនរងគ្រោះ នៅពេលដែលជនរងគ្រោះវិលត្រលប់ទៅកាន់លំនៅដ្ឋានរបស់គេវិញ ដើម្បីទៅយករបស់របរ ទ្រព្យសម្បត្តិ ឬអ្នកនៅក្នុងបន្ទុករបស់គេ។ មន្ត្រីនគរបាលយុត្តិធម៌មិនត្រូវទាមទារពីជនរងគ្រោះ នូវថវិកា ឬអ្វីមួយ ដើម្បីបំរើជាផលប្រយោជន៍ដល់ខ្លួនឡើយ។ មន្ត្រីនគរបាលយុត្តិធម៌ ត្រូវធ្វើការសហការជិតស្និទ្ធជាមួយ អ្នកឯកទេសខាងការព្យាបាល មន្ត្រីសង្គមកិច្ច អង្គការផ្តល់ទីជំរក ឬអង្គការពាក់ព័ន្ធដទៃទៀត ដែលទាក់ទងនឹងជនរងគ្រោះ។

ជនរងគ្រោះ មានសិទ្ធិទទួលបាននូវសំណងនិងជម្ងឺចិត្ត។ មន្ត្រីនគរបាលយុត្តិធម៌ គួរប្រាប់ជនរងគ្រោះអំពីសិទ្ធិដាក់ពាក្យប្តឹង ទៅព្រះរាជអាជ្ញា ដើម្បីសុំឱ្យមានការដោះស្រាយសំណងនិងជម្ងឺចិត្ត។

- សេចក្តីថ្លែងការណ៍របស់អង្គការសហប្រជាជាតិស្តីពីគោលការណ៍យុត្តិធម៌ជាមូលដ្ឋានសំរាប់ជនរងគ្រោះនៃបទល្មើសព្រហ្មទណ្ឌ មាត្រា ៥
- ក្បួននីតិវិធីប្រតិបត្តិការរបស់នគរបាលយុត្តិធម៌
- ច្បាប់ស្តីពីនីតិវិធីព្រហ្មទណ្ឌ មាត្រា ៩ និង ១៤
- ច្បាប់ព្រហ្មទណ្ឌអន្តរកាល មាត្រា ២៧

មន្ត្រីនគរបាលយុត្តិធម៌ គប្បីប្រាប់ជនរងគ្រោះ អំពីសិទ្ធិត្រូវមានមេធាវី ហើយប្រសិនបើចាំបាច់ ត្រូវបញ្ជូនជនរងគ្រោះ ទៅអង្គការជំនួយផ្នែកច្បាប់ដែលឥតគិតថ្លៃ ដូចជា គណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា ឬអង្គការក្រៅរដ្ឋាភិបាលផ្សេងៗ។

មន្ត្រីនគរបាលយុត្តិធម៌ គប្បីប្រាប់ជនរងគ្រោះ អំពីសកម្មភាព ទីកន្លែង និងពេលវេលាដែលមន្ត្រីនគរបាលយុត្តិធម៌ នឹងចាត់វិធានការ។ មន្ត្រីនគរបាលយុត្តធម៌ គប្បីប្រាប់ជនរងគ្រោះ អំពីព្រឹត្តការណ៍ធម្មតាដែលអាចកើតមាន ប្រសិនបើមានការចូលរួមពីជនរងគ្រោះ នៅក្នុងចំណាត់ការផ្សេងៗនោះ។

- ក្បួននីតិវិធីប្រតិបត្តិការរបស់នគរបាលយុត្តិធម៌

មន្ត្រីនគរបាលយុត្តិធម៌ គប្បីគោរពសិទ្ធិឯកជនរបស់ជនរងគ្រោះ ហើយមិនអាចផ្សព្វផ្សាយ ឬបញ្ចេញព័ត៌មានណាមួយ ដែលកំណត់បង្ហាញអំពីជនរងគ្រោះ ដោយគ្មានការអនុញ្ញាតពីជនរងគ្រោះ អ្នករងរបួស ឬគ្រួសាររបស់ជនរងគ្រោះដែលបានមរណភាពជាមុនឡើយ ឬក៏ព័ត៌មានទាំងឡាយណាដែលជនរងគ្រោះស្នើសុំមិនឱ្យមានការផ្សព្វផ្សាយ។

- ច្បាប់ស្តីពីរបបសារពត៌មាន មាត្រា ៤-៥-១៥
- ក្បួននីតិវិធីប្រតិបត្តិការរបស់នគរបាលយុត្តិធម៌

មន្ត្រីនគរបាលយុត្តធម៌ ត្រូវប្រគល់ទ្រព្យសម្បត្តិរបស់ជនរងគ្រោះទាំងឡាយណា ដែលមិនចាំបាច់ឆ្លងកាត់ដំណើរការរឿងក្តីឱ្យទៅជនរងគ្រោះវិញ ដោយគ្រាន់តែត្រូវប្រាប់ជនរងគ្រោះ អំពីពេលវេលាដែលត្រូវយកទ្រព្យសម្បត្តិដែលជាវត្ថុតាងនោះ មកបង្ហាញចំពោះមុខតុលាការវិញ នៅពេលណាដែលតុលាការត្រូវការ។

ចំពោះការដាក់ជនរងគ្រោះឱ្យស្ថិតនៅក្រោមការថែទាំរបស់អង្គការក្រៅរដ្ឋាភិបាល ឬស្ថាប័នដទៃទៀត មន្ត្រីនគរបាលយុត្តិធម៌ ក្រោមការដឹកនាំ និងសំរបសំរួលរបស់ព្រះរាជអាជ្ញា ត្រូវធានាថាជនរងគ្រោះមានការយល់ព្រមចំពោះការដាក់នោះ បើពុំនោះសោតទេ នឹងនាំឱ្យផ្ទុយនឹងបញ្ញត្តិច្បាប់។

## គ.២ ព្រះរាជអាជ្ញា និងក្រឡាបញ្ជីអយ្យការ

រឿងក្តីដែលទាក់ទងនឹងជនរងគ្រោះនៃបទល្មើសព្រហ្មទណ្ឌ ព្រះរាជអាជ្ញា ត្រូវធានាឱ្យមន្ត្រីនគរបាលយុត្តិធម៌ ធ្វើការស៊ើបអង្កេត ស្របទៅតាមគោលការណ៍ដែលមានចែងខាងលើ។ ជាពិសេសព្រះរាជអាជ្ញា ត្រូវធានាការប្រមូលភស្តុតាងកោសលវិច័យ និងភស្តុតាងនីតិវេជ្ជសាស្ត្រ ដែលទាក់ទងនឹងអំពើរំលោភខាងផ្លូវភេទ ហើយនឹងការធ្វើសម្ភាសន៍ជាមួយសាក្សី។

ព្រះរាជអាជ្ញា និងក្រឡាបញ្ជីមិនត្រូវសួរជនរងគ្រោះ អំពីកិច្ចការអាពាហ៍ពិពាហ៍ ឬសួរអំពីអ្វីមួយដែលឆក់យកប្រយោជន៍ពីជនរងគ្រោះឡើយ។ ជាពិសេស ចំណុចនេះរួមទាំងករណីផ្តាច់សមគ្គសង្វាស ដែលសហព័ទ្ធកំពុងមានការស្វះស្វែងក្នុងការលែងលះ ជាជនរងគ្រោះនៃអំពើហឹង្សាក្នុងគ្រួសារ។

ប្រសិនបើព្រះរាជអាជ្ញា ទទួលរបាយការណ៍ថា មានមន្ត្រីនគរបាលយុត្តិធម៌ មិនបានចាត់ការរឿងក្តី ឬទទួលរឿងមកហើយផ្អើបទុកមិនបានចាត់ការ ឬមិនបានបញ្ជូនទៅព្រះរាជអាជ្ញានោះ ព្រះរាជអាជ្ញាត្រូវបញ្ជាដោយផ្ទាល់ ឬតាមរយៈឋានានុក្រមរដ្ឋបាលមន្ត្រីនគរបាលយុត្តិធម៌ ដើម្បីឱ្យមន្ត្រីនគរបាលយុត្តិធម៌មានសមត្ថកិច្ចចាត់វិធានការរឿងនោះ ស្របតាមនីតិវិធីជាបន្ទាន់។

- ច្បាប់ស្តីពីនីតិវិធីព្រហ្មទណ្ឌ មាត្រា ៧ និង៤៨
- ប្រកាសលេខ ២៧ ចុះថ្ងៃទី ១១ មិថុនា ២០០៤ របស់ក្រសួងយុត្តិធម៌ ស្តីពីរបៀបរបបធ្វើការងាររបស់មន្ត្រីនគរបាលយុត្តិធម៌ ប្រការ ១៥

ក្នុងករណីដែលមន្ត្រីនគរបាលយុត្តិធម៌ មិនព្រមអនុវត្តតាមបញ្ជា ឬសេចក្តីបង្គាប់ណាមួយ ដែលចេញដោយព្រះរាជអាជ្ញា ឬមន្ត្រីនគរបាលយុត្តិធម៌ដែលគ្រប់គ្រងមន្ត្រីប្រព្រឹត្តរំលោភនោះ ព្រះរាជអាជ្ញាអាចផ្តើមការចោទប្រកាន់ពីបទរារាំងការអនុវត្តន៍នីតិវិធីច្បាប់។

- ច្បាប់ស្តីពីនីតិវិធីព្រហ្មទណ្ឌ មាត្រា ៧ និង៤៨
- ប្រកាសលេខ ២៧ ចុះថ្ងៃទី ១១ មិថុនា ២០០៤ របស់ក្រសួងយុត្តិធម៌ ស្តីពីរបៀបរបបធ្វើការងាររបស់មន្ត្រីនគរបាលយុត្តិធម៌ ប្រការ ១៥

ព្រះរាជអាជ្ញាគប្បីប្រាប់អំពីសិទ្ធិដល់ជនរងគ្រោះ ដើម្បីឱ្យដាក់ពាក្យប្តឹងទាមទារសំណងនិងជម្ងឺចិត្ត។

- សេចក្តីថ្លែងការណ៍របស់អង្គការសហប្រជាជាតិស្តីពីគោលការណ៍យុត្តិធម៌ជាមូលដ្ឋានសំរាប់ជនរងគ្រោះនៃបទល្មើសព្រហ្មទណ្ឌ មាត្រា ៥
- ច្បាប់ស្តីពីនីតិវិធីព្រហ្មទណ្ឌ មាត្រា ៩ និង១៤
- ច្បាប់ព្រហ្មទណ្ឌអន្តរកាល មាត្រា ២៧

ព្រះរាជអាជ្ញា គប្បីប្រាប់អំពីសិទ្ធិមានមេធាវីដល់ជនរងគ្រោះ ដើម្បីឱ្យគេរកមេធាវី ហើយប្រសិនបើចាំបាច់ ត្រូវបញ្ជូនជនរងគ្រោះទៅអង្គការជំនួយផ្នែកច្បាប់ដោយមិនយកកំរៃ ដូចជា គណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា ឬអង្គការក្រៅរដ្ឋាភិបាលផ្សេងៗ ។

ការជួបសំភាសន៍ជាមួយជនរងគ្រោះ ត្រូវធ្វើឡើងដោយព្រះរាជអាជ្ញាខ្លួនឯង ដោយមិនត្រូវបើកចំហរជាសាធារណៈទេ ។

មុនពេលធ្វើសម្ភាសន៍ជាមួយជនរងគ្រោះជាអនីតិជន ព្រះរាជអាជ្ញាគប្បីជូនដំណឹងទៅឪពុកម្តាយ ឬអាណាព្យាបាល របស់ជនរងគ្រោះជាអនីតិជននោះ ដើម្បីឱ្យចូលរួមក្នុងដំណើរការសំភាសន៍ ប្រសិនបើមិនមានការប៉ះពាល់ណាមួយដល់ផលប្រយោជន៍របស់អនីតិជននោះទេ ដូចជា ឪពុកម្តាយ ឬអាណាព្យាបាលរបស់ជនរងគ្រោះជាអនីតិជននោះ ជាជនល្មើស ។

ប្រសិនបើជនរងគ្រោះ ជាកុមារដែលគ្មានអ្នកកំដរ ព្រះរាជអាជ្ញាត្រូវចាត់វិធានការចាំបាច់នានា ដើម្បីចាត់កំលាំងសាធារណៈ និងអាជ្ញាធរមូលដ្ឋាន ស្វែងរកគ្រួសាររបស់កុមារនោះ ។

ព្រះរាជអាជ្ញា គួរធ្វើសម្ភាសន៍ជាមួយជនរងគ្រោះ តាមលក្ខណៈសុជីវធម៌ និងគោរពនូវសេចក្តីថ្លៃថ្នូររបស់ជនរងគ្រោះ ។ ជនរងគ្រោះគប្បីទទួលបានការលើកទឹកចិត្តឱ្យនិយាយដោយសេរី ។ ព្រះរាជអាជ្ញាគប្បីចាត់ទុកភស្តុតាងនានា ដែលជនរងគ្រោះមានជាកត្តាសំខាន់ ហើយមិនត្រូវធ្វើឡើងក្នុងលក្ខណៈគំរាមកំហែងបំភិតបំភ័យ ឬអំពើឆ្គាំឆ្គងអ្វីឡើយ ។

ទំនាក់ទំនងរវាងព្រះរាជអាជ្ញា និងជនរងគ្រោះជាអនីតិជន គប្បីធ្វើឡើងជាភាសាដែលកុមារងាយយល់ ។ ព្រះរាជអាជ្ញា មិនត្រូវប្រើនូវសំណួរនាំមុខឡើយ គឺគប្បីប្រើនូវភាសាសាមញ្ញ ហើយសួរសំណួរឱ្យបានច្បាស់ៗ ។

ការសម្រេចផ្តើមចោទប្រកាន់ របស់ព្រះរាជអាជ្ញា ត្រូវធ្វើការពិចារណាជាចំបងទៅលើសិទ្ធិរបស់ជនរងគ្រោះ (រួមមានសិទ្ធិទទួលបានសំណងនិងជម្ងឺចិត្តរបស់ជនរងគ្រោះ) ។ ប្រសិនបើព្រះរាជអាជ្ញា សម្រេចតំកល់រឿងទុកឥតចាត់ការ ព្រះរាជអាជ្ញាត្រូវជូនដំណឹងទៅភាគីជនរងគ្រោះ អំពីសេចក្តីសម្រេចរបស់ខ្លួន ។ ក្នុងរយៈពេល ២(ពីរ)ខែ គិតពីថ្ងៃបានទទួលលិខិតជូនដំណឹង ជនរងគ្រោះមានសិទ្ធិប្តឹងឧទ្ធរណ៍ចំពោះសេចក្តីសម្រេចរបស់ព្រះរាជអាជ្ញានោះ ។

- ច្បាប់ស្តីពីនីតិវិធីព្រហ្មទណ្ឌ មាត្រា ១០ និង ៥៩

ព្រះរាជអាជ្ញា ត្រូវទទួលខុសត្រូវក្នុងការផ្តល់ដំណឹង ឱ្យជនរងគ្រោះ ឬកោះអញ្ជើញជនរងគ្រោះឱ្យ

ចូលរួមក្នុងដំណើរការស៊ើបអង្កេត ឬសវនាការ តាមការចាំបាច់របស់ខ្លួន។

ព្រះរាជអាជ្ញា គប្បីជូនដំណឹងដល់ជនរងគ្រោះ អំពីដំណើរការវិវឌ្ឍន៍នៃចំណាត់ការរឿងក្តី រួមទាំងសាលក្រម ឬសេចក្តីសម្រេចផ្សេងៗ ដើម្បីឱ្យជនរងគ្រោះ អាចអនុវត្តនូវសិទ្ធិប្តឹងឧទ្ធរណ៍របស់ខ្លួន។

ព្រះរាជអាជ្ញា ឬក្រឡាបញ្ជី មិនត្រូវអនុញ្ញាតឱ្យមានការផ្សព្វផ្សាយអំពីរឿងក្តីរបស់ជនរងគ្រោះដោយគ្មានច្បាប់អនុញ្ញាតឡើយ។

- ច្បាប់ស្តីពីរបបសារពត៌មាន មាត្រា ៤-៥-១៥
- អនុសញ្ញា ស្តីពីសិទ្ធិកុមារ មាត្រា ១៦

ព្រះរាជអាជ្ញាត្រូវទទួលខុសត្រូវឱ្យជនរងគ្រោះដែលជាកុមារ ឬជនពិការ ដើម្បីទទួលបានការការពារ និងការថែទាំខាងសុខុមាលភាពរបស់គេតាមការចាំបាច់ សំរាប់ក្នុងដំណាក់កាលនៃដំណើរការនីតិវិធីរបស់តុលាការ ហើយអាចចាត់វិធានការណាមួយក្នុងនាមជនរងគ្រោះ។ ប្រសិនបើព្រះរាជអាជ្ញាដឹងថាជនរងគ្រោះជាកុមារត្រូវការចាំបាច់សំរាប់ការការពារ និងការថែទាំនោះ ព្រះរាជអាជ្ញាគប្បីចាត់វិធានការតាមការចាំបាច់ ដើម្បីផ្តល់ការថែទាំ និងការការពារ មានជាអាទិ៍:

- បញ្ជូនទៅភ្នាក់ងារជួយសង្គ្រោះជនរងគ្រោះ
- ចាត់វិធានការការពារជនរងគ្រោះឱ្យជៀសផុតពីអំពើញៀនថ្នាំញៀន ស្របតាមជំពូក XXIV នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ឬ
- ប្តឹងទៅតុលាការតាមមាត្រា ១១៩ និង ១២០ នៃច្បាប់ស្តីពីអាពាហ៍ពិពាហ៍ និងគ្រួសារ
    - អនុសញ្ញាស្តីពីសិទ្ធិកុមារ មាត្រា ៣.២ និង ៣៩
    - ច្បាប់ស្តីពីនីតិវិធីព្រហ្មទណ្ឌ មាត្រា ៥៤
    - ច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ របស់សាលាជំរះក្តី មាត្រា ៥

ព្រះរាជអាជ្ញា ត្រូវធានាថាការដាក់ជនរងគ្រោះឱ្យស្ថិតនៅក្រោមការថែទាំរបស់ អង្គការក្រៅរដ្ឋាភិបាល ឬស្ថាប័នដ៏ទៃទៀត ត្រូវតែមានការឯកភាពជាមុនពីសាមីខ្លួនផងដែរ បើពុំនោះសោតទេនឹងនាំអោយផ្ទុយនឹងបញ្ញត្តិច្បាប់។

ព្រះរាជអាជ្ញា ឬក្រឡាបញ្ជីរបស់ព្រះរាជអាជ្ញា មិនអាចធ្វើការសម្រុះសម្រួល សម្របសម្រួល ឬរៀបចំអ្វីផ្សេងៗ ចំពោះរឿងព្រហ្មទណ្ឌក្រៅពីច្បាប់កំណត់បានឡើយ។ តុលាការមិនត្រូវឱ្យជនរងគ្រោះ ចេញ

ការចំណាយផ្សេងៗបានឡើយ លើកលែងតែពន្ធជាផ្លូវការតែប៉ុណ្ណោះ ។ ការរំលោភលើគោលការណ៍ ទាំងនេះ នឹងត្រូវដាក់វិន័យរដ្ឋបាល ឬផ្តន្ទាទោសដាក់គុកពី ៦ ថ្ងៃ ដល់ មួយខែ ។

- ច្បាប់ស្តីពីនីតិវិធីព្រហ្មទណ្ឌ មាត្រា ៧

## គ.៣ ចៅក្រមស៊ើបអង្កេត និងក្រឡាបញ្ជីរបស់ចៅក្រមស៊ើបអង្កេត

រឿងក្តីដែលមានជនរងគ្រោះ ត្រូវចាត់ការជាអាទិភាពបំផុត ។

ចៅក្រមស៊ើបអង្កេត និងក្រឡាបញ្ជី មិនអាចស្នើសុំជាសម្ភារៈ ឬជាប្រយោជន៍អ្វីមួយពីជនរងគ្រោះបានឡើយ ។

បណ្តឹងអាជ្ញាមិនអាចសំរុះសំរួលបានដោយកិច្ចការណាមួយឡើយ ទោះជាជនរងគ្រោះ ឬដើមបណ្តឹងរដ្ឋប្បវេណីលះបង់បណ្តឹងរដ្ឋប្បវេណីរបស់ខ្លួនក៏ដោយ ក៏ចៅក្រមស៊ើបអង្កេតមិនអាចបញ្ឈប់ ឬផ្អាកដំណើរការស៊ើបអង្កេតនៃបណ្តឹងអាជ្ញាបានឡើយ ។

- ច្បាប់ស្តីពីនីតិវិធីព្រហ្មទណ្ឌ មាត្រា ៧ និង ៣៣

ចំពោះរឿងក្តីដែលជនរងគ្រោះជាកុមារ ឬជាបទល្មើសផ្លូវភេទ ប្រធានតុលាការគប្បីពិចារណាចាត់តាំងចៅក្រមដែលមានភេទដូចគ្នានឹងជនរងគ្រោះ ឬចៅក្រមដែលមានឯកទេស ឬបទពិសោធន៍ខាងរឿងក្តីនោះ ។

ប្រសិនបើជនរងគ្រោះ មិនទាន់បានរៀបចំបណ្តឹងទាមទារសំណងនិងជម្ងឺចិត្តនោះ ចៅក្រមស៊ើបអង្កេត គប្បីជូនព័ត៌មាននេះទៅជនរងគ្រោះ អំពីសិទ្ធិទទួលបានសំណងនិងជម្ងឺចិត្តនេះ ។

- សេចក្តីថ្លែងការណ៍របស់អង្គការសហប្រជាជាតិស្តីពីគោលការណ៍យុត្តិធម៌ជាមូលដ្ឋានសំរាប់ជនរងគ្រោះនៃបទល្មើសព្រហ្មទណ្ឌ មាត្រា ៥
- ច្បាប់ស្តីពីនីតិវិធីព្រហ្មទណ្ឌ មាត្រា ៩ និង ១៤
- ច្បាប់ព្រហ្មទណ្ឌអន្តរកាល មាត្រា ២៧

ប្រសិនបើជនរងគ្រោះមិនទាន់មានមេធាវី ចៅក្រមស៊ើបអង្កេតត្រូវប្រាប់ជនរងគ្រោះ អំពីសិទ្ធិត្រូវមានមេធាវី ។ ប្រធានតុលាការត្រូវចាត់តាំងមេធាវីដោយឯកឯង សំរាប់ជនរងគ្រោះជាអនីតិជនគ្មានទីពឹង ។

- ច្បាប់ស្តីពីនីតិវិធីព្រហ្មទណ្ឌ មាត្រា ៧៦

ដើម្បីសម្រេចដោះលែងជនជាប់ចោទឱ្យមានសេរីភាព ឬដាក់ឱ្យនៅក្រៅឃុំ ចៅក្រមស៊ើបអង្កេតត្រូវពិចារណា និងយកចិត្តទុកដាក់អំពីការការពារដល់ជនរងគ្រោះ។

- វិធានបទដ្ឋានអប្បបរិមា របស់អង្គការសហប្រជាជាតិ សំរាប់វិធានការដោះលែង មាត្រា ៦

កាលណាមានពាក្យបណ្តឹងរបស់ដើមបណ្តឹងរដ្ឋប្បវេណី ដែលបានប្តឹងសុំអោយឃុំខ្លួនជនជាប់ចោទដែលនៅក្រៅឃុំនោះ ចៅក្រមស៊ើបអង្កេតត្រូវសម្រេចអំពីបញ្ហានេះក្នុងរយៈពេល ៥ថ្ងៃ ហើយជូនដំណឹងទៅម្ចាស់បណ្តឹងវិញអំពីសេចក្តីសម្រេចរបស់ខ្លួន។

- ច្បាប់ស្តីពីនីតិវិធីព្រហ្មទណ្ឌ មាត្រា ៩៥

កាលណាភាគីជនរងគ្រោះប្តឹងសុំអោយឃុំខ្លួនជនជាប់ចោទដែលនៅក្រៅឃុំ ប៉ុន្តែចៅក្រមស៊ើបអង្កេតសម្រេចមិនឃុំខ្លួនជនជាប់ចោទនោះ ជនរងគ្រោះមានសិទ្ធិប្តឹងតវ៉ាទៅសាលាឧទ្ធរណ៍ក្នុងរយៈពេល ១៥ ថ្ងៃ គិតពីថ្ងៃទទួលដំណឹង។

- ច្បាប់ស្តីពីនីតិវិធីព្រហ្មទណ្ឌ មាត្រា ៧៩ និង ៩៥

ព្រះរាជអាជ្ញា ត្រូវចាត់ទុកជាចំបងចំពោះផលប្រយោជន៍របស់ជនរងគ្រោះជាអនីតិជន នៅពេលសម្រេចប្តឹង ឬមិនប្តឹងឧទ្ធរណ៍លើដីកាសម្រេចមិនឃុំខ្លួន (ដាក់ឱ្យនៅក្រៅឃុំ) ឬដីកាសម្រេចអនុញ្ញាតឱ្យនៅក្រៅឃុំបណ្តោះអាសន្នរបស់ចៅក្រមស៊ើបអង្កេត។

- ច្បាប់ស្តីពីនីតិវិធីព្រហ្មទណ្ឌ មាត្រា ៧៩
- អនុសញ្ញាស្តីពី សិទ្ធិកុមារ មាត្រា ៣

ការធ្វើសម្ភាសន៍ជនរងគ្រោះ ត្រូវធ្វើឡើងជាសំងាត់។ ចៅក្រមស៊ើបអង្កេត ត្រូវធ្វើការសាកសួរ (សម្ភាសន៍) ដោយខ្លួនឯងផ្ទាល់ ដោយមានក្រឡាបញ្ជីជាអ្នកធ្វើកំណត់ហេតុអមផង។

- ច្បាប់ស្តីពីនីតិវិធីព្រហ្មទណ្ឌ មាត្រា ៨១ និង ៨៦

ការទំនាក់ទំនងនានាក្នុងដំណើរការសាកសួរ(សម្ភាសន៍) ជនរងគ្រោះជាកុមារ ត្រូវធ្វើឡើងក្នុងកំរិតដែលកុមារងាយយល់។

ចៅក្រមស៊ើបអង្កេត អាចដាក់ឱ្យសួរដេញដោលតទល់គ្នា រវាងជនជាប់ចោទ និងជនរងគ្រោះ សំរាប់តែក្នុងករណីចាំបាច់ និងខានពុំបានតែប៉ុណ្ណោះ ជាពិសេសបទល្មើសរំលោភសេពសន្ថវៈ ឬបទល្មើសផ្លូវភេទដទៃទៀត។ ប្រសិនបើជនរងគ្រោះជាកុមារ ចៅក្រមស៊ើបអង្កេត មិនគប្បីដាក់ឱ្យសួរតទល់រវាង អនីតិជន និងជនជាប់ចោទឡើយ ប្រសិនបើមានការប៉ះពាល់ដល់ផលប្រយោជន៍ល្អបំផុតរបស់អនីតិជន។

- ច្បាប់ស្តីពីនីតិវិធីព្រហ្មទណ្ឌ មាត្រា ៨១ និង ៨២
- អនុសញ្ញាស្តីពីសិទ្ធិកុមារ មាត្រា ៣

តុលាការ គប្បីពិចារណាទៅលើរបាយការណ៍ណាមួយដែលអាចយកជាការបាន នូវរាល់របាយការណ៍ទាំងឡាយដែលបានផ្តល់ដោយភ្នាក់ងារផ្សេងៗ ដូចជា ភ្នាក់ងារគាំទ្រដល់ជនរងគ្រោះ ភ្នាក់ងារសង្គមកិច្ច ដែលទទួលបានពីជនរងគ្រោះផ្ទាល់ ឬពីមេធាវីរបស់ជនរងគ្រោះ។

ជនរងគ្រោះ និងអ្នកដទៃទៀតដែលបំពេញការងារក្នុងនាមជនរងគ្រោះ ដូចជា ក្រុមគ្រួសារ បងប្អូន និងសាក្សី ត្រូវទទួលបានការការពារសន្តិសុខសមស្រប នៅមុនពេល ក្នុងពេល និងក្រោយពេលនៃនីតិវិធីតុលាការ។

ជនរងគ្រោះ ដែលរង់ចាំការសាកសួរ(សម្ភាសន៍) ពីចៅក្រមស៊ើបអង្កេត គប្បីដាក់ឱ្យស្ថិតនៅកន្លែងរង់ចាំដាច់ដោយឡែកពីជនជាប់ចោទ។

ប្រសិនបើចៅក្រមស៊ើបអង្កេត ចេញដីកាសម្រេចលើកលែងចោទប្រកាន់ដល់ជនជាប់ចោទ ភាគីជនរងគ្រោះ ត្រូវទទួលបានការឱ្យដំណឹងមិនលើសពី ៧ ថ្ងៃ ចាប់ពីថ្ងៃចេញដីកានេះ។

- ច្បាប់ស្តីពីវិសោធនកម្មនៃនីតិវិធីព្រហ្មទណ្ឌ មាត្រា ៩០

ក្នុងករណីដែលភាគីជនរងគ្រោះ មិនសុខចិត្តនឹងដីកាសម្រេចលើកលែងចោទប្រកាន់របស់ចៅក្រមស៊ើបអង្កេតទេនោះ ភាគីជនរងគ្រោះមានសិទ្ធធ្វើពាក្យប្តឹងតវ៉ាទៅសាលាឧទ្ធរណ៍ ឬទៅរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ដោយផ្ទាល់ ឬតាមរយៈមេធាវីចាប់ពីថ្ងៃបានទទួលដំណឹង ។

- ច្បាប់ស្តីពីវិសោធនកម្មនៃនីតិវិធីព្រហ្មទណ្ឌ មាត្រា ៩០ និង ៩១

ព្រះរាជអាជ្ញាត្រូវចាត់ទុកជាចំបងចំពោះផលប្រយោជន៍របស់ជនរងគ្រោះជាអនីតិជន នៅពេលសម្រេចប្តឹង ឬមិនប្តឹងឧទ្ធរណ៍លើដីកាសម្រេចលើកលែងចោទប្រកាន់របស់ចៅក្រមស៊ើបអង្កេត។

ភាគីជនរងគ្រោះអាចមើលសំណុំរឿងរបស់ខ្លួននៅការិយាល័យក្រឡាបញ្ជី ហើយមានសិទ្ធិពិនិត្យសំណុំរឿងរបស់ខ្លួន ដូចជនជាប់ចោទដែរ ។

- ច្បាប់ស្តីពីនីតិវិធីព្រហ្មទណ្ឌ មាត្រា ១១០
- ច្បាប់ព្រហ្មទណ្ឌអន្តរកាល មាត្រា ២៧ កថាខណ្ឌ ១

ចៅក្រមស៊ើបអង្កេតមិនត្រូវអនុញ្ញាតឱ្យមានការផ្សព្វផ្សាយរឿងក្តីរបស់ជនរងគ្រោះ ដោយពុំមានច្បាប់អនុញ្ញាតឡើយ ។

- ច្បាប់សារព័ត៌មាន មាត្រា ៤ - ៥ - ១៥
- អនុសញ្ញាស្តីពីសិទ្ធិកុមារ មាត្រា ១៦

ប្រសិនបើមានដើមបណ្តឹងរដ្ឋប្បវេណី ដីកាសម្រេចលើកលែងចោទប្រកាន់ ដែលមានការឯកភាពពីព្រះរាជអាជ្ញាផងនោះ ចៅក្រមស៊ើបអង្កេតត្រូវជូនដំណឹងដល់ភាគីដើមបណ្តឹង ។ ក្នុងរយៈពេល៦០ថ្ងៃ គិតពីថ្ងៃទទួលដំណឹង ភាគីរដ្ឋប្បវេណីមានសិទ្ធិប្តឹងតវ៉ាទៅសាលាឧទ្ធរណ៍ ។

- ច្បាប់ស្តីពីវិសោធនកម្មនៃនីតិវិធីព្រហ្មទណ្ឌ មាត្រា ៩១

## គ.៤ ចៅក្រមជំនុំជម្រះ និងក្រឡាបញ្ជីរបស់ចៅក្រមជំនុំជម្រះ

ចំពោះរឿងក្តី ដែលជនរងគ្រោះជាកុមារ ឬជាបទល្មើសផ្លូវភេទ ប្រធានតុលាការគប្បីពិចារណាចាត់តាំងចៅក្រមដែលមានភេទដូចគ្នានឹងជនរងគ្រោះ ឬចៅក្រមដែលមានឯកទេស ឬបទពិសោធន៍ខាងរឿងក្តីនោះ ។

ជនរងគ្រោះត្រូវទទួលបានការជូនដំណឹងអំពីកាលបរិច្ឆេទបើកសវនាការរបស់ខ្លួន តាមពេលវេលាសមស្រប ។

ភាគីជនរងគ្រោះអាចមើលសំណុំរឿងរបស់ខ្លួននៅការិយាល័យក្រឡាបញ្ជី ហើយមានសិទ្ធិពិនិត្យសំណុំរឿងរបស់ខ្លួន ដូចជនជាប់ចោទដែរ ។

- ច្បាប់ស្តីពីនីតិវិធីព្រហ្មទណ្ឌ មាត្រា ១១០
- ច្បាប់ព្រហ្មទណ្ឌអន្តរកាល មាត្រា ២៧

ជនរងគ្រោះត្រូវទទួលបានការការពារសន្តិសុខសមស្រប ។ ចៅក្រមជំនុំជម្រះ ព្រះរាជអាជ្ញា និង ក្រឡាបញ្ជីសវនាការ ត្រូវពិចារណាអំពីសុវត្ថិភាព របស់ជនរងគ្រោះ សាក្សី ភាគីដែលចូលរួមក្នុងសវនាការ ។

ជនរងគ្រោះត្រូវដាក់ឱ្យស្ថិតនៅកន្លែងដាច់ដោយឡែកពីជនជាប់ចោទ ។ ការការពារសន្តិសុខ ចាំបាច់ ត្រូវយកចិត្តទុកដាក់សំរាប់ជនរងគ្រោះ នៅមុនពេល ក្នុងពេល និងក្រោយពេលដំណើរការនីតិវិធីរបស់ តុលាការ ។

ជនរងគ្រោះមានសិទ្ធិរកអ្នកបកប្រែភាសា ។

ជនរងគ្រោះមានសិទ្ធិប្តឹងជំទាស់ចៅក្រមជំនុំជម្រះឱ្យដកខ្លួនចេញពីរឿងក្តីរបស់ខ្លួន បើយល់ ឃើញថា ចៅក្រមនោះពុំអាចរកយុត្តិធម៌ឱ្យខ្លួនបានទេ ហើយស្នើសុំឱ្យប្រធានតុលាការចាត់តាំងចៅក្រមថ្មី មកជំនួសបាន ។

- ច្បាប់ស្តីពីនីតិវិធីជំនុំជម្រះផ្នែកព្រហ្មទណ្ឌ (១៩៨៩) មាត្រា ១០ និង ៣៤

ជនរងគ្រោះមានសិទ្ធិរកមេធាវីឱ្យការពារខ្លួន ។ ប្រសិនបើជនរងគ្រោះ មិនទាន់មានមេធាវីការពារ ខ្លួន ចៅក្រមត្រូវប្រាប់ជនរងគ្រោះ អំពីសិទ្ធិត្រូវមានមេធាវីការពារ ។ ចំពោះជនរងគ្រោះជាអនីតិជនគ្មានទី ពឹង ប្រធានតុលាការត្រូវខិតខំឱ្យអស់ពីលទ្ធភាព ដើម្បីចាត់តាំងមេធាវីជូនជនរងគ្រោះ ។

- ច្បាប់ស្តីពីនីតិវិធីព្រហ្មទណ្ឌ មាត្រា ៧៦ និង ១០៩

ប្រសិនបើជនរងគ្រោះជាអនីតិជន ឪពុកម្តាយ អាណាព្យាបាល មេធាវីរបស់អនីតិជន មានសិទ្ធិ ចូលរួមគ្រប់ដំណាក់កាលនៃនីតិវិធីដំណើរការរឿងក្តី ប្រសិនបើគ្មានការប៉ះពាល់ដល់ផលប្រយោជន៍របស់ អនីតិជនទេ ។

- អនុសញ្ញាស្តីពីសិទ្ធិកុមារ មាត្រា ៤០.២(ខ)(៣)

ប្រសិនបើជនរងគ្រោះមិនទាន់បានទាមទារសំណងនិងជម្ងឺចិត្តនៅឡើយទេនោះ ចៅក្រមជំនុំជម្រះ គប្បីប្រាប់ជនរងគ្រោះអំពីសិទ្ធិទទួលបានសំណងនិងជម្ងឺចិត្តនេះ ។

- សេចក្តីថ្លែងការណ៍ស្តីពីសិទ្ធិជាមូលដ្ឋាន របស់ជនរងគ្រោះ មាត្រា ៥
- ច្បាប់ស្តីពីនីតិវិធីព្រហ្មទណ្ឌ មាត្រា ៩- ១៤ និង ១៣១

- ច្បាប់ព្រហ្មទណ្ឌអន្តរកាល មាត្រា ២៧

ចៅក្រមជំនុំជម្រះគប្បីប្រាប់ជនរងគ្រោះ អំពីសិទ្ធិសួរសំណួរផ្សេងៗ ទៅជនជាប់ចោទ និងសាក្សី សិទ្ធិជំទាស់ សិទ្ធិបង្ហាញភស្តុតាង និងសិទ្ធិជូនសម្តីចុងក្រោយដល់តុលាការ ។

- ច្បាប់ស្តីពីនីតិវិធីព្រហ្មទណ្ឌ មាត្រា ១៣០- ១៣២- ១៣៣- ១៣៧- ១៣៩
- ច្បាប់ស្តីពីស្ថានទម្ងន់ទោស មាត្រា ២

ការបើកសវនាការរឿងក្តីទាក់ទងនឹងជនរងគ្រោះជាអនីតិជន ឬជនរងគ្រោះក្នុងបទល្មើសផ្លូវភេទ អាចធ្វើឡើងជាសំងាត់ ដោយគោរពទៅតាមផលប្រយោជន៍ សេចក្តីថ្លៃថ្នូរ និងភាពជាឯកជនរបស់អនីតិជន ដែលជាជនរងគ្រោះប្រសិនបើចាំបាច់ ។

- ច្បាប់ស្តីពីនីតិវិធីព្រហ្មទណ្ឌ មាត្រា ១២៩
- ច្បាប់ព្រហ្មទណ្ឌអន្តរកាល មាត្រា ២៣
- អនុសញ្ញាស្តីពីសិទ្ធិកុមារ មាត្រា ៣
- កតិកាសញ្ញាស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ មាត្រា ១៤

ចៅក្រមជំនុំជម្រះត្រូវធានាដល់សុវត្ថិភាពរបស់ជនរងគ្រោះ ។ នៅពេលមានវត្តមានរបស់ជនរងគ្រោះក្នុងពេលសវនាការ ចៅក្រមជំនុំជម្រះត្រូវធ្វើយ៉ាងណាកុំឱ្យជនរងគ្រោះទទួលរងគ្រោះជាលើកទីពីរបាន ។

តុលាការគប្បីខិតខំធ្វើយ៉ាងណាបង្កើតឱ្យមានបរិយាកាសទុកចិត្តគ្នា ដើម្បីឱ្យទទួលបាននូវភស្តុតាង ( ក្នុងភាពជាឯកជន សុវត្ថិភាព ទំនុកចិត្ត សិទ្ធស្នាល អត់ធ្មត់ និងហ្មត់ចត់) ។

មិនត្រូវអនុញ្ញាតឱ្យជនរងគ្រោះអង្គុយក្បែរជនជាប់ចោទឡើយ ។ ជនរងគ្រោះគប្បីឱ្យអង្គុយនៅទីតាំងក្បែរមេធាវី និងអ្នកគាំទ្ររបស់គេ ។

ជនរងគ្រោះមិនចាំបាច់រង់ចាំរហូតដល់ពេលសវនាការបញ្ចប់នោះទេ ។

ជនរងគ្រោះអាចផ្តល់សក្ខីកម្មតាមមធ្យោបាយសមស្របណាមួយ ស្របតាមគោលការណ៍ច្បាប់ ។ វិធីសាស្ត្រក្នុងការផ្តល់ភស្តុតាងតាមជំរើសផ្សេងៗ គួរផ្តល់ឱកាសឱ្យជនរងគ្រោះ ។ ឧទាហរណ៍ តាមរយៈ

កាសែតវីដេអូ សំភាសន៍នៅទីកន្លែងដោយឡែក បង្ហាញសក្ខីកម្មមុនពេលសវនាការ ហើយបន្ទាប់មកកំណត់ហេតុយកចម្លើយនោះ ត្រូវអានជាសាធារណៈក្នុងសវនាការ ... ។ល។

ការសាកសួរ(សម្ភាសន៍) ជនរងគ្រោះគប្បីធ្វើឡើងក្នុងលក្ខណៈសមស្រប ដូចជា:-

- ហាមប្រើប្រាស់សំណួរនាំមុខ
- មិនត្រូវធ្វើតាមរបៀបសួរចម្លើយ
- លើកទឹកចិត្តឱ្យនិយាយដោយសេរី
- ប្រើប្រាស់ពាក្យពេចន៍សាមញ្ញ ហើយសួរសំណួរឱ្យបានច្បាស់ៗ
- សួរសំណួរដោយឈរលើភាពអព្យាក្រិត្យ មិនត្រូវប្រើប្រាស់ពាក្យពេចន៍អសុរោះ បំភិតបំភ័យ ឬគំរាមកំហែងឡើយ
- យកភស្តុតាងជាសំខាន់ មិនត្រូវប្រើប្រាស់ពាក្យចំអកឡកឡឺយ លេងសើច ហើយចាត់ថាពាក្យបណ្តឹងនោះ មានសុពលភាពដាច់ខាតនោះទេ
- ព្យាយាមយល់ឱ្យបានច្បាស់អំពីស្ថានភាពរបស់ជនរងគ្រោះ

តុលាការត្រូវធានាថា កុមារដែលជាជនរងគ្រោះនៃបទល្មើសព្រហ្មទណ្ឌ និងកុមារដែលមានសមត្ថភាពបង្កើតទស្សនៈផ្ទាល់ខ្លួន បានបញ្ចេញនូវសិទ្ធិ និងទស្សនៈផ្សេងៗដោយសេរី លើគ្រប់បញ្ហាពាក់ព័ន្ធនឹងកុមារ ។ ទស្សនៈទាំងនេះរបស់កុមារ ត្រូវបានយកទៅពិចារណាថ្លឹងថ្លែង ដោយគិតទៅតាមវ័យ និងភាពចាស់ទុំរបស់កុមារ ។

- កតិការសញ្ញាអន្តរជាតិស្តីពីសិទ្ធិកុមារ មាត្រា ១២

ការទំនាក់ទំនងនានារវាង ចៅក្រមជំនុំជម្រះ និងជនរងគ្រោះជាអនីតិជន ត្រូវធ្វើឡើងក្នុងក៏រិតដែលអនីតិជនងាយយល់ ហើយទំនាក់ទំនងជាមួយជនរងគ្រោះដ៏ទៃទៀត ត្រូវពិចារណាអំពីសេចក្តីថ្លៃថ្នូររបស់គេ។ ចៅក្រមជំនុំជម្រះត្រូវធានាថា អ្នកចូលរួមដ៏ទៃទៀត រួមមាន ព្រះរាជអាជ្ញា មេធាវី និងជនជាប់ចោទត្រូវធ្វើឡើងដោយមានការគោរពនូវសេចក្តីថ្លៃថ្នូរ ។

តុលាការគប្បីពិចារណាទៅលើរបាយការណ៍ ឬភស្តុតាងណាមួយដែលអាចយកជាការបាន ដែលជារបាយការណ៍ ឬភស្តុតាង ដែលបានផ្តល់ឱ្យដោយភ្នាក់ងារផ្សេងៗ ដូចជា ភ្នាក់ងារគាំទ្រដល់ ជនរងគ្រោះ ភ្នាក់ងារសង្គមកិច្ចដែលទទួលបានពី ជនរងគ្រោះផ្ទាល់ ឬពីមេធាវីរបស់ជនរងគ្រោះ ។

ការសម្រេចផ្ដន្ទាទោសជនជាប់ចោទ ចៅក្រមជំនុំជម្រះត្រូវពិចារណាអំពីផលប៉ះពាល់នានាទៅលើជនរងគ្រោះ។

ចៅក្រមជំនុំជម្រះត្រូវសម្រេចអំពីសំណងនានា ដោយផ្អែកទៅតាមព្យសនកម្មដែលកើតមាន ហើយអាចផ្អាកការវាយតំលៃទៅលើចំនួនសំណង តែក្នុងករណីដែលចំនួនសំណងនោះ មិនអាចធ្វើការវាយតំលៃបានទាន់ពេលវេលាប៉ុណ្ណោះ។

- ច្បាប់ស្ដីពីនីតិវិធីព្រហ្មទណ្ឌ មាត្រា ៥- ១៩- ១៤៩- ១៥១

តុលាការអាចសម្រេចផ្ដល់សំណងនិងជម្ងឺចិត្តបាន ទោះជាអវត្តមានជនរងគ្រោះដែលមិនបានចូលរួមសវនាការក៏ដោយ (ប្រសិនបើមានការទាមទារពីជនរងគ្រោះរួចហើយ)។

- ច្បាប់ស្ដីពីនីតិវិធីព្រហ្មទណ្ឌ មាត្រា ១១៣

ចៅក្រមជំនុំជម្រះគប្បីប្រាប់ជនរងគ្រោះអំពីសិទ្ធិប្ដឹងឧទ្ធរណ៍

- ច្បាប់ស្ដីពីនីតិវិធីព្រហ្មទណ្ឌ មាត្រា ១៥៥- ១៦១ និង ១៦២
- ច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់សាលាជំរះក្ដី មាត្រា ៧ និង ៨
- ច្បាប់ព្រហ្មទណ្ឌអន្តរកាល មាត្រា ៤

សាលក្រមចម្លង(សេចក្ដីចម្លងសាលក្រម) ត្រូវផ្ដល់ឱ្យភាគីជនរងគ្រោះ តាមការស្នើរសុំ។

- ច្បាប់ព្រហ្មទណ្ឌអន្តរកាល មាត្រា ២៦ កថាខ័ណ្ឌ ២

តុលាការត្រូវរក្សាការសម្ងាត់នូវរាល់ភស្តុតាងនានាដែលទាក់ទងនឹងជនរងគ្រោះ។ តុលាការត្រូវពិចារណាជាចំបងអំពីផលប្រយោជន៍របស់ជនរងគ្រោះ ទាក់ទងនឹងភាពជាឯកជន កិត្តិយស និងកិត្តិសព្ទ មុនពេលអនុញ្ញាតឱ្យផ្សព្វផ្សាយនូវរឿងក្ដីរបស់ជនរងគ្រោះ ជាពិសេស រឿងក្ដីដែលជនរងគ្រោះមានអាយុក្រោម ១៨ ឆ្នាំ ឬ ជនរងគ្រោះជាស្ត្រី ដែលទទួលការរំលោភទាក់ទងនឹងបទល្មើសផ្លូវភេទ។

- ច្បាប់ស្ដីពីរបបសារព័ត៌មាន មាត្រា ៤- ៥ និង ១៥
- អនុសញ្ញាស្ដីពីសិទ្ធិកុមារ មាត្រា ១៦

ឯកសារតុលាការទាក់ទងនឹងជនរងគ្រោះនៃបទល្មើសព្រហ្មទណ្ឌ ត្រូវរក្សាទុកជាកិច្ចការសម្ងាត់ ។

- ច្បាប់ស្តីពីរបបសារព័ត៌មាន មាត្រា ៤- ៥ និង ១៥
- អនុសញ្ញាស្តីពីសិទ្ធិកុមារ មាត្រា ១៦

ការខកខានមិនបានរក្សាការសម្ងាត់ ចៅក្រមជំនុំជម្រះ ត្រូវរាយការណ៍ទៅអាជ្ញាធរមានសមត្ថកិច្ច ដើម្បីចាត់វិធានការតាមច្បាប់ ដូចជា រាយការណ៍ទៅមន្ត្រីនគរបាលយុត្តិធម៌ថ្នាក់លើ លេខាធិការដ្ឋានទទួលបន្ទុកកិច្ចការមន្ត្រីរាជការ អគ្គាធិការដ្ឋានកិច្ចការតុលាការក្រសួងយុត្តិធម៌ ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ។

ព្រះរាជអាជ្ញាគប្បីជួយគាំទ្រដល់ជនរងគ្រោះ ដើម្បីអនុវត្តដីកានានាទាក់ទងនឹងជនរងគ្រោះ ។

ដីកាបង្គាប់ឱ្យសងសំណងនានា ត្រូវអនុវត្តជាបន្ទាន់ដោយព្រះរាជអាជ្ញា តាមការស្នើសុំរបស់ភាគីរងគ្រោះ ។

- ច្បាប់ស្តីពីនីតិវិធីព្រហ្មទណ្ឌ មាត្រា ១៥៣
- ប្រកាសលេខ ២៧ ចុះថ្ងៃទី ១១ មិថុនា ២០០៤ របស់ក្រសួងយុត្តិធម៌ ស្តីពីរបៀបរបបធ្វើការងាររបស់មន្ត្រីនគរបាលយុត្តិធម៌មាត្រា ៤- ២១ និង ២៦

ហាមឃាត់ការទាមទារកំរៃមិនផ្លូវការ ។

ជនរងគ្រោះមានសិទ្ធិទទួលព័ត៌មានអំពីការដោះលែង ឬការរត់គេចខ្លួនរបស់ជនជាប់ចោទទាក់ទងនឹងរឿងក្តីរបស់ខ្លួន (សំរាប់សុវត្ថិភាព) ។

ការផ្តល់នូវការលើកលែងទោស ឬបន្ធូរបន្ថយទោសឱ្យទណ្ឌិត ឬអំពើធ្វើឱ្យមានការប៉ះពាល់ណាមួយទៅលើសុវត្ថិភាពរបស់ជនរងគ្រោះ ត្រូវលើកយកមកពិចារណាឱ្យបានហ្មត់ចត់ដោយអាជ្ញាធរមានសមត្ថកិច្ច មុនពេលសម្រេចនូវចំណុចខាងលើនេះ ។

ក្រោយពីទទួលបានសេចក្តីណែនាំនេះ សូមមន្ត្រីអនុវត្តច្បាប់ដែលមានសមត្ថកិច្ចពាក់ព័ន្ធទាំងអស់ អនុវត្តនូវគោលការណ៍ និងបទបញ្ញត្តិទាំងនេះឱ្យបានសម្រេច និងប្រកបដោយប្រសិទ្ធិភាពខ្ពស់ ។ ក្រសួងយុត្តិធម៌សង្ឃឹមយ៉ាងមុតមាំថា មន្ត្រីអនុវត្តច្បាប់ទាំងអស់ច្បាស់ជាយកចិត្តទុកដាក់ខិតខំអនុវត្តតាមសេចក្តី

ណែនាំនេះ ដើម្បីចូលរួមអនុវត្តគោលនយោបាយកំណែទម្រង់ច្បាប់ និងតុលាការឱ្យទទួលបានជោគជ័យជូនរាជរដ្ឋាភិបាលពុំខានឡើយ ។ /.

រដ្ឋមន្ត្រី

អង្គ វង្សវឌ្ឍនៈ

ចំលងជូនៈ

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម
- ក្រសួងមហាផ្ទៃ
- ក្រសួងការពារជាតិ
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងពាណិជ្ជកម្ម
- ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- ក្រសួងបរិស្ថាន
- ក្រសួងសុខាភិបាល
  ដើម្បីចម្លងផ្សព្វផ្សាយ
- ឯកសារ-កាលប្បវត្តិ